

# សៀវភៅណែនាំស្តីពីនីតិវិធីគយ

# ប្រព័ន្ធឆ្លងកាត់គយអាស៊ាន (ACTS)

*“ឆ្ពោះទៅកាន់ការតភ្ជាប់ ប្រសិទ្ធភាព សមាហរណកម្ម សុវត្ថិភាព និងនិរន្តរភាពកាន់តែប្រសើរនៃការដឹកជញ្ជូនអាស៊ាន ដើម្បីពង្រឹងការប្រកួតប្រជែងរបស់អាស៊ាន និងជំរុញកំណើន និងការអភិវឌ្ឍដែលមាននៅក្នុងតំបន់”*

ប្រព័ន្ធឆ្លងកាត់គយអាស៊ាន
(ACTS)

ចក្ខុវិស័យតែមួយ
អត្តសញ្ញាណមួយ
សហគមន៍តែមួយ

# បុព្វបទ

សៀវភៅនេះផ្តល់នូវគោលការណ៍ណែនាំ និងនីតិវិធីសម្រាប់ប្រព័ន្ធឆ្លងកាត់គយអាស៊ាន (ACTS) ដែលមានចែងក្នុងឯកសារបទប្បញ្ញត្តិច្បាប់ និងបច្ចេកទេសក្នុងពិធីសារទី៧ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីការសម្របសម្រួលទំនិញឆ្លងកាត់ (AFAFGIT) និងឧបសម្ព័ន្ធរបស់ពិធីសារនោះ។

សៀវភៅនេះត្រូវបានបង្កើតឡើងសម្រាប់មន្ត្រីគយនៅក្នុងប្រទេសតំបន់អាស៊ាន ដើម្បីអនុញ្ញាតឱ្យមានការបកស្រាយនិងការអនុវត្តដូចគ្នានៃប្រព័ន្ធឆ្លងកាត់គយអាស៊ាន (ACTS) ហើយអាចប្រើប្រាស់ជានីតិវិធីប្រតិបត្តិ ឬជាឯកសារគោលសម្រាប់បណ្តុះបណ្តាល។

សៀវភៅណែនាំនេះត្រូវបានពិនិត្យ និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់ដើម្បីធានាថា សៀវភៅអាចអនុលោមទៅតាមការផ្លាស់ប្តូរនីតិវិធីឆ្លងកាត់គយនានា ទាំងនៅថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ។

សៀវភៅណែនាំនេះអាចប្រើរួមគ្នាជាមួយសៀវភៅ “មគ្គុទ្ទេសក៍អ្នកប្រើប្រាស់ប្រព័ន្ធ ACTS” ដែលបានផ្តល់ជូនដោយក្រុមការងារអនុវត្តគម្រោងប្រព័ន្ធ ACTS ហើយសៀវភៅណែនាំនេះផ្តល់ការណែនាំលម្អិតស្តីពីប្រតិបត្តិការរបស់ប្រព័ន្ធ ACTS។

# តារាងកំណែ

| ល.រ | កាលបរិច្ឆេទ | បរិយាយ |
|---|---|---|
| ១ | ០១ កក្កដា ២០២០ | ការប្រែសម្រួលរបស់ភ្នាក់ងារបកប្រែ |
| ២ | ០១ សីហា ២០២០ | ការត្រួតពិនិត្យ និងកែសម្រួលរបស់នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន |
| ៣ | ៣១ សីហា ២០២០ | ការធ្វើបច្ចុប្បន្នភាពសៀវភៅក្រោយពេលក្រុមការងារ ARISE Plus បានធ្វើការកែសម្រួលច្បាប់ដើមនៃសៀវភៅនេះពាក់ព័ន្ធនឹងការទូទាត់បំណុល |

# អក្សរសង្ខេប

| ពាក្យ | អត្ថន័យ | អត្ថន័យជាភាសាខ្មែរ |
|---|---|---|
| AAR | Anticipated Arrival Record | សារបញ្ជាក់ថានឹងមានប្រតិបត្តិការឆ្លងកាត់មកដល់ |
| ACTS | ASEAN Customs Transit System | ប្រព័ន្ធឆ្លងកាត់គយអាស៊ាន |
| AEO | Authorized Economic Operator | ប្រតិបត្តិករសេដ្ឋកិច្ចទទួលបានការអនុញ្ញាត |
| AFAFGIT | ASEAN Framework Agreement on the Facilitation of Goods In Transit | កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីការសម្របសម្រួលទំនិញឆ្លងកាត់ |
| AGVCBP | ASEAN Goods Vehicle Cross-Border Permit | លិខិតអនុញ្ញាតយានយន្តដឹកជញ្ជូនទំនិញឆ្លងកាត់ព្រំដែនអាស៊ាន |
| AHTN | ASEAN Harmonized Tariff Nomenclature | តារាងនាមវល្លិស៊ីចង្វាក់អាស៊ាន |
| AMS | ASEAN Member States | ប្រទេសសមាជិកអាស៊ាន |
| ARN | ACTS Reference Number | លេខយោងប្រតិវេទន៍ឆ្លងកាត់គយអាស៊ាន |
| ASEAN | Association of South-East Asian Nation | សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ |
| ATR | Anticipated Transit Record | សារបញ្ជាក់ថានឹងមានប្រតិបត្តិការឆ្លងកាត់ |
| ATT | Authorized Transit Trader | ប្រតិបត្តិករឆ្លងកាត់ទទួលបានការអនុញ្ញាត |
| CMT | Central Management Team | ក្រុមការងារគ្រប់គ្រងមជ្ឈឹម |
| GATT | General Agreement on Tariffs and Trade | កិច្ចព្រមព្រៀងទូទៅលើទំនិញនិងពាណិជ្ជកម្ម |
| GMS | Guarantee Management System | ប្រព័ន្ធគ្រប់គ្រងនិមុត្តិធានា |
| GRN | Guarantee Reference Number | លេខយោងនិមុត្តិធានា |
| GST | Goods and Services Tax | អាករលើទំនិញនិងសេវាកម្ម |
| IT | Information Technology | បច្ចេកវិទ្យាព័ត៌មាន |
| MIS | Management Information System | ប្រព័ន្ធគ្រប់គ្រងព័ត៌មាន |
| NCF | Notify Crossing Frontier | សារបញ្ជាក់ថាប្រតិបត្តិការបានឆ្លងកាត់ព្រំដែន |
| PCA | Post Clearance Audit | សវនកម្មក្រោយបញ្ចេញទំនិញពីគយ |
| PIN | Personal Identification Number | លេខអត្តសញ្ញាណបុគ្គល |
| PMS | Participated (ASEAN) Member States | ប្រទេសចូលរួមអនុវត្តប្រព័ន្ធ |
| RDS | Reference Data System | ប្រព័ន្ធគ្រប់គ្រងទិន្នន័យយោង |

| | | |
|---|---|---|
| RKC | Revised Kyoto Convention | អនុសញ្ញាក្រុងក្យូតូ |
| TAD | Transit Accompany Document | ប្រតិវេទន៍អមដំណើរឆ្លងកាត់ |
| TFA | Trade Facilitation Agreement | កិច្ចព្រមព្រៀងសម្រួលពាណិជ្ជកម្ម |
| TIN | Trader Identification Number | លេខអត្តសញ្ញាណធុរជន |
| TRN | Trader Reference Number | លេខចុះបញ្ជីធុរជន |
| VAT | Value Added Tax | អាករលើតម្លៃបន្ថែម |

# មាតិកា

ផ្នែកទី១÷ ការឆ្លងកាត់គយអាស៊ាន និងប្រព័ន្ធឆ្លងកាត់គយអាស៊ាន ..... 1
១. ការចរាចរណ៍ទំនិញឆ្លងកាត់អន្តរជាតិ..... 1
១.១. មុខងារសំខាន់ៗនៃការឆ្លងកាត់..... 1
១.២. ការឆ្លងកាត់ក្រោមរបបឆ្លងកាត់គយអាស៊ាននៅក្នុងប្រទេសដែលចូលរួមអនុវត្តប្រព័ន្ធ..... 1
១.៣. ទិដ្ឋភាពរបស់គយលើហានិភ័យនៃទំនិញឆ្លងកាត់ ..... 1
១.៤. តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ប្រតិបត្តិករដឹកជញ្ជូនឆ្លងកាត់..... 2
២. ប្រតិបត្តិការ និងនីតិវិធីនៃប្រព័ន្ធឆ្លងកាត់គយអាស៊ាន..... 4
២.១. នីតិវិធីគោលនៃប្រព័ន្ធឆ្លងកាត់គយអាស៊ាន..... 4
២.២. មុខងារប្រព័ន្ធ ACTS ..... 4
២.៣. ទិដ្ឋភាពទូទៅនៃប្រព័ន្ធឆ្លងកាត់គយអាស៊ាន ..... 6
ឧបសម្ព័ន្ធនៃផ្នែកទី១ ..... 7
ឧបសម្ព័ន្ធ ១ក÷ សាវតារនៃប្រព័ន្ធឆ្លងកាត់គយអាស៊ាន ..... 7
ឧបសម្ព័ន្ធ ១ខ÷ សន្ទានុក្រម ..... 8
ផ្នែកទី២÷ ប្រព័ន្ធ ACTS សម្រាប់ឈ្មួញ ..... 9
១. ការប្រើប្រាស់ប្រព័ន្ធ ACTS ក្នុងនាមជាប្រតិបត្តិករដឹកជញ្ជូន (ឬម្ចាស់ទំនិញ) ..... 9
១.១. តម្រូវការមូលដ្ឋានសម្រាប់ប្រើប្រាស់ប្រព័ន្ធ ACTS ..... 9
១.២. ការរៀបចំសម្រាប់ដំណើរការឆ្លងកាត់ ..... 9
២. ការប្រកាសប្រតិវេទន៍ឆ្លងកាត់..... 10
២.១. ការដាក់ប្រតិវេទន៍និងការផ្ទៀងផ្ទាត់ ..... 10
២.២. រំហូរនីតិវិធីប្រព័ន្ធ ACTS..... 10
៣. ដំណើរការឆ្លងកាត់..... 11
៣.១. ការបង្វែរតម្រាយផ្លូវ..... 11
៣.២. ឧប្បត្តិហេតុផ្សេងទៀត ..... 11
៣.៣. ការបញ្ឈប់ ឬការបញ្ចប់ប្រតិបត្តិការឆ្លងកាត់..... 12

៤. នីតិវិធីអនុវត្តពេលប្រព័ន្ធមិនដំណើរការ ..... 12
ឧបសម្ព័ន្ធនៃផ្នែកទី២ ..... 13
ឧបសម្ព័ន្ធ ២ក÷ ទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់ ..... 13
ឧបសម្ព័ន្ធ ២ខ÷ ការចុះឈ្មោះក្រុមហ៊ុននិងអ្នកប្រើប្រាស់ ..... 13
១. ការចុះឈ្មោះក្រុមហ៊ុន ..... 13
២. ទំនាក់ទំនងរវាងក្រុមហ៊ុន និងប្រតិវេទករ ..... 13
៣. ការចូលប្រើប្រាស់ប្រព័ន្ធតាមរយៈ: ACTS Trader Portal ..... 13
៤. ពាក្យស្នើសុំចុះបញ្ជីធុរជនតាមប្រព័ន្ធ ACTS ..... 14
៥. លិខិតផ្ទេរសិទ្ធរវាងម្ចាស់ទំនិញនិងជើងសាក្នុងប្រព័ន្ធ ACTS ..... 15
៦. ពាក្យសុំសម្រាប់បុគ្គលិកក្រុមហ៊ុនដែលទទួលបានការផ្ទេរសិទ្ធដើម្បីប្រកាសប្រតិវេទន៍ ACTS ..... 16
ផ្នែកទី៣÷ ប្រតិបត្តិករឆ្លងកាត់ទទួលបានការអនុញ្ញាត និងនីតិវិធីសាមញ្ញ ..... 17
១. គោលបំណងនៃនីតិវិធីសាមញ្ញ ..... 17
២. មូលដ្ឋានសម្រាប់ទទួលបានសិទ្ធិជាប្រតិបត្តិករឆ្លងកាត់ទទួលបានការអនុញ្ញាត ..... 17
៣. ពាក្យសុំសម្រាប់ប្រតិបត្តិករឆ្លងកាត់ទទួលបានការអនុញ្ញាត (ATT) ..... 18
៤. នីតិវិធីសាមញ្ញ ..... 20
៤.១. ការលើកលែងពីការបង្ហាញទំនិញនៅការិយាល័យចេញដំណើរ ..... 20
៤.២. ការប្រើប្រាស់ស្នៀលពិសេសដែលទទួលបានការអនុញ្ញាត ..... 20
៤.៣. និមុត្តិធានាសម្រាប់ប្រតិបត្តិការច្រើនលើក ..... 20
៤.៤. ការអនុញ្ញាតបញ្ចប់នីតិវិធីនៅទីតាំងរបស់ធុរជន ..... 21
៤.៥. ទីតាំងដែលទទួលបានអនុញ្ញាត ..... 22
ឧបសម្ព័ន្ធនៃផ្នែកទី៣ ..... 23
ឧបសម្ព័ន្ធ ៣ក÷ ប្រតិបត្តិការឆ្លងកាត់ទទួលបានការអនុញ្ញាត និងការអនុញ្ញាត ..... 23
ឧបសម្ព័ន្ធ ៣ខ÷ ពាក្យសុំប្រតិបត្តិករឆ្លងកាត់ដែលទទួលបានការអនុញ្ញាត ..... 24
ផ្នែកទី៤÷ ការិយាល័យគ្រប់គ្រងនិមុត្តិធានា ..... 38
១. និមុត្តិធានា ..... 38

១.១. និមុត្តិធានាសម្រាប់ប្រតិបត្តិការតែមួយលើក ........ 38
១.២. និមុត្តិធានាសម្រាប់ប្រតិបត្តិការច្រើនលើក និងបរិមាណយោង ........ 38
២. ការគ្រប់គ្រងនិមុត្តិធានាតាមប្រព័ន្ធ ACTS ........ 39
២.១. ការចុះបញ្ជិកា និងសុពលភាព ........ 39
២.២. ការផ្ទៀងផ្ទាត់ការប្រើប្រាស់និមុត្តិធានា ........ 39
២.៣. ការប្រើប្រាស់និមុត្តិធានា ........ 39
២.៤. ការបញ្ចេញការប្រើប្រាស់និមុត្តិធានា ........ 40
ឧបសម្ព័ន្ធនៃផ្នែកទី៤ ........ 41
ឧបសម្ព័ន្ធ ៤ក÷ ឯកសារនិមុត្តិធានាសម្រាប់ប្រតិបត្តិការមួយលើក ........ 41
ឧបសម្ព័ន្ធ ៤ខ÷ ឯកសារនិមុត្តិធានាសម្រាប់ប្រតិបត្តិការច្រើនលើក ........ 45
ផ្នែកទី៥÷ វិធានតិវិធីនៃប្រព័ន្ធ ACTS ........ 49
១. នៅការិយាល័យចេញដំណើរ ........ 49
១.១. ភារកិច្ចរបស់ម្ចាស់ទំនិញ ........ 49
១.២. ភារកិច្ចរបស់មន្ត្រីគយ ........ 50
២. នៅការិយាល័យគយឆ្លងកាត់ ........ 51
២.១. សារបញ្ជាក់ថាប្រតិបត្តិការបានឆ្លងកាត់ព្រំដែន (NCF) ........ 51
៣. នៅការិយាល័យគម្រដ្ឋាន ........ 51
៣.១. សារបញ្ជាក់ថាបានមកដល់ (Arrival Advice) ........ 51
៣.២. ការបញ្ចប់ការឆ្លងកាត់ ........ 52
ឧបសម្ព័ន្ធនៃផ្នែកទី៥ ........ 53
ឧបសម្ព័ន្ធ ៥ក÷ តារាងវិធានិដ្ឋភាពទូទៅនៃដំណើរការ ........ 53
ឧបសម្ព័ន្ធ ៥ខ÷ សៀវលសុវត្ថិភាព ........ 54
១. គោលបំណងរបស់សៀវល ........ 54
២. លក្ខណៈសំខាន់ៗរបស់សៀវល ........ 54
៣. លក្ខណៈបច្ចេកទេស ........ 55

៤. វិធីសាស្ត្រនៃការកិបសៀល ........ 55

៥. ការលះបង់ចោលលក្ខខណ្ឌតម្រូវសៀល ........ 55

៦. ការដឹកជញ្ជូនដែលសមស្របសម្រាប់កិបសៀល ........ 55

ឧបសម្ព័ន្ធ ៥គ÷ ប្រតិវេទន៍អមដំណើរឆ្លងកាត់ (TAD) ........ 56

១. បញ្ជីមុខទំនិញ TAD ........ 57

២. ទម្រង់រាយការណ៍ឧប្បត្តិហេតុ ........ 58

ឧបសម្ព័ន្ធ ៥ឃ÷ ភាពជាក់លាក់នៃការផ្ទៀងផ្ទាត់ប្រតិវេទន៍ ........ 60

ផ្នែកទី៦÷ ការិយាល័យចេញដំណើរ ........ 61

១. ការត្រួតពិនិត្យធម្មតានៅការិយាល័យចេញដំណើរ ........ 61

១.១. វិធានការត្រួតពិនិត្យនៅការិយាល័យចេញដំណើរ ........ 61

២. នីតិវិធីសាមញ្ញនៅការិយាល័យចេញដំណើរ ........ 63

២.១. ទំនិញជាប់កម្រិតកំណត់ ........ 64

២.២. វិធានត្រួតពិនិត្យនៅការិយាល័យចេញដំណើរ ........ 64

៣. ការឆ្លងកាត់ ........ 65

៣.១. ការឆ្លងកាត់ត្រឹមត្រូវ ........ 65

៣.២. ដំណើរការឆ្លងកាត់មិនប្រក្រតី ........ 66

ឧបសម្ព័ន្ធនៃផ្នែកទី៦ ........ 67

ឧបសម្ព័ន្ធ ៦ក÷ គោលការណ៍នៃការគ្រប់គ្រងហានិភ័យ ........ 67

ផ្នែកទី៧÷ ការិយាល័យគយឆ្លងកាត់ ........ 73

១. បុរេត្រួតពិនិត្យ ........ 73

២. ស្ថានភាពនិងការទទួលស្គាល់ដំណើរការឆ្លងកាត់ ........ 73

២.១. គ្មានសារបញ្ជាក់ថានឹងមានប្រតិបត្តិការឆ្លងកាត់ (ATR) ........ 74

៣. ការសម្រេចចិត្តត្រួតពិនិត្យដំណើរការឆ្លងកាត់ ........ 74

៣.១. សារបញ្ជាក់ថាប្រតិបត្តិការបានឆ្លងកាត់ព្រំដែន (NCF) ........ 74

ផ្នែកទី៨÷ ការិយាល័យគម្រោងដ្ឋាន ........ 75

១. ការត្រួតពិនិត្យមុនការមកដល់......75
១.១. នីតិវិធីធម្មតា ឬនីតិវិធីសាមញ្ញ......75
២. ការមកដល់ក្រោមនីតិវិធីធម្មតា......75
២.១. ការមកដល់ត្រឹមត្រូវតាមលក្ខខណ្ឌ......75
២.២. ការមកដល់មិនត្រឹមត្រូវតាមលក្ខខណ្ឌ......76
២.៣. ការសម្រេចចិត្តត្រួតពិនិត្យ......76
២.៤. ភាពមិនប្រក្រតី......77
៣. ការមកដល់ក្រោមនីតិវិធីសាមញ្ញ......77
៣.១. ការបញ្ចេញទំនិញដោយស្វ័យប្រវត្តិ......78
៣.២. ព័ត៌មាននៃការទម្លាក់ទំនិញ......78
៣.៣. ការគ្រប់គ្រងការពិនិត្យ......78
៣.៤. ភាពមិនប្រក្រតី......79
ផ្នែកទី៩÷ ការបង្វែរ ឬការមិនប្រគល់ទំនិញ......80
១. ការបង្វែរទៅកាន់ការិយាល័យឆ្លងកាត់ ឬការិយាល័យគម្រូដ្ឋានដែលមិនបានប្រកាស......80
១.១. ការទាញយកព័ត៌មានប្រតិវេទន៍......80
១.២. ការិយាល័យឆ្លងកាត់ផ្សេងទៀត......80
២. ឧប្បត្តិហេតុផ្សេងៗ......81
៣. ការលុបចោលប្រតិវេទន៍ឆ្លងកាត់......82
ផ្នែកទី១០÷ នីតិវិធីអនុវត្តពេលប្រព័ន្ធមិនដំណើរការ......83
១. ពេលណាត្រូវប្រើនីតិវិធីអនុវត្តពេលប្រព័ន្ធមិនដំណើរការ......83
២. វិធានការពេលប្រតិបត្តិការមិនដំណើរការនៅការិយាល័យចេញដំណើរ......83
៣. វិធានការពេលប្រតិបត្តិការមិនដំណើរការនៅការិយាល័យគយឆ្លងកាត់......83
៤. វិធានការពេលប្រតិបត្តិការមិនដំណើរការនៅការិយាល័យគម្រូដ្ឋាន......84
៥. វិធានការនៅពេលដែលប្រព័ន្ធ ACTS មានដំណើរការឡើងវិញ......85
៦. តារាងសង្ខេបនីតិវិធីនៅពេលប្រព័ន្ធ ACTS មិនមានដំណើរការ......86

ផ្នែកទី១១៖  ការសាកសួរ និងការប្រមូលបំណុលគយមកវិញ ........................................................ 87
១. នីតិវិធីសាកសួររបស់ប្រព័ន្ធ........................................................................................ 87
១.១. សារបញ្ជាក់នានា .................................................................................................. 87
១.២. ការចាប់ផ្ដើមនីតិវិធីសាកសួរ ..................................................................................... 87
១.៣. ភស្តុតាងដែលបានផ្ដល់ដោយម្ចាស់ទំនិញ...................................................................... 87
២. នីតិវិធីប្រមូលបំណុលគយមកវិញតាមប្រព័ន្ធ ACTS......................................................... 88
២.១. ការចាត់វិធានការប្រមូលបំណុលគយមកវិញ.................................................................... 88
ឧបសម្ព័ន្ធនៃផ្នែកទី១១ ...................................................................................................... 92
ឧបសម្ព័ន្ធ ១១ក៖ ការសាកសួរ និងការប្រមូលបំណុលមកវិញ .................................................. 92
១. សេចក្ដីផ្ដើម........................................................................................................... 92
២. បញ្ជីសកម្មភាពរួម.................................................................................................... 92
ឧបសម្ព័ន្ធ ១១ខ៖ ការសាកសួរការបញ្ចប់ប្រតិបត្តិការឆ្លងកាត់ .................................................... 94
ឧបសម្ព័ន្ធ ១១គ៖ ជំនួយទៅវិញទៅមកសម្រាប់ការទូទាត់សំណង ................................................ 95
ឧបសម្ព័ន្ធ ១១ឃ៖ ការសាកសួរការបញ្ចប់ដំណើរការឆ្លងកាត់ (សម្រាប់គយ) .................................. 97
ឧបសម្ព័ន្ធ ១១ង៖ ការសាកសួរការបញ្ចប់ដំណើរការឆ្លងកាត់ (សម្រាប់អ្នកធានា)............................. 99
ឧបសម្ព័ន្ធ ១១ច៖ ការទាមទារសំណងសម្រាប់ប្រមូលបំណុលគយមកវិញ ...................................... 100
ផ្នែកទី១២៖ ការពន្យល់នីតិវិធីគយក្នុងទម្រង់ជាតារាងរំហូរនីតិវិធី................................................ 101
១. នីតិវិធីគយតាមប្រព័ន្ធ ACTS - តារាងរំហូរនីតិវិធី............................................................ 101
១.១. ស្វែងយល់អំពីសញ្ញាតារាងរំហូរ................................................................................... 101
១.២. ដំណើរការប្រព័ន្ធ.................................................................................................... 101
១.៣. រូបសញ្ញាប្រើក្នុងតារាងរំហូរទាំងនេះ............................................................................. 102
១.៤. ទិដ្ឋភាពទូទៅនៃរំហូរនីតិវិធីសំខាន់ៗ ............................................................................ 104
១.៥. ដំណើរការទទួលយកប្រតិវេទន៍ ACTS ........................................................................ 105
១.៦. ការត្រួតពិនិត្យប្រតិវេទន៍តាមប្រព័ន្ធ ACTS ក្រោមនីតិវិធីធម្មតា ........................................ 107
១.៧. ការត្រួតពិនិត្យប្រតិវេទន៍តាមប្រព័ន្ធ ACTS ក្រោមនីតិវិធីសាមញ្ញ....................................... 109

**១.៨. ដំណើរការនៅការិយាល័យចេញដំណើរ ការបញ្ចេញទំនិញសម្រាប់ឆ្លងកាត់** .................... 111

**១.៩. ការចុះបញ្ជិកានិមុត្តិធានាតាមប្រព័ន្ធ** ACTS .................... 113

**១.១០. ដំណើរការតាមប្រព័ន្ធ** ACTS **នៅការិយាល័យឆ្លងកាត់** .................... 115

**១.១១. ដំណើរការមកដល់តាមប្រព័ន្ធ** ACTS - **នីតិវិធីធម្មតា** .................... 117

**១.១២. ដំណើរការមកដល់តាមប្រព័ន្ធ** ACTS - **នីតិវិធីសាមញ្ញ** .................... 119

**១.១៣. ការគ្រប់គ្រងនិមុត្តិធានាតាមប្រព័ន្ធ** ACTS - **ការបញ្ចេញការប្រើប្រាស់និមុត្តិធានា** .................... 121

**១.១៤. នីតិវិធីសាកសួរតាមប្រព័ន្ធ** ACTS .................... 123

**១.១៥. នីតិវិធីប្រមូលបំណុលមកវិញតាមប្រព័ន្ធ** ACTS .................... 125

# ផ្នែកទី១÷ ការឆ្លងកាត់គយអាស៊ាន និងប្រព័ន្ធឆ្លងកាត់គយអាស៊ាន

## ១. ការចរាចរណ៍ទំនិញឆ្លងកាត់អន្តរជាតិ

នៅពេលទំនិញចូលប្រទេសណាមួយ ទំនិញទាំងនោះអាចនឹងត្រូវជាប់ពន្ធ អាករ និងកម្រៃផ្សេងៗលើការនាំចូល បន្ទាប់មកទើបអាចអនុវត្តវិធានគោលនយោបាយជាតិផ្សេងទៀត។ ដោយឡែក ទំនិញឆ្លងកាត់ប្រទេសកម្ពុជាទាំងអស់ត្រូវស្ថិតក្រោមរបបព្យួរពន្ធ។ នីតិវិធីនេះ ក៏អាចនឹងត្រូវអនុវត្តនៅប្រទេសបន្ទាប់ទៀតនៅពេលទំនិញឆ្លងកាត់ប្រទេសនោះដែរ។ ទំនិញអាចត្រូវឆ្លងកាត់នីតិវិធីនានាជាបន្តបន្ទាប់នៅច្រកព្រំដែន មុនពេលទៅដល់គោលដៅចុងក្រោយ។

### ១.១. មុខងារសំខាន់ៗនៃការឆ្លងកាត់

ការឆ្លងកាត់អន្តរជាតិ គឺជាយន្តការគយដែលអនុញ្ញាតឱ្យប្រតិបត្តិករដែលដឹកទំនិញឆ្លងកាត់ព្រំដែនចូលមកក្នុងប្រទេស ដោយមិនបង់ពន្ធ និងអាករនានាប្រសិនបើទំនិញទាំងនោះត្រូវបានចេញពីប្រទេសវិញ។ យន្តការនេះផ្តល់នូវនីតិវិធីរដ្ឋបាលសាមញ្ញ និងចំណាយតិចដើម្បីដឹកទំនិញឆ្លងកាត់ដែនគយ។

### ១.២. ការឆ្លងកាត់ក្រោមរបបឆ្លងកាត់គយអាស៊ាននៅក្នុងប្រទេសដែលចូលរួមអនុវត្តប្រព័ន្ធ

ប្រព័ន្ធឆ្លងកាត់គយអាស៊ាន គឺជាប្រព័ន្ធត្រួតពិនិត្យមួយដែលត្រូវបានរចនាឡើងដើម្បីជួយសម្រួលដល់ដំណើរការឆ្លងកាត់ក្នុងរដ្ឋសមាជិកអាស៊ានដែលចូលរួមអនុវត្តប្រព័ន្ធ (PMS)។ ប្រព័ន្ធនេះ ផ្តល់នូវលទ្ធភាពនៃការចំណាយលើការដឹកជញ្ជូនយ៉ាងទាបបំផុត ការកាត់បន្ថយការត្រួតពិនិត្យទំនិញ រួមទាំងការលើកទឹកចិត្តដល់ធុរជនដែលមានអនុលោមភាពខ្ពស់នូវប្រសិទ្ធភាពបន្ថែមតាមរយៈនីតិវិធីសាមញ្ញ (Simplified Procedure)។ ប្រព័ន្ធ ACTS ក៏អាចផ្តល់ឱ្យអាជ្ញាធរគយនូវមធ្យោបាយអេឡិចត្រូនិក ដើម្បីត្រួតពិនិត្យប្រតិបត្តិការឆ្លងកាត់ ប្រកបដោយប្រសិទ្ធភាពផងដែរ។

### ១.៣. ទិដ្ឋភាពរបស់គយលើហានិភ័យនៃទំនិញឆ្លងកាត់

ការអនុញ្ញាតឱ្យឆ្លងកាត់ទាំងអស់ ត្រូវបានកំណត់ដោយការវាយតម្លៃហានិភ័យ ទោះបីជាប្រភេទទំនិញអ្វីក៏ដោយ ធុរជនមានអនុលោមភាពខ្ពស់ក៏ដោយ ឬតម្រាយផ្លូវដែលមានការអនុញ្ញាតក៏ដោយ។

#### ១.៣.១. ការគ្រប់គ្រងហានិភ័យរបស់ប្រព័ន្ធឆ្លងកាត់គយ

ប្រព័ន្ធឆ្លងកាត់មួយដែលអាចគ្រប់គ្រងហានិភ័យបាន គួរមានមុខងារសំខាន់ៗ ដូចខាងក្រោម÷

- មានចំណេះដឹងអំពីអ្នកដាក់ពាក្យសុំ និង/ឬប្រតិបត្តិករឆ្លងកាត់
- មានសមត្ថភាពក្នុងការទូទាត់ប្រាក់ពន្ធ អាករ ណាមួយក្នុងករណីដែលទំនិញត្រូវបានបាត់បង់ឬបង្វែរ
- កំណត់អត្តសញ្ញាណទំនិញណាមួយដែលបង្ហាញពីហានិភ័យដែលមិនអាចទទួលយកបាន
- ធានាថា ទំនិញមិនអាចត្រូវបានបន្ថែមចូល ឬដកចេញនៅពេលធ្វើប្រតិបត្តិការឆ្លងកាត់ និង
- មានសមត្ថភាពតាមដានប្រតិបត្តិការឆ្លងកាត់ពីការិយាល័យចេញដំណើរដល់ការិយាល័យគម្យដ្ឋាន។

#### ១.៣.២. ការគ្រប់គ្រងហានិភ័យរបស់ប្រព័ន្ធឆ្លងកាត់គយអាស៊ាន

ប្រព័ន្ធឆ្លងកាត់គយអាស៊ាន ធ្វើការគ្រប់គ្រងហានិភ័យដោយប្រើប្រាស់មុខងារសំខាន់ៗ ដូចខាងក្រោម÷

- មានលទ្ធភាពកំណត់អត្តសញ្ញាណធុរជន (ម្ចាស់ទំនិញ) ស្ថិតក្រោមច្បាប់គយរបស់បណ្តារដ្ឋសមាជិកដែលចូលរួមអនុវត្តប្រព័ន្ធ ហើយមានលទ្ធភាពទទួលខុសត្រូវចំពោះប្រតិបត្តិការឆ្លងកាត់
- ប្រតិវេទករ (ម្ចាស់ទំនិញ) បានតម្កល់និមុត្តិធានា ដែលគ្របដណ្តប់ទាំងស្រុងលើប្រាក់ពន្ធនិងអាករ (បំណុលគយ) ហើយនិមុត្តិធានានេះអាចត្រូវបានទាមទារដោយរដ្ឋសមាជិកណាមួយដែលដឹកជញ្ជូនឆ្លងកាត់ ក្នុងករណីរកឃើញថា ទំនិញត្រូវបានបាត់បង់ដោយផ្នែក ឬទាំងស្រុងនៅប្រទេសនោះ
- ការកំណត់នូវបញ្ជីទំនិញដែលអនុញ្ញាតឱ្យឆ្លងកាត់ និងទំនិញដកចេញពីការឆ្លងកាត់
- ទំនិញត្រូវបានផ្ទុកនៅក្នុងរថយន្ត ឬកុងតឺន័រដែលមានសុវត្ថិភាព និង
- ការផ្ញើសារអេឡិចត្រូនិកដើម្បីតាមដានប្រតិបត្តិការឆ្លងកាត់នៅព្រំដែននីមួយៗតាំងពីការិយាល័យចេញដំណើរដល់ការិយាល័យគម្យដ្ឋាន។

### ១.៤. តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ប្រតិបត្តិករដឹកជញ្ជូនឆ្លងកាត់

បុគ្គលដែលទទួលខុសត្រូវចំពោះប្រតិបត្តិការដឹកជញ្ជូនឆ្លងកាត់គឺ "ម្ចាស់ទំនិញ" ដែលធ្វើការដាក់ឯកសារនៅក្នុងប្រព័ន្ធ ACTS ហើយអាចជាម្ចាស់ទំនិញផ្ទាល់ ឬជាតំណាងរបស់ម្ចាស់ទំនិញ (ក្រុមហ៊ុនដឹកជញ្ជូន)។

#### ១.៤.១. ដំណើរការនីតិវិធីប្រព័ន្ធឆ្លងកាត់គយអាស៊ាន

ម្ចាស់ទំនិញ (ឬអ្នកតំណាង) ត្រូវចុះបញ្ជីនៅក្នុងប្រព័ន្ធ ACTS និង÷

- ផ្តួចផ្តើមប្រតិបត្តិការឆ្លងកាត់ ហើយត្រូវទទួលខុសត្រូវចំពោះនីតិវិធីនៃប្រព័ន្ធ ACTS រហូតដល់ប្រតិបត្តិការត្រូវបានបញ្ចប់
- តម្កល់និមុត្តិធានាជូនរដ្ឋបាលគយដើម្បីធានាលើហានិភ័យនៃការបាត់បង់ចំណូល
- ដាក់ប្រតិវេទន៍តាមទម្រង់អេឡិចត្រូនិកជូនរដ្ឋបាលគយតាមរយៈប្រព័ន្ធ ACTS
- បង្ហាញនូវទំនិញនិងឯកសារអមភ្ជាប់នានាជូនមន្ត្រីគយនៅការិយាល័យចេញដំណើរដើម្បីធ្វើការត្រួតពិនិត្យ។

##### ក. ការអនុញ្ញាតឱ្យឆ្លងកាត់

- ទំនិញត្រូវបានធានាសុវត្ថិភាពយ៉ាងត្រឹមត្រូវហើយផ្ទុកក្នុងកុងតឺន័រ ឬមធ្យោបាយដឹកជញ្ជូនដែលមានភ្ជាប់ជាមួយសៀលគយដែលអាចការពារបាន
- អ្នកបើកបរធ្វើការចេញដំណើរដោយគោរពតាមការណែនាំនានានៅតាមតម្រាយផ្លូវ។ អ្នកបើកបរត្រូវយកជាមួយនូវប្រតិវេទន៍អមដំណើរឆ្លងកាត់ (TAD) ដែលបោះពុម្ពដោយមន្ត្រីគយដែលមានលេខប្រតិវេទន៍ និងការបរិយាយនានារបស់ទំនិញដែលដឹកជញ្ជូនឆ្លងកាត់
- ប្រតិវេទន៍អម (TAD) និងទំនិញ ព្រមទាំងសៀលគយត្រូវបង្ហាញជូនមន្ត្រីគយនៅមាត់ច្រកឆ្លងកាត់

- អ្នកបើកបរបញ្ចប់ប្រតិបត្តិការរបស់ខ្លួនដោយបង្ហាញឯកសារ និងទំនិញដល់មន្ត្រីគយនៅការិយាល័យគយគម្យដ្ឋាន។

### ខ. ការិយាល័យគម្យដ្ឋាន

ការត្រួតពិនិត្យរបស់មន្ត្រីគយនៅការិយាល័យគម្យដ្ឋានដើម្បីធានាថា៖

- ទំនិញត្រូវបានបង្ហាញ ហើយត្រូវបានផ្ទុកក្នុងសៀលដោយមិនមានភាពមិនប្រក្រតីនានា។ បន្ទាប់មក បរិមាណនិមុត្តិធានាត្រូវបានបញ្ចេញវិញ ឬ
- ភាពមិនប្រក្រតីនានាត្រូវបានរកឃើញ ឬទំនិញត្រូវបានបាត់បង់ ម្ចាស់ទំនិញត្រូវទទួលខុសត្រូវរហូតដល់មានដំណោះស្រាយសមស្រប។

### គ. ឱកាសសម្រាប់នីតិវិធីសាមញ្ញ

ប្រតិបត្តិករឆ្លងកាត់អាចធ្វើការស្នើសុំដើម្បីក្លាយជា "ប្រតិបត្តិករឆ្លងកាត់ទទួលបានការអនុញ្ញាត (ATT)"។ មុខងារនេះតម្រូវឱ្យមានការវាយតម្លៃពីមន្ត្រីគយតាមរយៈបទពិសោធន៍ ភាពជឿជាក់ និងស្ថិរភាពហិរញ្ញវត្ថុ។ ប្រតិបត្តិករឆ្លងកាត់ទទួលបានការអនុញ្ញាត (ATT) អាចទទួលបានការលើកទឹកចិត្តនានាមានដូចជា៖ ការកាត់បន្ថយបរិមាណនិមុត្តិធានា ការកាត់បន្ថយការត្រួតពិនិត្យ និងការអនុញ្ញាតឱ្យបំពេញបែបបទនៅទីតាំងណាមួយក៏បានដែលទីតាំងនោះត្រូវមានការអនុញ្ញាតជាមុនពីគយ។

(សូមមើល "ផ្នែកទី៣៖ ប្រតិបត្តិករទទួលបានការអនុញ្ញាតនិងនីតិវិធីសាមញ្ញ" សម្រាប់ព័ត៌មានលម្អិត)

## ១.៤.២. ការដាក់ប្រតិវេទន៍ឆ្លងកាត់គយអាស៊ាន

នៅពេលរៀបចំដាក់ប្រតិវេទន៍ឆ្លងកាត់គយអាស៊ាន ម្ចាស់ទំនិញត្រូវផ្តល់ព័ត៌មានដែលត្រឹមត្រូវយ៉ាងលម្អិតដើម្បីកំណត់ឱ្យបានត្រឹមត្រូវនូវទំនិញដែលមានបំណងដឹកជញ្ជូនឆ្លងកាត់ និងការវេចខ្ចប់របស់ទំនិញទាំងនោះ។ ព័ត៌មានប្រតិវេទន៍ត្រូវបានប្រើប្រាស់សម្រាប់ផ្ទៀងផ្ទាត់ថាតើ ទំនិញទាំងនោះពិតជាអាចអនុញ្ញាតឱ្យឆ្លងកាត់ (ឧ. មិនស្ថិតក្រោមបញ្ជីទំនិញដកចេញពីការឆ្លងកាត់) និងដើម្បីគណនាប្រាក់ពន្ធសមស្របសម្រាប់តម្កល់និមុត្តិធានា។

## ១.៤.៣. និមុត្តិធានា និងអ្នកធានា

និមុត្តិធានាគឺជាបរិមាណទឹកប្រាក់ដែលតម្កល់ទុក ឬអាចប្រើប្រាស់បានដោយគយក្នុងករណីមានបទល្មើស ឬភាពមិនប្រក្រតីនានា ដូចជាការបាត់បង់ ឬការបង្វែរទំនិញ។ បរិមាណនៃនិមុត្តិធានាត្រូវបានគណនាដោយយកតាមអត្រានៃប្រទេសឆ្លងកាត់ណាមួយដែលខ្ពស់ជាងគេ។ និមុត្តិធានាត្រូវបានរក្សាទុកដោយគយ (ការិយាល័យគ្រប់គ្រងនិមុត្តិធានា) នៃប្រទេសចេញដំណើររហូតដល់បញ្ចប់ក្នុងករណីមិនមានភាពមិនប្រក្រតី។

### ក. អ្នកធានា

អ្នកធានាគឺជានីតិបុគ្គល (ឧ. ធនាគារ) ដែលទទួលខុសត្រូវក្នុងការបង់ពន្ធ និងអាករ ក្នុងករណីដែលមានភាពមិនប្រក្រតី ហើយដែលម្ចាស់ទំនិញមិនមានលទ្ធភាពបង់ប្រាក់ពន្ធ និងអាករទាំងនោះ។ អ្នកធានាត្រូវទទួលបាន

ការអនុញ្ញាតជាមុនពីគយនៅក្នុងប្រទេសដែលចាប់ផ្តើមប្រតិបត្តិការឆ្លងកាត់។ សម្រាប់ការអនុវត្តជំហានដំបូងរបស់ប្រព័ន្ធ ACTS រដ្ឋសមាជិកនឹងទទួលយកតែនិមុត្តិធានាដែលចេញដោយធនាគារតែប៉ុណ្ណោះ។

### ខ. ប្រភេទនិមុត្តិធានា

- **និមុត្តិធានាសម្រាប់តែប្រតិបត្តិការមួយលើក**

គ្របដណ្តប់ទៅលើប្រតិបត្តិការតែមួយលើកតាមការស្នើសុំរបស់ម្ចាស់ទំនិញ មានលទ្ធភាពគ្របដណ្តប់លើប្រាក់ពន្ធ អាករ និងកម្រៃនានាទាំងស្រុងនៃទំនិញដែលដឹកជញ្ជូនឆ្លងកាត់។

- **និមុត្តិធានាសម្រាប់ប្រតិបត្តិការច្រើនលើក**

គ្របដណ្តប់លើប្រតិបត្តិការដឹកជញ្ជូនច្រើនលើក លើបរិមាណណាមួយដែលស្មើទៅនឹង ១០០% នៃប្រាក់ពន្ធអាករ និងកម្រៃផ្សេងៗក្នុងករណីដែលមានភាពមិនប្រក្រតីនានា ក្នុងរង្វង់យ៉ាងតិច ១ សប្តាហ៍នៃប្រតិបត្តិការឆ្លងកាត់។

## ២. ប្រតិបត្តិការ និងនីតិវិធីនៃប្រព័ន្ធឆ្លងកាត់គយអាស៊ាន

### ២.១. នីតិវិធីគោលនៃប្រព័ន្ធឆ្លងកាត់គយអាស៊ាន

សៀវភៅណែនាំប្រតិបត្តិការនេះ ត្រូវបានរៀបចំឡើងស្របតាមផ្នែកផ្សេងៗនៃការទទួលខុសត្រូវរបស់អ្នកប្រើប្រាស់ដូចជា ប្រតិបត្តិករដែលបានចុះបញ្ជី ឬប្រតិបត្តិករដឹកជញ្ជូនឆ្លងកាត់ និងមន្ត្រីគយនៃប្រទេសឆ្លងកាត់។ ទំនួលខុសត្រូវនិងទំនាក់ទំនងសំខាន់ៗទាំងនេះត្រូវបានដាក់ជាក្រុមនៅក្នុងសៀវភៅណែនាំនេះ ដូចខាងក្រោម÷

- ផ្នែកទី២ ដល់ទី៤÷ ពន្យល់ដល់ធុរជន និងប្រតិបត្តិករដឹកជញ្ជូនពីរបៀបប្រើប្រាស់ប្រព័ន្ធ ACTS និងមុខងារនៃនិមុត្តិធានា និងអ្នកធានា
- ផ្នែកទី៥ ដល់ទី១២÷ សេចក្តីសង្ខេបស្តីពីការត្រួតពិនិត្យគយនៅក្នុងប្រព័ន្ធ ACTS និងសេចក្តីណែនាំលម្អិតស្តីពីនីតិវិធីគ្រប់គ្រងនៅការិយាល័យគយចេញដំណើរ ការិយាល័យគយឆ្លងកាត់ និងការិយាល័យគយគម្យដ្ឋាន។

### ២.២. មុខងារប្រព័ន្ធ ACTS

- ម្ចាស់ទំនិញតម្កល់និមុត្តិធានានៅធនាគារ ហើយយកលិខិតបញ្ជាក់និមុត្តិធានានោះដាក់ជូនមន្ត្រីទទួលបន្ទុកគ្រប់គ្រងនិមុត្តិធានា។ ទម្រង់នៃនិមុត្តិធានាមានចែងនៅក្នុងឧបសម្ព័ន្ធនៃផ្នែកទី៤ នៃសៀវភៅនេះ
- ព័ត៌មាននៃនិមុត្តិធានាត្រូវបានកត់ត្រាទុកចូលក្នុងប្រព័ន្ធដោយមានលេខយោងនិមុត្តិធានា (GRN) ជាសម្គាល់
- ម្ចាស់ទំនិញបំពេញប្រតិវេទន៍ឆ្លងកាត់ជាទម្រង់អេឡិចត្រូនិកនៅការិយាល័យគយចេញដំណើរដោយប្រើប្រាស់លេខយោងនិមុត្តិធានា (GRN) ដែលទទួលបាន
- ប្រព័ន្ធ ACTS ធ្វើការផ្ទៀងផ្ទាត់និមុត្តិធានាដោយគណនាប្រាក់ពន្ធនិងអាករដែលខ្ពស់បំផុតនៅក្នុងចំណោមបណ្តាប្រទេសដែលដឹកជញ្ជូនឆ្លងកាត់

- មន្ត្រីគយកិបសៀលលើមធ្យោបាយដឹកជញ្ជូន (ក្នុងករណីនីតិវិធីសាមញ្ញ ប្រតិបត្តិករជាអ្នកកិបសៀលដោយខ្លួនឯង)
- ក្នុងករណីការផ្ទៀងផ្ទាត់ទទួលបានជោគជ័យ ប្រតិវេទន៍ឆ្លងកាត់នឹងត្រូវបានចុះបញ្ជីដោយទទួលបាននូវលេខយោងប្រតិវេទន៍ឆ្លងកាត់គយអាស៊ាន (ARN) ដើម្បីសម្គាល់ប្រតិបត្តិការនោះ
- ប្រតិវេទន៍អមដំណើរឆ្លងកាត់ (TAD) ត្រូវបានបោះពុម្ពចេញហើយត្រូវយកតាមមធ្យោបាយដឹកជញ្ជូនចាប់ពីការិយាល័យគយចេញដំណើររហូតដល់ការិយាល័យគយគម្យដ្ឋាន។ ទម្រង់នៃ TAD ត្រូវបានបង្ហាញនៅក្នុងផ្នែកទី៥ ឧបសម្ព័ន្ធ ៥គ នៃសៀវភៅនេះ
- សារអេឡិចត្រូនិកដែលបញ្ជាក់ពីការឆ្លងកាត់ (ATR) និងការមកដល់ (AAR) នឹងត្រូវបានផ្ញើទៅកាន់ការិយាល័យគយនីមួយៗ ចេញពីការិយាល័យគយចេញដំណើរដោយស្វ័យប្រវត្តិ
- សារអេឡិចត្រូនិកដែលបញ្ជាក់ពីការឆ្លងកាត់ព្រំដែន (NCF) ត្រូវបានផ្ញើពីការិយាល័យឆ្លងកាត់ដោយស្វ័យប្រវត្តិទៅកាន់ការិយាល័យគយចេញដំណើរ។ បន្ទាប់ពីទទួលបានសារនេះហើយ ការិយាល័យគយចេញដំណើរនឹងផ្ញើព័ត៌មាននេះដល់គ្រប់ការិយាល័យដែលពាក់ព័ន្ធទាំងអស់
- សារបញ្ជាក់ថាបានមកដល់ (Arrival Advice) ត្រូវបានផ្ញើពីការិយាល័យគយគម្យដ្ឋានមកការិយាល័យគយចេញដំណើរនៅពេលទំនិញមកដល់
- ការិយាល័យគយគម្យដ្ឋាននឹងផ្ញើសារស្តីពីលទ្ធផលត្រួតពិនិត្យ (Control Result) មកកាន់ការិយាល័យគយចេញដំណើរនៅពេលទំនិញត្រូវបានត្រួតពិនិត្យរួច
- ប្រព័ន្ធនេះនឹងផ្តល់នូវនីតិវិធីសាមញ្ញ និងនីតិវិធីធម្មតា
- នីតិវិធីសម្រាប់អនុវត្តជំនួសប្រព័ន្ធ ACTS នៅពេលមានអាសន្នគឺពុំមានឡើយ។

## ២.៣. ទិដ្ឋភាពទូទៅនៃប្រព័ន្ធឆ្លងកាត់គយអាស៊ាន



# ឧបសម្ព័ន្ធនៃផ្នែកទី១

## ឧបសម្ព័ន្ធ ១ក÷ សាវតារនៃប្រព័ន្ធឆ្លងកាត់គយអាស៊ាន

ប្រព័ន្ធឆ្លងកាត់គយអាស៊ាន គឺជាប្រព័ន្ធស៊ីចង្វាក់សម្រាប់គ្រប់គ្រងទំនិញឆ្លងកាត់ប្រទេសសមាជិកអាស៊ាន។ ប្រព័ន្ធនេះសម្រាប់ប្រើជំនួសនីតិវិធីបច្ចុប្បន្នដែលមានទម្រង់ក្រដាស ដោយការប្រើប្រាស់នូវសារអេឡិចត្រូនិកសម្រាប់ធ្វើការវិភាគទិន្នន័យ និងព័ត៌មានដែលចាំបាច់សម្រាប់នីតិវិធីឆ្លងកាត់។ ប្រព័ន្ធនេះផ្តល់នូវការឆ្លងកាត់ប្រកបដោយប្រសិទ្ធភាពជាងមុន ដែលសម្រួលពាណិជ្ជកម្ម ព្រមគ្នាជាមួយការកាត់បន្ថយហានិភ័យនៃការប្រើប្រាស់ប្រព័ន្ធឆ្លងកាត់ដែលពុំសូវមានប្រសិទ្ធភាព ការបាត់បង់ទំនិញ និងការការពារការបាត់បង់ចំណូល។

នៅក្នុងពិធីសារទី៧ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីការសម្របសម្រួលទំនិញឆ្លងកាត់ (AFAFGIT) ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៨ នៅទីក្រុងហាណូយប្រទេសវៀតណាម រដ្ឋាភិបាលនៃប្រទេសសមាជិកនៃសមាគមន៍ប្រជាតិអាស៊ីអាគ្នេយ៍ (ASEAN) រួមមាន÷ ប្រទេសព្រុយណេដារូសាលឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាមានិតឡាវ ម៉ាឡេស៊ី សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃ និងសាធារណរដ្ឋសង្គមនិយមវៀតណាម បានឯកភាពគ្នាដើម្បីបង្កើតប្រព័ន្ធឆ្លងកាត់គយអាស៊ាន និងអនុវត្តតាមបញ្ញត្តិនៃពិធីសារនេះចំពោះទំនិញដែលឆ្លងកាត់នៅក្នុងប្រទេសរបស់ខ្លួន។

ពិធីសារទី៧ នៃ AFAFGIT និងឧបសម្ព័ន្ធបច្ចេកទេសរបស់ពិធីសារនេះបានបង្កើតជាបទប្បញ្ញត្តិច្បាប់និងបច្ចេកទេសសម្រាប់ប្រតិបត្តិការនៃប្រព័ន្ធ ACTS ជាប្រព័ន្ធគយដែលមានប្រសិទ្ធភាពនិងសក្តិសិទ្ធភាពខ្ពស់ ក្នុងចំណោមបណ្តារដ្ឋសមាជិកអាស៊ាន។

បទប្បញ្ញត្តិទាំងនេះស្របតាមស្តង់ដារអន្តរជាតិដូចដែលបានណែនាំនៅក្នុងអនុសញ្ញាក្រុងក្យូតូ (RKC) និងកិច្ចព្រមព្រៀងសម្របសម្រួលពាណិជ្ជកម្ម របស់អង្គការពាណិជ្ជកម្មពិភពលោក។ ជំពូកទី ១ ឧបសម្ព័ន្ធ ង នៃ RKC បានផ្តល់នូវបទដ្ឋានដែលបានណែនាំសម្រាប់ការសម្របសម្រួលទំនិញឆ្លងកាត់ ក្រោមការគ្រប់គ្រងរបស់គយ រួមទាំងនិមុត្តិធានា។ បទប្បញ្ញត្តិទាំងនេះ ក៏រាប់បញ្ចូលទាំងស្តង់ដារទាក់ទងនឹងអ្នកទទួលខុសត្រូវ អ្នកផ្ញើនិងអ្នកទទួលទំនិញ ការបំពេញបែបបទនៅការិយាល័យចេញដំណើរ ការកិបសៀលគយនិងការកំណត់ចិរវេលានៃការឆ្លងកាត់។

កិច្ចព្រមព្រៀងសម្របសម្រួលពាណិជ្ជកម្មរបស់អង្គការពាណិជ្ជកម្មពិភពលោក មានចែងអំពីការឆ្លងកាត់ដោយសេរី និងការពង្រឹងប្រតិបត្តិករគោលសម្រាប់ធ្វើប្រតិបត្តិការឆ្លងកាត់ដូចដែលបានបញ្ជាក់នៅក្នុងមាត្រាទី៥ នៃកិច្ចព្រមព្រាងទូទៅលើទំនិញនិងពាណិជ្ជកម្ម (GATT)។ មាត្រាទី ១១ មានរៀបរាប់អំពីមាត្រដ្ឋានឆ្លងកាត់ដែលតម្រូវឱ្យមានឯកសារតិចបំផុត នីតិវិធីសាមញ្ញបំផុត និងនិមុត្តិធានាទាបបំផុត។

អនុសញ្ញានៃកិច្ចព្រមព្រៀងសម្រួលពាណិជ្ជកម្ម (TFA) និង RKC លើកទឹកចិត្តឱ្យមានកិច្ចព្រមព្រៀងដែលសម្រួលដល់ការដឹកជញ្ជូនឆ្លងកាត់។ កិច្ចព្រមព្រៀងនេះនឹងនាំឱ្យមាននីតិវិធីឆ្លងកាត់គយស៊ីចង្វាក់គ្នាមួយ និងមានការផ្លាស់ប្តូរទិន្នន័យគ្នាតាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ អនុសញ្ញា RKC ណែនាំថា គ្រប់ភាគីពាក់ព័ន្ធគួរឯកភាពគ្នាដើម្បីបង្កើតជាកិច្ចព្រមព្រៀងអន្តរជាតិមួយស្តីពីការឆ្លងកាត់។

## ឧបសម្ព័ន្ធ ១៦៖ សន្ទានុក្រម

វាក្យសព្ទដែលប្រើប្រាស់នៅក្នុងសៀវភៅនេះ មានអត្ថន័យដូចគ្នាទៅនឹងអត្ថន័យដែលបានពន្យល់នៅក្នុងមាត្រាទី១ នៃពិធីសារទី៧ នៃ AFAFGIT ។

- ប្រព័ន្ធឆ្លងកាត់គយអាស៊ាន (ACTS)៖ ជាប្រព័ន្ធឆ្លងកាត់មួយដែលត្រូវអភិវឌ្ឍឡើងសម្រាប់សម្រួលនីតិវិធីឆ្លងកាត់ក្នុងតំបន់អាស៊ាន ដូចមានចែងនៅក្នុងពិធីសារទី៧
- នីតិវិធី ACTS ៖ បញ្ញត្តិនានាសម្រាប់គ្រប់គ្រងការអនុវត្តប្រព័ន្ធ ACTS ដូចមានចែងក្នុងពិធីសារទី៧ និងឧបសម្ព័ន្ធនៃពិធីសារនេះ
- អាជ្ញាធរមានសមត្ថកិច្ច៖ មន្ត្រីគយឬអាជ្ញាធរផ្សេងទៀតដែលមានភារកិច្ចអនុវត្តតាមពិធីសារនេះ
- គយ៖ មន្ត្រីគយដែលពាក់ព័ន្ធ
- បំណុលគយ៖ ប្រាក់ពន្ធ អាករ និងកម្រៃនានាសម្រាប់ធានាដល់ការដឹកជញ្ជូនឆ្លងកាត់ក្រោមរបបឆ្លងកាត់គយអាស៊ាន
- ការិយាល័យចេញដំណើរ៖ ការិយាល័យគយនានាដែលទំនិញចាប់ផ្តើមចេញដំណើរ
- ការិយាល័យគម្រដ្ឋាន៖ ការិយាល័យគយនានាដែលប្រតិបត្តិការឆ្លងកាត់បានបញ្ចប់
- ការិយាល័យឆ្លងកាត់៖ ការិយាល័យគយនៅមាត់ច្រកព្រំដែនក្នុងបរិបទឆ្លងកាត់
- ការិយាល័យដាក់ឯកសារ៖ ការិយាល័យដែលម្ចាស់ទំនិញធ្វើការដាក់ឯកសារប្រតិវេទន៍ ACTS
- បច្ចេកទេសវិភាគទិន្នន័យ៖ ទម្រង់ព័ត៌មានដែលចាំបាច់សម្រាប់បំពេញក្នុងប្រតិវេទន៍សម្រាប់ឱ្យប្រព័ន្ធធ្វើការវិភាគ និងបញ្ជូនទិន្នន័យទៅកាន់អាជ្ញាធរនានា
- អ្នកធានា៖ ភាគីទី៣ ដែលទទួលបានការអនុញ្ញាតក្នុងការអះអាងថានិងមានលទ្ធភាពបង់បំណុលគយនានាក្នុងករណីដែលម្ចាស់ទំនិញមិនអាចបង់បាន
- ការិយាល័យគ្រប់គ្រងនិមុត្តិធានា៖ ការិយាល័យគយដែលត្រូវបានចាត់តាំងសម្រាប់គ្រប់គ្រងនូវអ្នកធានា និងនិមុត្តិធានាសម្រាប់គ្របដណ្តប់លើប្រតិបត្តិការឆ្លងកាត់
- ម្ចាស់ទំនិញ៖ បុគ្គលដែលធ្វើការដឹកជញ្ជូនទំនិញក្រោមរបបឆ្លងកាត់គយអាស៊ាន ទោះបីជាប្រតិបត្តិការនេះត្រូវបានធ្វើដោយអ្នកតំណាងក៏ដោយ
- ប្រតិបត្តិការដឹកជញ្ជូនឆ្លងកាត់៖ ការដឹកជញ្ជូនទំនិញពីការិយាល័យគយចេញដំណើរ ទៅការិយាល័យគយគម្រដ្ឋានក្រោមរបបឆ្លងកាត់គយអាស៊ាន

## ផ្នែកទី២÷ ប្រព័ន្ធ ACTS សម្រាប់ធុរជន

### ១. ការប្រើប្រាស់ប្រព័ន្ធ ACTS ក្នុងនាមជាប្រតិបត្តិករដឹកជញ្ជូន (ឬម្ចាស់ទំនិញ)

បុគ្គល (ឬអ្នកតំណាង) ដែលដឹកទំនិញឆ្លងកាត់ក្រោមរបបឆ្លងកាត់គយអាស៊ានត្រូវបានហៅថា "ម្ចាស់ទំនិញ"។ ម្ចាស់ទំនិញត្រូវរៀបចំដាក់ប្រតិវេទន៍ និងឆ្លើយតបទៅកាន់មន្ត្រីគយវិញក្នុងករណីចាំបាច់។ ភាគីដែលពាក់ព័ន្ធក្នុងប្រតិបត្តិការឆ្លងកាត់ រួមមាន÷

- ម្ចាស់ទំនិញ÷ ភាគីដែលដឹកជញ្ជូនទំនិញក្រោមរបបឆ្លងកាត់គយអាស៊ាន ទោះបីជាប្រតិបត្តិការនេះត្រូវបានធ្វើឡើងដោយអ្នកតំណាង
- អ្នកផ្ញើទំនិញ÷ ភាគីដែលផ្ញើទំនិញដែលបានប្រកាស
- អ្នកទទួលទំនិញ÷ ភាគីដែលទទួលទំនិញដែលបានប្រកាស
- អ្នកតំណាង÷ រូបវន្តបុគ្គល ឬនីតិបុគ្គលដែលតំណាងឱ្យម្ចាស់ទំនិញសម្រាប់ប្រកាសប្រតិវេទន៍ឆ្លងកាត់
- ប្រតិវេទករ÷ បុគ្គលិករបស់ក្រុមហ៊ុនអ្នកតំណាងដែលទទួលបានការផ្ទេរសិទ្ធសម្រាប់ធ្វើការប្រកាសប្រតិវេទន៍ឆ្លងកាត់

#### ១.១. តម្រូវការមូលដ្ឋានសម្រាប់ប្រើប្រាស់ប្រព័ន្ធ ACTS

- មានម៉ាស៊ីនកុំព្យូទ័រតភ្ជាប់ទៅកាន់ Internet
- ចុះឈ្មោះប្រើប្រាស់ប្រព័ន្ធ ACTS
- ចូលរួមវគ្គបណ្ដុះបណ្ដាលប្រព័ន្ធ ACTS នានា
- មានចំណេះដឹងនូវព័ត៌មានដែលចាំបាច់សម្រាប់ធ្វើប្រតិវេទន៍ ACTS

#### ១.២. ការរៀបចំសម្រាប់ដំណើរការឆ្លងកាត់

ប្រតិវេទន៍ឆ្លងកាត់គយអាស៊ានត្រូវរៀបចំ និងប្រកាសដោយម្ចាស់ទំនិញតាមរយៈ÷

- បុគ្គលិកដែលទទួលបានការផ្ទេរសិទ្ធ (ប្រតិវេទករ)
- ក្រុមហ៊ុនតំណាងដែលទទួលបានការផ្ទេរសិទ្ធពីម្ចាស់ទំនិញ

ម្ចាស់ទំនិញត្រូវតម្កល់និមុត្តិធានានៅស្ថាប័នហិរញ្ញវត្ថុដែលទទួលបានការអនុញ្ញាតពីគយ ហើយត្រូវបង្ហាញលិខិតនោះជូនមន្ត្រីគយទទួលបន្ទុកគ្រប់គ្រងនិមុត្តិធានាដើម្បីរក្សាទុក និងចុះបញ្ជីក្នុងប្រព័ន្ធ។ មន្ត្រីគយនឹងប្រាប់នូវលេខ GRN សម្រាប់ឱ្យម្ចាស់ទំនិញយកលេខនោះទៅចុះប្រតិវេទន៍។

##### ១.២.១. ការកម្រិតកំណត់លើការផ្ទុកទំនិញ

ទំនិញដែលប្រកាសក្នុងមួយប្រតិវេទន៍នៃប្រព័ន្ធ ACTS ត្រូវតែជាទំនិញដែលផ្ទុកក្នុងមធ្យោបាយដឹកជញ្ជូនតែមួយដូចជា÷

- មធ្យោបាយដឹកជញ្ជូនផ្លូវគោកដែលមានកន្ទុយសណ្ដោង ឬកុងតឺន័រ និង
- មធ្យោបាយដឹកជញ្ជូនដូចដែលបានរៀបរាប់ខាងលើចេញដំណើរពីការិយាល័យចេញដំណើរដល់ការិយាល័យគម្យដ្ឋាន

បើក្នុងប្រតិបត្តិការតែមួយហើយមានមធ្យោបាយដឹកជញ្ជូនលើសពីមួយ ម្ចាស់ទំនិញត្រូវធ្វើការប្រកាសប្រតិវេទន៍បន្ថែមទៀតទោះបីជាទំនិញដូចគ្នា ឬតម្រាយផ្លូវដូចគ្នាក៏ដោយ។

## ២. ការប្រកាសប្រតិវេទន៍ឆ្លងកាត់

### ២.១. ការដាក់ប្រតិវេទន៍និងការផ្ទៀងផ្ទាត់

ប្រតិវេទន៍ឆ្លងកាត់គយអាស៊ានត្រូវប្រកាសជាទម្រង់អេឡិចត្រូនិកនៅការិយាល័យចេញដំណើរ។ នៅពេលចុះលេខ ប្រតិវេទករត្រូវបញ្ចូលលេខចុះបញ្ជីធុរជន (TRN) ដែលទទួលបាននៅពេលចុះបញ្ជីក្នុងប្រព័ន្ធ ACTS និងលេខយោងនិមុត្តិធានា (GRN) ចូលទៅក្នុងប្រព័ន្ធ។

#### ២.១.១. លទ្ធផលនៃការផ្ទៀងផ្ទាត់

ប្រតិវេទន៍ ACTS អាចចុះបញ្ជីបានដរាបណាប្រតិវេទករបំពេញព័ត៌មានបានត្រឹមត្រូវនិងគ្រប់គ្រាន់ ហើយប្រព័ន្ធធ្វើការផ្ទៀងផ្ទាត់ដោយជោគជ័យ។ ករណីមានកំហុសនានា ប្រព័ន្ធនឹងបដិសេធការចុះបញ្ជីហើយនឹងផ្ញើសារត្រឡប់មកកាន់ប្រតិវេទករវិញ (នៅទំព័រដើម) សម្រាប់ប្រតិវេទករធ្វើការពិនិត្យមើលនិងកែតម្រូវ។ នៅពេលដែលការចុះបញ្ជីទទួលបានជោគជ័យ ប្រព័ន្ធនឹងផ្តល់នូវលេខយោងប្រតិវេទន៍ (ARN) និងផ្ញើសារទៅកាន់ប្រតិវេទករ។

### ២.២. វិធាននីតិវិធីប្រព័ន្ធ ACTS

ប្រសិនបើប្រតិវេទន៍មួយត្រូវបានបដិសេធ មានន័យថាប្រព័ន្ធប្រាកដជាមានមូលហេតុរបស់វា។ ទោះបីជាយ៉ាងនេះក្តី ទំនិញនៅតែអាចធ្វើប្រតិបត្តិការឆ្លងកាត់បានដោយប្រើប្រាស់របបផ្សេងទៀតក្រៅពីប្រព័ន្ធ ACTS។ ក្រៅពីនោះ ប្រតិវេទករអាចកែតម្រូវប្រតិវេទន៍រួចដាក់ស្នើម្តងទៀត។

*ចំណាំ៖ ប្រតិវេទករអាចធ្វើការកែប្រតិវេទន៍របស់ខ្លួនបានមុនពេលមន្ត្រីគយធ្វើការត្រួតពិនិត្យ។*

នៅពេលដែលប្រតិវេទន៍ត្រូវបានទទួលយកដោយប្រព័ន្ធ សូមរង់ចាំដំណឹងពីមន្ត្រីដែលនៅការិយាល័យចេញដំណើរ៖

- ប្រសិនបើមន្ត្រីសម្រេចថាត្រូវត្រួតពិនិត្យ ម្ចាស់ទំនិញ ឬតំណាងត្រូវបង្ហាញទំនិញ និងឯកសារអមភ្ជាប់
- ករណីរកមិនឃើញភាពមិនប្រក្រតីនានា ឬមន្ត្រីសម្រេចថាមិនត្រួតពិនិត្យ៖
  - ប្រព័ន្ធ ACTS និងពិនិត្យមើលសុពលភាពនិមុត្តិធានា និងបរិមាណដែលត្រូវប្រើប្រាស់
  - សៀលគយត្រូវបានកិបលើមធ្យោបាយដឹកជញ្ជូន ឬកុងតឺន័រ
  - ប្រតិវេទន៍ត្រូវបានបោះពុម្ពជាទម្រង់ក្រដាស (TAD)
  - មន្ត្រីគយបញ្ចេញទំនិញសម្រាប់ឆ្លងកាត់
  - ករណីមានកំហុសនៅលើព័ត៌មាននិមុត្តិធានា ប្រព័ន្ធនឹងជូនដំណឹងដល់ម្ចាស់ទំនិញដើម្បីធ្វើការកែតម្រូវ
- ករណីមន្ត្រីគយរកឃើញនូវកំហុសឆ្គងតូច (ដែលអាចកែតម្រូវបាន) ប្រតិវេទករត្រូវកែតម្រូវប្រតិវេទន៍

- ករណីមន្ត្រីគយរកឃើញកំហុសធ្ងន់ធ្ងរ (ដែលមិនអាចកែតម្រូវបាន) ប្រតិវេទន៍នេះត្រូវលុបចោល ហើយម្ចាស់ទំនិញ/អ្នកតំណាងអាចរងនូវទោសទណ្ឌតាមបទប្បញ្ញត្តិជាធរមាន។ បើម្ចាស់ទំនិញចង់បន្តប្រតិបត្តិការនោះ ប្រតិវេទករអាចធ្វើការប្រកាសប្រតិវេទន៍ថ្មីបាន
- ប្រតិវេទន៍ ACTS អាចត្រូវបានលុបចោលតាមការសម្រេចចិត្តរបស់គយ ឬតាមការស្នើសុំរបស់ម្ចាស់ទំនិញ/អ្នកតំណាងក្នុងហេតុផលសមស្រប។

### ២.២.១. តម្រាយផ្លូវ និងថិរវេលា

មន្ត្រីគយនៅការិយាល័យចេញដំណើរមានសិទ្ធិកំណត់ពេលវេលាត្រូវទៅដល់ការិយាល័យគម្រដ្ឋាន និងពេលវេលាត្រួតពិនិត្យ។ ក្នុងករណីមានការពន្យានានា ដោយមានហេតុផលសមស្រប មន្ត្រីគយអាចធ្វើការសាកសួរដំណឹង។

## ៣. ដំណើរការឆ្លងកាត់

អ្នកបើកបរដឹកទំនិញចេញដោយមានការណែនាំពីម្ចាស់ទំនិញនិងមន្ត្រីគយ ដោយអមនូវប្រតិវេទន៍ (TAD) សម្រាប់បង្ហាញជូនមន្ត្រីគយនៅការិយាល័យឆ្លងកាត់ (ព្រំដែន) និងការិយាល័យគម្រដ្ឋាន។ ក្នុងករណីមានឧប្បត្តិហេតុនានាកើតឡើង អ្នកបើកបរត្រូវរាយការណ៍ជូនស្ថាប័នមានសមត្ថកិច្ចជាបន្ទាន់។

នៅពេលដែលទំនិញមកដល់ដោយមិនមានភាពមិនប្រក្រតីនានា ទំនិញត្រូវបានបញ្ចេញនៅការិយាល័យគយគម្រដ្ឋាន ហើយបរិមាណប្រាក់កក់ត្រូវបានបញ្ចេញទៅក្នុងនិមុត្តិធានាដើមវិញ។ នៅពេលដែលទំនិញមិនទៅដល់ការិយាល័យគម្រដ្ឋានតាមការកំណត់ ម្ចាស់ទំនិញត្រូវបកស្រាយប្រាប់មន្ត្រីគយអំពីមូលហេតុសមស្រប។

### ៣.១. ការបង្វែរតម្រាយផ្លូវ

ក្នុងករណីដែលមានការបង្វែរតម្រាយផ្លូវទៅកាន់ការិយាល័យគយគម្រដ្ឋានមួយទៀត ក្រៅពីការិយាល័យគយគម្រដ្ឋានដែលបានប្រកាស ម្ចាស់ទំនិញ ឬអ្នកទទួលទំនិញត្រូវជូនដំណឹងទៅកាន់ការិយាល័យគម្រដ្ឋាននោះ។ ការជូនដំណឹងនោះទៀតសោតក៏ត្រូវតែជូនដល់ការិយាល័យឆ្លងកាត់ផងដែរ (បើមាន)។

ប្រព័ន្ធ ACTS នឹងផ្ទៀងផ្ទាត់នូវសុពលភាពនានាដូចជា÷ ថិរវេលាដែលនៅសល់ ការិយាល័យឆ្លងកាត់ ការិយាល័យគម្រដ្ឋាន តម្រាយផ្លូវ បរិមាណនិមុត្តិធានា ឬការកម្រិតកំណត់នៅក្នុងប្រទេសណាមួយ។

### ៣.២. ឧប្បត្តិហេតុផ្សេងទៀត

ក្នុងករណីមានឧប្បត្តិហេតុណាមួយដូចខាងក្រោម ក្រុមហ៊ុនដឹកជញ្ជូនត្រូវរាយការណ៍ជាបន្ទាន់ជូនអាជ្ញាធរមានសមត្ថកិច្ច និងកត់ត្រាទុកនៅក្នុង TAD ឬមានភស្តុតាងនានាដូចជា÷ របាយការណ៍របស់អាជ្ញាធរពាក់ព័ន្ធ ឬប្រើប្រាស់នូវកំណត់ហេតុដូចមានក្នុងឧបសម្ព័ន្ធទី៥ ហើយបង្ហាញភស្តុតាងទាំងនោះសម្រាប់ផ្ទៀងផ្ទាត់ជាមួយមន្ត្រីមានសមត្ថកិច្ចនៃដែនដីប្រទេសដឹកជញ្ជូនឆ្លងកាត់។

- ប្រសិនបើតម្រាយផ្លូវត្រូវបានផ្លាស់ប្តូរ
- ប្រសិនបើសៀលត្រូវបានខូចខាតក្នុងពេលប្រតិបត្តិការក្រៅពីការត្រួតពិនិត្យរបស់គយ

- ប្រសិនបើទំនិញត្រូវបានផ្ទេរទៅកាន់មធ្យោបាយដឹកជញ្ជូនផ្សេងទៀតក្រៅពីការតម្រូវរបស់គយ
- ក្នុងករណីមានគ្រោះថ្នាក់ដែលតម្រូវឱ្យមានការលើកដាក់ទំនិញជាបន្ទាន់នូវផ្នែកខ្លះឬទាំងស្រុង
- ក្នុងករណីគ្រោះថ្នាក់ ឬឧប្បត្តិហេតុនានាផ្សេងទៀតដែលអាចធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពរបស់ម្ចាស់ទំនិញ ឬក្រុមហ៊ុនដឹកជញ្ជូនក្នុងការអនុវត្តតាមកាតព្វកិច្ច។

នៅពេលយល់ថា ប្រតិបត្តិការឆ្លងកាត់អាចបន្តដំណើរបានធម្មតា មន្ត្រីគយមានសមត្ថកិច្ចត្រូវធ្វើការចារនៅលើ TAD និងធ្វើការបញ្ជាក់នៅក្នុងប្រព័ន្ធ ACTS។

### ៣.៣. ការបញ្ឈប់ ឬការបញ្ចប់ប្រតិបត្តិការឆ្លងកាត់

ភាពមិនប្រក្រតីនានា ដែលរកឃើញដោយគយនៅការិយាល័យគម្យដ្ឋាន នឹងត្រូវតាមដានដោយការិយាល័យចេញដំណើរជាមួយនឹងម្ចាស់ទំនិញបើចាំបាច់។ ការប្រើប្រាស់ប្រព័ន្ធ ACTS ម្ចាស់ទំនិញជាអ្នកទទួលខុសត្រូវមុនគេលើការសងបំណុលគយ ក្នុងករណីរកឃើញនូវភាពមិនប្រក្រតីនានា។

## ៤. នីតិវិធីអនុវត្តពេលប្រព័ន្ធមិនដំណើរការ

នីតិវិធីនេះអនុវត្ត÷

- នៅពេលប្រព័ន្ធអេឡិចត្រូនិកសម្រាប់មន្ត្រីមានសមត្ថកិច្ចមិនដំណើរការ
- នៅពេលប្រព័ន្ធអេឡិចត្រូនិកសម្រាប់ធុរជនមិនដំណើរការ ឬ
- នៅពេលប្រព័ន្ធបណ្តាញរវាងប្រព័ន្ធសម្រាប់ធុរជននិងមន្ត្រីមិនដំណើរការ

ក្នុងករណីនេះ ម្ចាស់ទំនិញគួរប្រឹក្សាយោបល់ជាមួយមន្ត្រីគយនៃប្រទេសរបស់ខ្លួន។ ក្រុមការងារបច្ចេកទេសប្រចាំតំបន់នឹងផ្តល់ដំណឹងអំពីរយៈពេលដែលប្រព័ន្ធអាចដំណើរការឡើងវិញ។

# ឧបសម្ព័ន្ធនៃផ្នែកទី២

## ឧបសម្ព័ន្ធ ២ក៖ ទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់

ប្រតិវេទន៍ ACTS មាននូវទំនិញជាប់កម្រិតកំណត់ដែលអនុញ្ញាតឱ្យឆ្លងកាត់ធម្មតា។ សូមមើលនៅផ្នែកទី៥ សម្រាប់ការណែនាំស្តីពីការដោះស្រាយជាមួយទំនិញជាប់កម្រិតកំណត់។ ទំនិញហាមឃាត់នៅក្នុងប្រទេសណាមួយដែលបម្រុងឆ្លងកាត់នឹងត្រូវបានបដិសេធដោយប្រព័ន្ធ ACTS ពោលគឺមិនអនុញ្ញាតឱ្យឆ្លងកាត់ឡើយ។

ប្រព័ន្ធគ្រប់គ្រងទិន្នន័យយោង (RDS) នៃមជ្ឈមណ្ឌលកណ្តាលនឹងគ្រប់គ្រងទៅលើបញ្ជីទំនិញហាមឃាត់ ទំនិញជាប់កម្រិតកំណត់ ទៅតាមតារាងពន្ធរបស់ប្រទេសសមាជិកអាស៊ាន។ បញ្ជីទំនិញនេះនឹងត្រូវបានកែប្រែដោយក្រុមការងារគ្រប់គ្រងមជ្ឈឹម (CMT) នៅពេលមានការស្នើសុំពីប្រទេសណាមួយ។

ទំនិញមួយចំនួនត្រូវបានដកចេញពីការឆ្លងកាត់ ដោយសារតែទំនិញទាំងនោះមានអត្រាពន្ធគិតតាមឯកតា ហើយដែលមិនអាចដំណើរការដោយប្រព័ន្ធ ACTS បាន។

## ឧបសម្ព័ន្ធ ២ខ៖ ការចុះឈ្មោះក្រុមហ៊ុននិងអ្នកប្រើប្រាស់

### ១. ការចុះឈ្មោះក្រុមហ៊ុន

មុនពេលធ្វើប្រតិបត្តិការក្នុងប្រព័ន្ធ ACTS បាន ធុរជនត្រូវចុះឈ្មោះជាមុនសិន។ ទម្រង់បែបបទនៃការចុះឈ្មោះមាននៅក្នុងឧបសម្ព័ន្ធនេះ។

### ២. ទំនាក់ទំនងរវាងក្រុមហ៊ុន និងប្រតិវេទករ




### ៣. ការចូលប្រើប្រាស់ប្រព័ន្ធតាមរយៈ ACTS TRADER PORTAL

បន្ទាប់ពីចុះឈ្មោះនៅក្នុងប្រព័ន្ធ ACTS បុគ្គលដែលនឹងរៀបចំប្រតិវេទន៍ឆ្លងកាត់ជំនួសឱ្យម្ចាស់ទំនិញឆ្លងកាត់តាមប្រព័ន្ធ ACTS អាចដាក់ប្រតិវេទន៍តាមមធ្យោបាយអេឡិចត្រូនិកដោយខ្លួនឯង ដោយប្រើប្រាស់គណនីអ្នកប្រើប្រាស់ប្រព័ន្ធ ACTS ។ ពាក្យសុំគណនីអ្នកប្រើប្រាស់ត្រូវបានត្រួតពិនិត្យដោយមន្ត្រីទទួលបន្ទុកប្រព័ន្ធ ACTS ដើម្បីបញ្ជាក់ព័ត៌មានលម្អិតធៀបនឹងព័ត៌មានដែលបានចុះបញ្ជីលើកមុន តាមរយៈដំណើរការពាក្យសុំចុះបញ្ជីធុរជនដូចខាងលើ។ បន្ទាប់ពីមន្ត្រីឯកភាព ប្រព័ន្ធនឹងផ្ញើសារទៅកាន់អ្នកប្រើប្រាស់ ហើយអ្នកប្រើប្រាស់នឹងត្រូវដាក់ពាក្យ

សម្ងាត់ដោយខ្លួនឯង។ នៅពេលចូលទៅកាន់ប្រព័ន្ធ ACTS ឈ្មោះអ្នកប្រើប្រាស់និងពាក្យសម្ងាត់របស់បុគ្គលម្នាក់គឺជាហត្ថលេខារបស់បុគ្គលនោះ។ រាល់សកម្មភាពប្រើប្រាស់ប្រព័ន្ធ ត្រូវបានកត់ត្រាទុកនិងជាការទទួលខុសត្រូវរបស់បុគ្គលនោះ។ ** ពាក្យសម្ងាត់មិនត្រូវចែករំលែកឡើយ **។

## ៤. ពាក្យស្នើសុំចុះបញ្ជីធុរជនតាមប្រព័ន្ធ ACTS

| TRADER APPLICATION | | |
|---|---|---|
| **APPLICANT INFORMATION** | | |
| Name: | | |
| **ORGANIZATION INFORMATION** | | |
| Parent: | | |
| Organization name: | | |
| Branch: | | |
| Organization name: | | |
| Addresses | | |
| Primary | | |
| Street & Number: | | Postal Code: |
| City: | Country: | |
| Secondary | | |
| Street & Number: | | Postal Code: |
| City: | Country: | |
| **CONTACT DETAILS** | | |
| Contact Person: | | |
| Phone: | Fax: | E-mail: |
| Web Address: | | |
| **IDENTIFIERS** | | |
| GST / VAT number☐ | Previous TIN☐ | |
| GST/ VAT number☐ | Previous TIN☐ | |
| GST/ VAT number☐ | Previous TIN☐ | |
| GST/ VAT number☐ | Previous TIN☐ | |
| Passport Number ☐ | Previous TIN☐ | |
| Passport Number ☐ | Previous TIN☐ | |
| Passport Number ☐ | Previous TIN☐ | |
| Passport Number ☐ | Previous TIN☐ | |
| Signatures | | |
| I authorize the verification of the information provided on this form as to my credit. I have received a copy of this application. | | |
| Signature of applicant: | | Date: |

## ៥. លិខិតផ្ទេរសិទ្ធរវាងម្ចាស់ទំនិញនិងជើងសាក្នុងប្រព័ន្ធ ACTS

**Headed notepaper in the name of the Principal**

*Authorisation letter template from Principal to the Customs Authority authorising Broker to Act as a Representative for the submission of ACTS declarations on behalf of Principal*

To: Customs Authority

(Name and address of HQ Department responsible)

Date: dd/mm/yyyy

Dear Sir / Madam,

This is to confirm that (name & address of Principal, VAT/GST number)

Name: .............................................................................

Address: ..........................................................................

.......................................................................................

.......................................................................................

has authorised (name and address of Broker, VAT / GST number)

Name: .............................................................................

Address: ..........................................................................

.......................................................................................

.......................................................................................

to act as our representative for the submission of Customs Transit declarations to the ASEAN Customs Transit System (ACTS).

Yours faithfully,

(Signature)

(Full name and position of signatory)

## ៦. ពាក្យសុំសម្រាប់បុគ្គលិកក្រុមហ៊ុនដែលទទួលបានការផ្ទេរសិទ្ធដើម្បីប្រកាសប្រតិវេទន៍ ACTS

| EMPLOYEE/DECLARANT DETAILS AND AUTHORIZATION | | |
|---|---|---|
| **EMPLOYEE INFORMATION** | | |
| First Name: | Last Name: | |
| Personal ID: | Male ☐ Female ☐ | |
| Father Name: | | |
| Addresses | | |
| Primary | | |
| Street & Number: | | Postal Code: |
| City: | Country: | |
| Secondary | | |
| Street & Number: | | Postal Code: |
| City: | Country: | |
| **CONTACT DETAILS** | | |
| Contact Person: | | |
| Phone: | Fax: | E-mail: |
| Web Address: | | |
| **IDENTIFIERS** | | |
| Employer Name:<br>Employer Address:<br>Employee Passport Number: | | |
| Signature of the Employee | | |
| I authorize the verification of the information provided on this form as to my credit. I have received a copy of this application. | | |
| Signature: signed | | Date: |
| Signature of the Employer | | |
| I authorize the above-mentioned employee to submit ACTS declarations on my behalf. | | |
| Signature: | | Date: |

# ផ្នែកទី៣÷ ប្រតិបត្តិករឆ្លងកាត់ទទួលបានការអនុញ្ញាត និងនីតិវិធីសាមញ្ញ

## ១. គោលបំណងនៃនីតិវិធីសាមញ្ញ

១.១. គោលបំណងនៃនីតិវិធីឆ្លងកាត់សាមញ្ញ គឺដើម្បីរកតុល្យភាពរវាងការគ្រប់គ្រងរបស់គយ និងការសម្រួលពាណិជ្ជកម្មក្នុងកម្រិតសមស្របសម្រាប់ធុរជនធ្លាប់មានអនុលោមភាពខ្ពស់ និងភាពដែលអាចទុកចិត្តបានក្នុងប្រតិបត្តិការឆ្លងកាត់។

១.២. ធុរជនដែលប្រើប្រាស់ប្រព័ន្ធឆ្លងកាត់ជាប្រចាំ និងមានប្រវត្តិអនុលោមភាពល្អ អនុញ្ញាតឱ្យអាជ្ញាធរគយបន្ធូរបន្ថយការត្រួតពិនិត្យធម្មតា មានន័យថា ធុរជនមានហានិភ័យកម្រិតទាបចំពោះទំនួលខុសត្រូវនៃការត្រួតពិនិត្យរបស់គយ។

១.៣. រដ្ឋបាលគយជាអ្នកកំណត់លក្ខខណ្ឌជាមុន សម្រាប់ប្រតិបត្តិករឆ្លងកាត់ទទួលបានការអនុញ្ញាត (ATT) ។ លក្ខខណ្ឌនេះផ្តល់នូវការអនុគ្រោះ រួមមាន÷

- ការកាត់បន្ថយបរិមាណនិមុត្តិធានាសម្រាប់ប្រតិបត្តិការច្រើនលើក
- ការបញ្ចេញទំនិញក្រៅការិយាល័យគយ នៅក្នុងទីតាំងដែលទទួលបានការអនុញ្ញាត (ឧទាហរណ៍÷ ឃ្លាំងទំនិញរបស់ធុរជន) និង
- ការកិបសៀលដោយខ្លួនឯង ដែលទទួលបានការអនុញ្ញាតពីគយ លើរថយន្តដឹកទំនិញ និងកុងតឺន័រក្នុងពេលឆ្លងកាត់។

*ចំណាំ÷ ទន្ទឹមនឹងការទទួលបាននីតិវិធីសាមញ្ញ ប្រតិបត្តិករក៏ត្រូវបន្ថែមការទទួលខុសត្រូវផងដែរ។*

## ២. មូលដ្ឋានសម្រាប់ទទួលបានសិទ្ធិជាប្រតិបត្តិករឆ្លងកាត់ទទួលបានការអនុញ្ញាត

២.១. ដើម្បីទទួលបានសិទ្ធិជាប្រតិបត្តិករឆ្លងកាត់ទទួលបានការអនុញ្ញាត និងការប្រើប្រាស់នីតិវិធីសាមញ្ញត្រូវបំពេញតាមលក្ខខណ្ឌទូទៅដូចខាងក្រោម។

២.២. អ្នកដាក់ពាក្យសុំ÷

ក) ត្រូវធ្វើឡើងជាមួយការិយាល័យដែលបានចុះបញ្ជី ទីស្នាក់ការកណ្តាល ឬគ្រឹះស្ថានធុរកិច្ចអចិន្ត្រៃយ៍ក្នុងដែនដីរបស់កម្ពុជា និង

ខ) ត្រូវប្រើនីតិវិធី ACTS ជាប្រចាំ ឬបង្ហាញចេតនាអនុវត្តនីតិវិធីនេះ។

២.៣. ដើម្បីធានាការគ្រប់គ្រងឱ្យបានត្រឹមត្រូវនៃនីតិវិធីសាមញ្ញ ការអនុញ្ញាតអាចផ្តល់ជូនចំពោះតែបុគ្គលណាដែលរក្សាកំណត់ត្រាដែលអាចឱ្យអាជ្ញាធរមានសមត្ថកិច្ចត្រួតពិនិត្យនីតិវិធី និងអនុវត្តការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពតែប៉ុណ្ណោះ។

២.៤. ក្នុងការពិចារណាលើពាក្យសុំ អាជ្ញាធរមានសមត្ថកិច្ចត្រូវពិចារណាលើការផ្តន្ទាទោសណាមួយក្រោមច្បាប់គយ និងច្បាប់ពន្ធដារក្នុងរយៈពេល ៥ឆ្នាំ កន្លងមក។

## ៣. ពាក្យសុំសម្រាប់ប្រតិបត្តិករឆ្លងកាត់ទទួលបានការអនុញ្ញាត (ATT)

៣.១. ពាក្យសុំសម្រាប់ប្រតិបត្តិករឆ្លងកាត់ទទួលបានការអនុញ្ញាតត្រូវធ្វើជាមួយមន្ត្រីគយ ដែលជាអាជ្ញាធរមានសមត្ថកិច្ច ដោយប្រើប្រាស់ទម្រង់ និងពិចារណាលើឯកសារពន្យល់សម្រាប់អ្នកដាក់ពាក្យសុំ ដូចមានក្នុងឧបសម្ព័ន្ធនៃផ្នែកនេះរបស់សៀវភៅនេះ។

៣.២. បុគ្គលដាក់ពាក្យសុំសម្រាប់ប្រតិបត្តិករឆ្លងកាត់ទទួលបានការអនុញ្ញាត និងនីតិវិធីសាមញ្ញពាក់ព័ន្ធត្រូវទទួលខុសត្រូវលើ÷

ក) ភាពត្រឹមត្រូវនៃព័ត៌មានដែលបានផ្តល់ឱ្យ និង

ខ) ភាពត្រឹមត្រូវតាមច្បាប់នៃឯកសារភ្ជាប់មកជាមួយ។

៣.៣. ការអនុញ្ញាតទាំងឡាយណាដែលរកឃើញថា បានផ្តល់ឱ្យព័ត៌មានមិនពិត ឬព័ត៌មានមិនត្រឹមត្រូវ ត្រូវដកហូតការអនុញ្ញាតនេះជាបន្ទាន់។

៣.៤. វិសាលភាពរបស់ប្រតិបត្តិករឆ្លងកាត់ទទួលបានការអនុញ្ញាត (ATT) ÷

៣.៤.១. សូមចំណាំថា ប្រតិបត្តិករឆ្លងកាត់ទទួលបានការអនុញ្ញាត និងការអនុញ្ញាតនៃនីតិវិធីសាមញ្ញជាក់លាក់ណាមួយ មានដែនកំណត់ចំពោះដែនសមត្ថកិច្ចរបស់អាជ្ញាធរ ដែលចេញការអនុញ្ញាតនេះ។

៣.៤.២. ឧទាហរណ៍÷ ប្រសិនបើធុរជន ឬក្រុមហ៊ុនដឹកជញ្ជូនមានក្រុមហ៊ុនទាំងក្នុងប្រទេសចេញដំណើរ (ប្រទេស ក) និងប្រទេសគម្យដ្ឋាន (ប្រទេស គ) ប្រតិបត្តិករឆ្លងកាត់ទទួលបានការអនុញ្ញាត និងការអនុញ្ញាតត្រូវបានផ្តល់ជូនអត្ថប្រយោជន៍ជាច្រើនទាំងក្នុងប្រទេសចេញដំណើរ និងប្រទេសគម្យដ្ឋាន។

៣.៤.៣. ដើម្បីទទួលបានអត្ថប្រយោជន៍នេះ÷

ក) អ្នកដាក់ពាក្យសុំត្រូវមានធុរកិច្ចអចិន្ត្រៃយ៍ក្នុងប្រទេសទាំងពីរ ដូចបានពន្យល់ក្នុងកថាខ័ណ្ឌ ២.២. ខាងលើ និង

ខ) ពាក្យសុំដាច់ដោយឡែកត្រូវផ្ញើជូនអាជ្ញាធរគយក្នុងប្រទេសទាំងពីរ ដោយស្នើសុំ ប្រតិបត្តិករឆ្លងកាត់ទទួលបានការអនុញ្ញាត និងការអនុញ្ញាត÷

- សម្រាប់ឆ្លងកាត់ពីប្រទេស ក ទៅប្រទេស គ ដោយស្នើសុំការអនុញ្ញាតប្រទេសចេញដំណើរក្នុងប្រទេស ក និង
- ស្នើសុំការអនុញ្ញាតប្រទេសគម្យដ្ឋានក្នុងប្រទេស គ ឬ
- ជាមួយនឹងចរាចរណ៍ឆ្លងកាត់ទាំងទៅទាំងមក ស្នើសុំការអនុញ្ញាតប្រទេសចេញដំណើរ និងប្រទេសគម្យដ្ឋានក្នុងពាក្យសុំដោយផ្ញើជូនទាំងប្រទេស ក និងប្រទេស គ។

៣.៥. ការផ្តល់ការអនុញ្ញាត÷

៣.៥.១. បន្ទាប់ពីទទួលបាន និងវាយតម្លៃពាក្យសុំប្រតិបត្តិករឆ្លងកាត់ទទួលបានការអនុញ្ញាត÷

ក) អាជ្ញាធរទទួលបន្ទុកការអនុម័តត្រូវចាត់វិធានការសមស្របដើម្បីផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃពាក្យសុំដូចជា ការធ្វើទស្សនកិច្ចទៅកាន់ទីតាំងអ្នកដាក់ពាក្យសុំក្នុងការបញ្ជាក់វិធានការសុវត្ថិភាពរូបវន្ត និងព័ត៌មានលម្អិតនៃការគ្រប់គ្រងការរៀបចំ និងកំណត់ត្រាដែលបានរក្សាទុក

If the Customs Authority making the claim is in the same country as Guarantor, the written demand shall be presented to the Guarantor's counters at [address of the Guarantor being the place of presentation[7]]; or
if the Customs Authority making the claim is not in the same country as Guarantor, demands shall be made through any of the nominated correspondent banks in paragraph (e) below either by a written demand or via authenticated SWIFT to Guarantor's SWIFT code [insert SWIFT code] in the Form of Demand and Supporting Statement as follows:-

[Where the beneficiary is making a paper form written demand directly to the Guarantor]
"We refer to your reference no.[insert Guarantor's transaction reference number].
We hereby make a demand for the claim amount of [currency & amount of the beneficiary]. We hereby certify that we do not have proof of the termination of the transit procedure for [Name of Principal & address] under the Transit ACTS Reference Number (ARN) and dated [date of transit declaration."

[Where the beneficiary makes a demand through the nominated correspondent bank of the Guarantor as stipulated in clause (f);]
"We refer to your reference no.[insert Guarantor's transaction reference number].We hereby confirm receipt of a claim from [insert name of Customs Authority making the claim] in the Form of Claim for Recovery of Customs Debt as prescribed by ACTS. The claimant advises that they do not have proof of the termination of the transit procedure for [Name of Principal & address] under the Transit ACTS Reference Number (ARN) and dated [date of transit declaration]. Please pay the amount of [currency & amount] to the account of [Name of Custom Authority] account number [...][settlement instructions] ."

---

5 Full name and address of Principal

6 Any Beneficiary may make a demand for payment in their local currency. The Guarantor shall pay the Beneficiary, the amount demanded in their local currency or the amount available under the Maximum Amount converted at the prevailing exchange rate on the Date of Payment.

7 The written demand must be received by the Guarantor Bank at this address on or before the Claim Expiry Date.

Complying demands shall be paid within 30 days from date of receipt by the Guarantor ("Date of Payment"). The written demand or authenticated SWIFT shall be deemed as full and final of the amount of debt owing by the Principal to the claimant Customs Authority.

(c) A letter issued by the Customs Office of Guarantee releasing the Guarantor of its obligations under this Guarantee shall be full and final release of the Guarantor of its obligations under this Guarantee, notwithstanding that the original of this Guarantee has not been returned for cancellation.[8] Nevertheless, the return of the original Guarantee prior to the expiry date without any confirmation from Beneficiaries shall be deemed to be sufficient notice to the Guarantor to discharge all its liabilities under this Guarantee.[9]

(d) If the Guarantor receives more than one demand on the same day and the total of the demands exceeds the Maximum Amount, the Guarantor has an absolute discretion regarding the determination of which demand or demands it will pay and in what proportion, if any, its pays those demands.

(e) This Guarantee shall not be assigned or transferred without the Guarantor's prior written consent.

(f) The Beneficiaries may make their claim through the following correspondent[10] bank:-

| Country | Name of Correspondent Bank appointed by Customs Authority | Address of Headquarters |
|---|---|---|
| For Example<br>Malaysia<br>Thailand<br>Singapore | <br>Maybank Berhad<br>Bangkok Bank<br>DBS | Customs Authorities to provide address of their preferred banks. |

(g) The Customs Office of Guarantee shall be authorised to accept any amendments including cancellation notice by the Guarantor.

---

[8;9] In the event the journey is aborted and the issued Guarantee is no longer required, the Principal shall notify the Office of Guarantee and request the Office of Guarantee to issue a Letter of Release to the Guarantor Bank to release it of its obligations under the Guarantee with immediate effect quoting the Guarantee reference. However, if the Office of Guarantee releases the original Guarantee whether directly to the Guarantor or through the Principal, the Guarantor shall be discharged of its liabilities immediately without further reference to the Office of Guarantee.

[10] The Guarantor Bank may refer to the List of Banks appointed by each Customs Authority in each country, and select a correspondent bank in each country of transit and destination involved in the transit operation, alternatively, the Guarantee issuing bank may appoint a correspondent bank of their choice.

(h) Save as otherwise provided in this Guarantee, this Guarantee is issued subject to the Uniform Rules for Demand Guarantees (URDG 2010 REVISION, ICC Publication No 758) save and except that the requirement for a supporting statement under Article 15a of URDG758 is hereby excluded.

(i) This Guarantee is effective and valid from ddmmyyyy (the Effective Date) and expires on ddmmyyyy (the Expiry Date)[11]. All demands under this Guarantee shall be received on or before the close of business at the counters of the Guarantor within 1 year from the Expiry Date ("Claim Expiry Date").[12] The Guarantor shall have no liability under this Guarantee in respect of any claim which has not been received by the Guarantor on or before the Claim Expiry Date.

Made on this [day] [month], year]

..............................................................................................................................[13]
Authorised Signatory of the Guarantor Bank signing under Power of Attorney[14]

…………………………… ……………………………………..
(Signature) (Name – Printed)

……………………………………
(Position)

For and on behalf of…………………………………………………………………
(Name of Guarantor Bank)

[11] The Principal shall apply for the Guarantee to be issued and lodged with the Customs Office of Guarantee prior to the Expiry Date, in time for a Customs Declaration to be submitted.
[12] The Guarantor is liable to honour any demands received on or before the Claim Expiry Date. All complying demands received on or before the Claim Expiry Date shall be paid by the Date of Payment.
[13] The person signing the document must enter the following by hand writing before his or her signature "Guarantee for the amount of......................................" the amount being written out in letters.
[14] The Office of Guarantee which accepts this Guarantee shall be responsible to ensure that the form of execution is in a form which is legally binding on the Guarantor Bank i.e. the person signing has the legal capability to bind the Guarantor Bank to this undertaking under this Guarantee.

# ផ្នែកទី៥៖ វិធាននីតិវិធីនៃប្រព័ន្ធ ACTS

ផ្នែកនេះពិពណ៌នាវិធាននីតិវិធីទាំងមូលរបស់ប្រព័ន្ធ ACTS ចំណែកឯផ្នែកបន្ទាប់នៃសៀវភៅណែនាំនេះនឹងពន្យល់លម្អិតអំពីនីតិវិធីជាដំណាក់កាល ដែលការិយាល័យគយត្រូវអនុវត្តស្របតាមតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនក្នុងការគ្រប់គ្រងប្រតិបត្តិការឆ្លងកាត់។

## ១. នៅការិយាល័យចេញដំណើរ

### ១.១. ភារកិច្ចរបស់ម្ចាស់ទំនិញ

- ម្ចាស់ទំនិញតម្កល់និមុត្តិធានានៅធនាគារ និងយកឯកសារនិមុត្តិធានានោះមកដាក់នៅការិយាល័យគ្រប់គ្រងនិមុត្តិធានា។
- ម្ចាស់ទំនិញ ឬអ្នកតំណាងបញ្ចូលទិន្នន័យប្រតិវេទន៍ឆ្លងកាត់ក្នុងប្រព័ន្ធ ACTS នៅការិយាល័យចេញដំណើរដោយយោងតាមនិមុត្តិធានាដែលនឹងត្រូវប្រើដើម្បីគ្របដណ្តប់ប្រតិបត្តិការឆ្លងកាត់។

#### ១.១.១. ប្រតិវេទន៍ឆ្លងកាត់

- ប្រតិវេទន៍ត្រូវមានទិន្នន័យចាំបាច់ទាំងអស់ និងអនុលោមតាមភាពជាក់លាក់របស់ប្រព័ន្ធ ACTS
- ប្រព័ន្ធធ្វើការផ្ទៀងផ្ទាត់ទិន្នន័យដោយស្វ័យប្រវត្តិ
- រួមទាំងផ្ទៀងផ្ទាត់សុពលភាពនិមុត្តិធានា
- ប្រព័ន្ធនឹងបង្ហាញប្រាប់ ប្រសិនបើមានភាពមិនប្រក្រតីក្នុងទិន្នន័យ ហើយជូនដំណឹងមកកាន់ធុរជន ដូចនេះ ធុរជនអាចធ្វើការកែសម្រួល មុនពេលប្រតិវេទន៍ត្រូវបានទទួលយកនៅចុងក្រោយ។

#### ១.១.២. ទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់

ប្រព័ន្ធ ACTS នឹងបដិសេធទំនិញហាមឃាត់ ដោយមានសារពន្យល់ដល់ប្រតិវេទករ។ ពាក់ព័ន្ធនឹងទំនិញជាប់កម្រិតកំណត់ ប្រព័ន្ធ ACTS នឹងនាំប្រតិវេទន៍ដោយស្វ័យប្រវត្តិទៅរក “ដំណើរការនីតិវិធីធម្មតា” ដោយបង្កើតសារបញ្ជាក់ថា ជាប្រភេទ “ទំនិញជាប់កម្រិតកំណត់”។

បន្ទាប់មកប្រតិវេទន៍ និងទំនិញត្រូវបង្ហាញដល់ការិយាល័យចេញដំណើរ ហើយមន្ត្រីគយនឹងសម្រេចចិត្តត្រួតពិនិត្យឯកសារបន្ថែម និង/ឬតម្រូវឱ្យត្រួតពិនិត្យរូបវន្តទំនិញ ហើយសម្រេចថាតើអនុញ្ញាតបញ្ចេញទំនិញសម្រាប់ឆ្លងកាត់ដែរឬទេ។

#### ១.១.៣. លេខយោងប្រតិវេទន៍ (ARN)

បន្ទាប់ពីបានកែតម្រូវ និងបានទទួលយកប្រតិវេទន៍ ប្រព័ន្ធនឹងផ្តល់ប្រតិវេទន៍ជាមួយនឹងលេខយោងប្រតិវេទន៍ឆ្លងកាត់គយអាស៊ាន (ARN) ដែលមិនស្ទួនគ្នាឡើយ។

## ១.២. ភារកិច្ចរបស់មន្ត្រីគយ

### ១.២.១. ការបញ្ចេញទំនិញសម្រាប់ឆ្លងកាត់

- រាល់ការត្រួតពិនិត្យដែលចាត់ទុកថាមានភាពចាំបាច់ត្រូវអនុវត្តទាំងនៅការិយាល័យចេញដំណើរ (ក្រោមនីតិវិធីធម្មតា) ឬនៅទីតាំងដែលទទួលបានអនុញ្ញាតរបស់ម្ចាស់ទំនិញ (ក្រោមនីតិវិធីសាមញ្ញ)។
- ប្រសិនបើ គ្មានការសង្ស័យ (Satisfactory) បំណុលគយត្រូវបានគណនាតាមតម្លៃពន្ធ និងអាករខ្ពស់បំផុតក្នុងប្រទេសដែលពាក់ព័ន្ធនឹងប្រតិបត្តិការឆ្លងកាត់ ដែលត្រូវបានចុះបញ្ជិកាប្រើប្រាស់ធៀបនឹងនិមុត្តិធានា។
- ទំនិញក្នុងពេលឆ្លងកាត់ត្រូវធានាសុវត្ថិភាពដោយមានសៀលកិបជាប់ជាមួយ (សូមមើលក្នុងឧបសម្ព័ន្ធ ៥ខ សម្រាប់លក្ខខណ្ឌតម្រូវក្នុងការប្រើប្រាស់សៀល)។
- ទំនិញត្រូវបានបញ្ចេញសម្រាប់ឆ្លងកាត់។

### ១.២.២. ប្រតិវេទន៍អមដំណើរឆ្លងកាត់ (TAD)

- ក្រោយពីគយបានអនុញ្ញាត ប្រតិវេទន៍អមដំណើរឆ្លងកាត់ (TAD) ត្រូវបានបោះពុម្ពនៅការិយាល័យចេញដំណើរ។
- ប្រសិនប្រតិវេទន៍មានការបរិយាយទំនិញលើសពីមួយ ដូចបានកំណត់ដោយកូដទំនិញ AHTN, TAD អាចមាន “បញ្ជីទំនិញ” ដែលជាផ្នែកនៃ TAD។
- ក្នុងនីតិវិធីសាមញ្ញ TAD ត្រូវបានបោះពុម្ពនៅការិយាល័យម្ចាស់ទំនិញខ្លួនឯង។
- TAD និងបញ្ជីទំនិញផ្សេងទៀតត្រូវនៅជាប់ជាមួយអ្នកបើកបររថយន្ត និងនៅជាមួយទំនិញ។
- TAD ត្រូវបានបង្ហាញដល់ការិយាល័យឆ្លងកាត់ និងការិយាល័យគម្រដ្ឋាន។

### ១.២.៣. សារបញ្ជាក់ថានឹងមានប្រតិបត្តិការឆ្លងកាត់មកដល់ (AAR)

- ការិយាល័យចេញដំណើរផ្ញើសារបញ្ជាក់ថានឹងមានប្រតិបត្តិការឆ្លងកាត់មកដល់ជាអេឡិចត្រូនិកដោយស្វ័យប្រវត្តិទៅឱ្យការិយាល័យគម្រដ្ឋានដែលបានប្រកាស។
- សារនេះមានព័ត៌មានសំខាន់ៗដែលបានមកពីប្រតិវេទន៍ ដើម្បីជួយការិយាល័យគម្រដ្ឋានធ្វើការត្រួតពិនិត្យទំនិញនៅពេលទៅដល់។
- ការិយាល័យគម្រដ្ឋានចាំបាច់ត្រូវទទួលបានព័ត៌មានឱ្យបានច្រើនបំផុតអំពីប្រតិបត្តិការឆ្លងកាត់ ដើម្បីធ្វើការសម្រេចចិត្តដែលអាចទុកចិត្តបាន និងត្រឹមត្រូវ ដើម្បីចាត់វិធានការនៅពេលដែលទំនិញមកដល់។

### ១.២.៤. សារបញ្ជាក់ថានឹងមានប្រតិបត្តិការឆ្លងកាត់ (ATR)

- ការិយាល័យចេញដំណើរក៏ផ្ញើសារបញ្ជាក់ថានឹងមានប្រតិបត្តិការឆ្លងកាត់ដោយស្វ័យប្រវត្តិ ទៅឱ្យការិយាល័យពាក់ព័ន្ធនៃការឆ្លងកាត់ ដូចនេះការិយាល័យឆ្លងកាត់នីមួយៗមានការជូនដំណឹងជាមុនអំពីទំនិញដែលអាចមានបញ្ហា ហើយអាចត្រួតពិនិត្យដំណើរការឆ្លងកាត់។

## ២. នៅការិយាល័យគយឆ្លងកាត់

- នៅពេលទំនិញឆ្លងកាត់ការិយាល័យគយឆ្លងកាត់ ទំនិញ ប្រតិវេទន៍អមដំណើរឆ្លងកាត់ និងបញ្ជីមុខទំនិញដទៃទៀតត្រូវបង្ហាញមន្ត្រីគយ។




សារបញ្ជាក់ថានឹងមានប្រតិបត្តិការឆ្លងកាត់ដែលមានក្នុងប្រព័ន្ធនឹងស្វែងរកដោយស្វ័យប្រវត្តិ នៅពេលដែលលេខយោងប្រតិវេទន៍ឆ្លងកាត់គយអាស៊ាន (ARN) ត្រូវបានបញ្ចូលដោយដៃទៅក្នុងប្រព័ន្ធ ACTS ដោយមន្ត្រីគយ ឬដោយស្កែនបារកូដនៅលើ TAD។

- រថយន្ត ឬកុងតឺន័រអាចត្រូវបានពិនិត្យដើម្បីធានាថាសៀលនៅសភាពដូចដើម និងបន្ទាប់មកប្រតិបត្តិការអាចត្រូវបានអនុញ្ញាតឱ្យឆ្លងកាត់។

### ២.១. សារបញ្ជាក់ថាប្រតិបត្តិការបានឆ្លងកាត់ព្រំដែន (NCF)

- ការឆ្លងកាត់ព្រំដែននៃប្រតិបត្តិការឆ្លងកាត់ត្រូវបានចុះបញ្ជីក្នុងប្រព័ន្ធ ACTS និង “សារបញ្ជាក់ថាប្រតិបត្តិការបានឆ្លងកាត់ព្រំដែន (NCF)” ត្រូវបានផ្ញើទៅការិយាល័យចេញដំណើរ និងការិយាល័យគយឆ្លងកាត់ដទៃទៀត ព្រមទាំងការិយាល័យគម្យដ្ឋានផងដែរ។

## ៣. នៅការិយាល័យគម្យដ្ឋាន

- បន្ទាប់ពីទំនិញមកដល់ ទំនិញត្រូវបង្ហាញការិយាល័យគម្យដ្ឋាន ជាមួយនឹងប្រតិវេទន៍អមដំណើរឆ្លង-កាត់ ឬដោយប្រយោល ឬតាមរយៈអ្នកទទួលទំនិញដែលបានអនុញ្ញាត។
- នៅពេលដែលលេខ ARN ត្រូវបានចុះបញ្ជីទៅក្នុងប្រព័ន្ធដោយដៃ ឬតាមរយៈឧបករណ៍ស្កែនបារកូដ ប្រព័ន្ធនឹងស្វែងរកសារបញ្ជាក់ថានឹងមានប្រតិបត្តិការឆ្លងកាត់មកដល់។
- មន្ត្រីគយដោយមានព័ត៌មានលម្អិតអំពីប្រតិបត្តិការឆ្លងកាត់ មានឱកាសធ្វើការវាយតម្លៃហានិភ័យ និងធ្វើការសម្រេចចិត្តតាំងពីដំបូងថាតើត្រួតពិនិត្យអ្វីខ្លះដែលមានភាពចាំបាច់។

### ៣.១. សារបញ្ជាក់ថាបានមកដល់ (ARRIVAL ADVICE)

- ការមកដល់នៃប្រតិបត្តិការឆ្លងកាត់ត្រូវបានចុះបញ្ជីក្នុងប្រព័ន្ធ ACTS និងសារបញ្ជាក់ថាបានមកដល់ត្រូវបានផ្ញើទៅឱ្យការិយាល័យចេញដំណើរ។

- បន្ទាប់ពីការត្រួតពិនិត្យពាក់ព័ន្ធត្រូវបានអនុវត្ត ការិយាល័យគម្រដ្ឋាននឹងជូនដំណឹងការិយាល័យចេញដំណើរនៃលទ្ធផលត្រួតពិនិត្យដោយប្រើសារ ស្តីពីលទ្ធផលត្រួតពិនិត្យ ដោយបញ្ជាក់អំពីភាពមិនប្រក្រតីណាមួយ ប្រសិនបើបានរកឃើញ។

### ៣.២. ការបញ្ចប់ការឆ្លងកាត់

- ប្រសិនបើ ការមកដល់នៃទំនិញនៅការិយាល័យគម្រដ្ឋាន មិនមានកំហុសឆ្គង (Satisfactory) សារត្រួតពិនិត្យវិជ្ជមាន មានន័យថា សារបញ្ជាក់ការបញ្ចប់ទាំងស្រុងត្រូវបានផ្ញើទៅការិយាល័យចេញដំណើរដើម្បីបញ្ចប់ប្រតិបត្តិការឆ្លងកាត់ ហើយបញ្ចប់និមុត្តិធានាដែលបានប្រើសម្រាប់ប្រតិបត្តិការនេះ។
- ប្រសិនបើ ទំនិញមកដល់ដោយមានកំហុសឆ្គង (Unsatisfactory) ដោយហេតុផលណាមួយ ការិយាល័យគម្រដ្ឋាននឹងផ្ញើសារទៅឱ្យការិយាល័យចេញដំណើរដោយគូសបញ្ជាក់អំពីការបញ្ចប់ប្រតិបត្តិការក្រោមលក្ខខណ្ឌកំណត់។

## ឧបសម្ព័ន្ធនៃផ្នែកទី៥

### ឧបសម្ព័ន្ធ ៥ក÷ តារាងវិហ្សទិដ្ឋភាពទូទៅនៃដំណើរការ




ដ្យាក្រាមនេះពន្យល់អំពីទិដ្ឋភាពទូទៅនៃវិហ្សនីតិវិធីសំខាន់ៗនៃប្រព័ន្ធ ACTS ប៉ុន្តែដ្យាក្រាមនេះមិនបង្ហាញនូវដំណើរការតូចៗនោះទេ ដូចជា÷

- ការកែតម្រូវនានា
- ការផ្ទៀងផ្ទាត់ប្រតិវេទន៍ ការទទួលយក និងដំណើរការផ្ទៀងផ្ទាត់
- ការវិភាគហានិភ័យ
- ព័ត៌មានលម្អិតដំណើរការត្រួតពិនិត្យនៅការិយាល័យចេញដំណើរ និងការិយាល័យគម្យដ្ឋាន
- ការគ្រប់គ្រងនិមុត្តិធានា
- ការចាត់ចែងលទ្ធផលត្រួតពិនិត្យ
- ការបង្វែរទំនិញឆ្លងកាត់
- ដំណើរការសាកសួរ ឬ
- ការទូទាត់ពន្ធនិងអាករមកវិញ

ដំណើរការសំខាន់ៗមានពន្យល់ដូចខាងក្រោម÷

- រដ្ឋបាលប្រព័ន្ធ ACTS
- ការរៀបចំប្រតិវេទន៍ឆ្លងកាត់អេឡិចត្រូនិកតាមប្រព័ន្ធ ACTS និងការផ្តល់និមុត្តិធានា
- ដំណើរប្រព័ន្ធ ACTS ក្នុងការទទួលយកប្រតិវេទន៍
- ដំណើរការនៅការិយាល័យចេញដំណើរ
- ប្រតិវេទន៍អមដំណើរឆ្លងកាត់ (TAD) និងការចាប់ផ្តើមដំណើរការឆ្លងកាត់
- ដំណើរការនៅការិយាល័យគយឆ្លងកាត់
- ដំណើរការមកដល់នៅការិយាល័យគម្យដ្ឋាន
- ការបញ្ចេញទំនិញសម្រាប់ឆ្លងកាត់ និងបញ្ជូនដំណាក់កាលបន្ទាប់ក្នុងប្រព័ន្ធ ACTS។

***ចំណាំ:*** *តារាងវិហ្សលម្អិតនេះ បង្ហាញដំណាក់កាលនៃដំណើរការ ACTS នីមួយៗ ដោយមានការពន្យល់ ក្នុងឧបសម្ព័ន្ធទូទៅនៅផ្នែកខាងក្រោយនៃសៀវភៅណែនាំនេះ។*

## ឧបសម្ព័ន្ធ ៥ខ÷ សៀលសុវត្ថិភាព

### ១. គោលបំណងរបស់សៀល

សៀលដែលបានកិបនៅលើរថយន្ត និងកុងតឺន័រ ផ្តល់នូវយន្តការសុវត្ថិភាពរូបវន្តដើម្បីធានាថា ទំនិញដែលបង្ហាញនៅចំណុចចាប់ផ្តើមនៃដំណើរការឆ្លងកាត់នឹងចាកចេញប្រទេសឆ្លងកាត់ក្នុងបរិមាណ ទម្រង់ និងក្នុងស្ថានភាពដូចគ្នា។

សៀលត្រូវធ្វើឡើងដោយអនុលោមតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ ដើម្បីធានាប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាព។

សៀលមានច្រើនប្រភេទ រួមទាំង សៀលអេឡិចត្រូនិក (មីក្រូឈីប) ដែលនៅពេលវាខូច អាចបញ្ជូនសញ្ញាទៅកាន់ផ្តាយរណប និងផ្ញើព័ត៌មានទៅឱ្យអាជ្ញាធរមានសមត្ថកិច្ច ឬម្ចាស់ទំនិញដែលបានកិបសៀលនៅលើរថយន្ត ឬកុងតឺន័រនោះ ដូចជា ព័ត៌មានអំពីទីតាំងរបស់រថយន្ត ឬកុងតឺន័រ។

- ម្ចាស់ទំនិញអាចអនុញ្ញាតឱ្យប្រើប្រភេទសៀលពិសេសលើមធ្យោបាយដឹកជញ្ជូន ឬកុងតឺន័រទំនិញដោយអនុលោមលក្ខខណ្ឌបច្ចេកទេស។



រូបភាពទី១÷ ឧទាហរណ៍នៃប្រភេទសៀលផ្សេងៗ

### ២. លក្ខណៈសំខាន់ៗរបស់សៀល

សៀលត្រូវមានលក្ខណៈ និងស្របតាមបច្ចេកទេសជាក់លាក់សំខាន់ៗដូចខាងក្រោម÷

ក) រក្សាបានសុវត្ថិភាពក្នុងការប្រើប្រាស់ធម្មតា

ខ) ងាយស្រួលត្រួតពិនិត្យ និងងាយសម្គាល់

គ) ត្រូវបានផលិតឡើងក្នុងករណីខូចខាត ឬការដកចេញណាមួយ អាចបន្សល់នូវដានដែលអាចមើលឃើញដោយភ្នែកទទេ

ឃ) ត្រូវបានផលិតឡើងសម្រាប់ប្រើតែមួយដង ប្រសិនបើ មានចេតនាប្រើច្រើនដង ដូចនេះអាចបង្ហាញយ៉ាងច្បាស់នូវសញ្ញាសម្គាល់នីមួយៗនៅគ្រប់ពេលដែលសៀលទាំងនេះត្រូវបានប្រើម្តងទៀត និង

ង) មានសញ្ញាសម្គាល់ច្បាស់លាស់។

### ៣. លក្ខណៈបច្ចេកទេស

ក) ទម្រង់ និងទំហំរបស់សៀលអាចខុសគ្នាតាមរយៈវិធីសាស្ត្រប្រើប្រាស់សៀល ប៉ុន្តែទំហំត្រូវធានាថាសញ្ញាសម្គាល់មានភាពងាយស្រួលអាន។

ខ) សញ្ញាសម្គាល់របស់សៀលត្រូវតែមិនអាចក្លែងបន្លំបាន និងពិបាកធ្វើឡើងវិញ។

គ) សារធាតុដែលប្រើត្រូវធន់នឹងការខូចខាតដោយចៃដន្យ និងដើម្បីបង្ការការក្លែងបន្លំ ឬការប្រើប្រាស់ឡើងវិញ។

### ៤. វិធីសាស្ត្រនៃការកិបសៀល

មានវិធីសាស្ត្រពីរក្នុងការកិបសៀល÷

- កិបសៀលលើកុងតឺន័រ/ មធ្យោបាយដឹកជញ្ជូនដែលមានទំនិញ
- កិបសៀលលើកញ្ចប់ទំនិញនីមួយៗ

សៀលត្រូវបានកិបមុនពេលទំនិញត្រូវបានបញ្ចេញសម្រាប់ឆ្លងកាត់។ លេខសីរៀល (Serial Number) តែមួយគត់របស់សៀលត្រូវដាក់បញ្ចូលទៅក្នុងប្រព័ន្ធ ACTS។

### ៥. ការលះបង់ចោលលក្ខខណ្ឌតម្រូវសៀល

ការិយាល័យចេញដំណើរអាចលះបង់ចោលលក្ខខណ្ឌតម្រូវសម្រាប់ការកិបសៀល នៅពេលដែលប្រភពនៃទំនិញដែលត្រូវបានដឹកជញ្ជូនធ្វើឱ្យការងារនេះមិនអាចអនុវត្តបាន ក្រោមបរិយាយគ្រប់គ្រាន់អំពីទំនិញដើម្បីធានាភាពងាយស្រួលក្នុងការកំណត់អត្តសញ្ញាណទំនិញ។

**ឧទាហរណ៍ដូចជា÷**

- ទំនិញដែលបានដឹកជញ្ជូនមានទ្រង់ទ្រាយធំ
- សម្ភារ ឬគ្រឿងចក្រធំៗ ដែលធ្វើការចល័តដោយមិនចាំបាច់វេចខ្ចប់

### ៦. ការដឹកជញ្ជូនដែលសមស្របសម្រាប់កិបសៀល

ការិយាល័យចេញដំណើរ ចាត់ទុកមធ្យោបាយដឹកជញ្ជូនមួយមានភាពសមស្របសម្រាប់កិបសៀលនៅពេលដែល÷

- សៀលអាចកិបយ៉ាងងាយស្រួល និងមានប្រសិទ្ធភាពសម្រាប់មធ្យោបាយទាំងនេះ
- សៀលត្រូវបានផលិតឡើងដោយមិនអាចដកចេញ ឬប៉ះពាល់ទំនិញដោយមិនបន្សល់ដានឱ្យឃើញនៃការរុះរើ ឬដោយមិនបំបែកសៀលនោះឡើយ
- សៀលមិនមានចន្លោះដែលអាចលាក់ទំនិញបាន និង
- ចន្លោះដែលបានរក្សាទុកសម្រាប់ផ្ទុកទំនិញមានភាពងាយស្រួលសម្រាប់អាជ្ញាធរមានសមត្ថកិច្ចត្រួតពិនិត្យ។

## ACTS - ASEAN CUSTOMS TRANSIT SYSTEM

ARN 0000000000089678145

TRANSIT ACCOMPANYING DOCUMENT (TAD)

1 DECLARATION
Type

2 Consignor TIN

3 Forms

4 Total Items

5 Total packages

6 Consignee TIN

7 Total gross weight (Kg)

8 Proposed date of departure

9 Date of release for transit

10 Trader reference/Contact details

11 Proposed countries of transit

12 Country of destination

13 Identification of means of transport

14 Container ☐

15 OFFICE OF DEPARTURE

16 Nationality of means of transport

17 Mode of Transport

18 place of loading

19 Office of Exit

20 Location of goods

21 Container identifier, marks and number of packages, number and type of packages and description of goods

22 Item No

23 Commodity Code

24 Currency code

25 Invoice value

26 Gross weight (kg)

27 Net weight (kg)

28 Supplementary Unit

29 Country of origin

30 Country of origin code

31 Other information covering the liability of goods to specific requirements

32 Change of conveyance / container

Place and country — Code | Place and country — Code

Identity and nationality of new means of transport — Code | Identity and nationality of new means of transport — Code

New Container (yes / no)? ☐ Identity of new container | New Ctr. (yes or no)? ☐ Identity of new container

33 CERTIFICATION BY COMPETENT AUTHORITY

New seals Number: Serial number: | New seals Number: Serial number:

Name and signature Stamp | Name and signature Stamp

34 Principal TIN

Represented by
Place and date:

35 Other incidents during carriage; details and measures taken:

Details on reverse ☐

36 CERTIFICATION BY COMPETENT AUTHORITIES

37 Intended Customs offices of transit

38 Guarantee details

39 Countries not valid for guarantee (code)

40 Customs Office of Destination

41 CONTROL BY CUSTOMS OFFICE OF DEPARTURE
Result:

Seals affixed (Number):
Serial number:
Time limit (date) & Itinerary:
Name and signature: Stamp

42 CONTROL BY CUSTOMS OFFICE OF DESTINATION
Date of arrival:
Examination of seals:
Remarks:

43 Receipt registration under No.

Name and signature: Stamp

## ១. បញ្ជីមុខទំនិញ TAD

# ACTS TRANSIT ACCOMPANYING DOCUMENT
## LIST OF ITEMS

ARN 0000000000089678145

34 Principal — TIN — 3 Forms

21 Container identifier, marks and number of packages, number and type of packages and description of goods

22 Item No | 23 Commodity Code | 24 Currency code
25 Invoice value
26 Gross weight (kg) | 27 Net weight (kg)
28 Supplementary Unit
29 Country of origin | 30 Country of origin code

31 Other information covering the liability of goods to specific requirements

21 Container identifier, marks and number of packages, number and type of packages and description of goods

22 Item No | 23 Commodity Code | 24 Currency code
25 Invoice value
26 Gross weight (kg) | 27 Net weight (kg)
28 Supplementary Unit
29 Country of origin | 30 Country of origin code

31 Other information covering the liability of goods to specific requirements

21 Container identifier, marks and number of packages, number and type of packages and description of goods

22 Item No | 23 Commodity Code | 24 Currency code
25 Invoice value
26 Gross weight (kg) | 27 Net weight (kg)
28 Supplementary Unit
29 Country of origin | 30 Country of origin code

31 Other information covering the liability of goods to specific requirements

21 Container identifier, marks and number of packages, number and type of packages and description of goods

22 Item No | 23 Commodity Code | 24 Currency code
25 Invoice value
26 Gross weight (kg) | 27 Net weight (kg)
28 Supplementary Unit
29 Country of origin | 30 Country of origin code

31 Other information covering the liability of goods to specific requirements

21 Container identifier, marks and number of packages, number and type of packages and description of goods

22 Item No | 23 Commodity Code | 24 Currency code
25 Invoice value
26 Gross weight (kg) | 27 Net weight (kg)
28 Supplementary Unit
29 Country of origin | 30 Country of origin code

31 Other information covering the liability of goods to specific requirements

## ២. ទម្រង់រាយការណ៍ឧប្បត្តិហេតុ

# ASEAN CUSTOMS TRANSIT SYSTEM (ACTS)

| **TRANSIT INCIDENT REPORT FORM**<br>To accompany the ACTS Transit Accompanying Document (TAD) – see guidance on reverse | 1. ACTS Reference Number (ARN): |
|---|---|
| 2. Transport operator (name, address, contact details) | 3. Principal (name, address, contact details) |
| 4. Registration plate & nationality of means of transport at departure — Container Y/N | 5. Customs Office Of Departure |

**6. Nature of en-route incident:**

1) Diversion to different frontier office / country? YES / NO (delete inapplicable)
2) Transfer of goods or container to another means of transport? YES / NO
3) Customs seals on load compartment or container are broken or missing? YES / NO
4) Load compartment or container is damaged or opened without Customs authority? YES / NO
5) Load/cargo manifest discrepancies or goods appear to be damaged or missing? YES / NO
6) Failure to obtain permission to proceed of authorities at border control point? YES / NO
7) Other reportable incident during transit? YES / NO

**7. In all cases of en-route incidents give details below**

| Item No (from box 22 of TAD) | Number and type of packages; description of the goods involved (from TAD box 21) | Details, including date, place and circumstances of the incident/s, including quantities of any goods missing or destroyed |
|---|---|---|
| | | |

**8. Change of means of transport / container / frontier office / country of transit and / or destination**

*Give details in this section where the transit goods are transferred to another vehicle or container or load compartment*

1) Identity and nationality of new road vehicle:
2) If containerised , identity no. of new container:
3) Number and identity of new seals attached:
4) New frontier office and / or country of destination:
5) Place , country of transhipment — Name / Signature — Stamp

**9. Where transit goods are damaged, destroyed, missing or stolen, give details of measures taken:**
(copies of any relevant police reports are to be attached)

Where space on this report is not sufficient, attach details on separate paper and record here details of those attachments

| **10. Authority (e.g. Police, or other Government Agency) having completed this report** | **11. control by next Customs Office after occurrence of incident** |
|---|---|
| Place, date | Place, date |

## ការណែនាំសម្រាប់ប្រើប្រាស់ទម្រង់រាយការណ៍ឧប្បត្តិហេតុឆ្លងកាត់តាមប្រព័ន្ធ ACTS

1. ឯកសារនេះនឹងត្រូវបំពេញក្នុងករណីដែលមានឧប្បត្តិហេតុនានានៃដំណើរការឆ្លងកាត់តាមប្រព័ន្ធ ACTS។ ឧប្បត្តិហេតុទាំងនេះអាចពាក់ព័ន្ធនឹង÷
   - ការផ្លាស់ប្តូរមធ្យោបាយដឹកជញ្ជូនដោយសារគ្រោះថ្នាក់ខូចមធ្យោបាយដឹកជញ្ជូន
   - ការបង្វែរទៅកាន់ការិយាល័យគយមួយផ្សេងទៀតដែលខុសពីការិយាល័យគយដែលបានកំណត់ពីខាងដើម
   - ការបង្វែរទៅកាន់ប្រទេសមួយផ្សេងទៀតដែលខុសពីប្រទេសដែលបានកំណត់ពីខាងដើម
   - ការធ្វើឱ្យខូចខាតសៀលរបស់ក្រុមហ៊ុន ឬរបស់អាជ្ញាធរគយដោយចៃដន្យ
   - ការលួចទំនិញ
   - ឧប្បត្តិហេតុផ្សេងទៀត
2. ឯកសារនេះនឹងត្រូវបំពេញ ចុះហត្ថលេខា និងបោះត្រាជាមួយនឹងត្រាផ្លូវការដោយទីភ្នាក់ងារផ្លូវការ ដូចជាភ្នាក់ងារនគរបាល ឬភ្នាក់ងាររដ្ឋាភិបាលផ្សេងទៀត។
3. ប្រតិវេទន៍អមដំណើរឆ្លងកាត់ (TAD) ត្រូវបោះពុម្ពនៅការិយាល័យចេញដំណើរ និងរក្សាទុកជាមួយទំនិញអំឡុងពេលប្រតិបត្តិការឆ្លងកាត់តាមប្រព័ន្ធ ACTS ហើយក្នុងករណីនៃឧប្បត្តិហេតុសូមសរសេរដៃនៅកន្លែងដែលបានបង្ហាញ។
4. ឯកសារនេះ និងឯកសារភ្ជាប់ផ្សេងទៀតត្រូវបំពេញជាភាសាអង់គ្លេស។ ជាងនេះទៅទៀត ព័ត៌មានដែលបានកត់ត្រាទុកអាចធ្វើម្តងទៀតជាភាសាជាតិ។
5. ប្រតិបត្តិករដឹកជញ្ជូនទទួលខុសត្រូវក្នុងការធានាថារាល់ឯកសារដឹកជញ្ជូន និងឯកសារគយទាំងអស់ត្រូវបង្ហាញដល់មន្ត្រីដឹកជញ្ជូន និងមន្ត្រីគយនៅច្រកឆ្លងកាត់ព្រំដែននីមួយៗ និងនៅការិយាល័យគមម្យដ្ឋាន។
6. មន្ត្រីគយនៅការិយាល័យគម្យដ្ឋាននឹងចុះហត្ថលេខា និងបោះត្រាលើ TAD ក្នុងប្រអប់ ៤៣ ហើយប្រគល់ឱ្យប្រតិបត្តិករដឹកជញ្ជូនវិញទុកជាវិក្កយបត្រ។ ក្រោមនីតិវិធីសាមញ្ញតាមប្រព័ន្ធ ACTS ធុរជននៅការិយាល័យគយគម្យដ្ឋាននឹងចុះហត្ថលេខា និងបោះត្រាក្នុងប្រអប់ ៤៣ នៃ TAD ហើយប្រគល់ឱ្យទៅប្រតិបត្តិករដឹកជញ្ជូនវិញទុកជាវិក្កយបត្រ។

## ឧប្បត្តិហេតុនានា

7. អាជ្ញាធរគយម្ចាស់ប្រទេសត្រូវជូនដំណឹងជាបន្ទាន់ ក្នុងករណី មានការខូចខាតដោយបាត់សៀលគយ មានការខូចខាត ឬការបំផ្លាញទំនិញ បង្ខំចិត្តផ្លាស់ប្តូររថយន្តដោយសារឧប្បត្តិហេតុ ឬខូច ឬបង្ខំចិត្តផ្លាស់ប្តូរតម្រាយផ្លូវ
8. ឧទាហរណ៍ខាងដើម ក្នុងករណីមានឧប្បត្តិហេតុ ឬការខូចខាតឬបាត់បង់ជាក់ស្តែង ឧប្បត្តិហេតុនេះត្រូវរាយការណ៍មកស្ថាប័នរដ្ឋ ដូចជា ស្ថាប័ននគរបាល ឬទីភ្នាក់ងាររដ្ឋាភិបាល ដែលនឹងបញ្ចប់ ព្រមទាំងអនុម័តទម្រង់របាយការណ៍ឧប្បត្តិហេតុឆ្លងកាត់តាមប្រព័ន្ធ ACTS និង TAD។

9. ដើម្បីបន្តប្រតិបត្តិការឆ្លងកាត់តាមប្រព័ន្ធ ACTS មធ្យោបាយដឹកជញ្ជូនជំនួសត្រូវមានលិខិតអនុញ្ញាតយានយន្តដឹកទំនិញឆ្លងកាត់ព្រំដែនអាស៊ាន (AGVCBP)។ ប្រសិនបើ មិនមានមធ្យោបាយដឹកជញ្ជូនបែបនេះទេ ទំនិញត្រូវដឹកជញ្ជូនទៅការិយាល័យគយដែលនៅជិតបំផុត ហើយប្រតិបត្តិការឆ្លងកាត់តាមប្រព័ន្ធ ACTS នឹងត្រូវបញ្ចប់នៅទីនេះក្រោមការត្រួតពិនិត្យរបស់មន្ត្រីគយ។
10. រាល់ឧបទ្ទវហេតុដែលបណ្តាលឱ្យ ឬតម្រូវឱ្យបំបែក និងជំនួសសៀលត្រូវកត់ត្រាដោយដៃនៅលើ TAD (ប្រអប់លេខ ៣៣) និងនៅលើទម្រង់រាយការណ៍ឧប្បត្តិហេតុឆ្លងកាត់។

***កំណត់សម្គាល់សម្រាប់អាជ្ញាធរគយ÷*** *ការប្រើប្រាស់នៃទម្រង់នេះជាជម្រើស។ គោលបំណងគឺដើម្បីសង្ខេបព័ត៌មានសំខាន់ៗក្នុងការរាយការណ៍ក្នុងករណីមានឧប្បត្តិហេតុនានា អំឡុងពេលប្រតិបត្តិការឆ្លងកាត់ និងសម្រាប់ភ្នាក់ងាររដ្ឋាភិបាលប្រើប្រាស់សម្រាប់ចុះហត្ថលេខា និងបោះត្រាជាមួយត្រាផ្លូវការ។ សូមបញ្ជាក់ថា ទម្រង់នេះមាននៅការិយាល័យចេញដំណើរដើម្បីផ្តល់ដល់អ្នកបើកបរ ជាមួយនឹង TAD ក្រោមនីតិវិធីធម្មតា។ សម្រាប់នីតិវិធីសាមញ្ញ ត្រូវបានស្នើថា អាជ្ញាធរគយផ្តល់ទម្រង់ទាំងនេះជាអេឡិចត្រូនិកដល់ម្ចាស់ទំនិញដែលជាប្រតិបត្តិករឆ្លងកាត់ទទួលបានការអនុញ្ញាត។*

## ឧបសម្ព័ន្ធ ៥យ÷ ភាពជាក់លាក់នៃការផ្ទៀងផ្ទាត់ប្រតិវេទន៍

សៀវភៅបច្ចេកទេសសម្រាប់អ្នកប្រើប្រាស់ប្រព័ន្ធ ACTS ផ្តល់ព័ត៌មានលម្អិតអំពីសមាសភាពលម្អិតនៃទិន្នន័យ ឬការបរិយាយព័ត៌មានក្នុងប្រតិវេទន៍ឆ្លងកាត់ដែលត្រូវបានត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ក្នុងដំណើរការទទួលយកនិងការផ្ទៀងផ្ទាត់។

# ផ្នែកទី៦÷ ការិយាល័យចេញដំណើរ

មាននីតិវិធីឆ្លងកាត់តាមប្រព័ន្ធ ACTS ចំនួនពីរសម្រាប់ម្ចាស់ទំនិញ÷

- **នីតិវិធីធម្មតា**÷ ដែលតម្រូវឱ្យទំនិញត្រូវបង្ហាញនៅការិយាល័យចេញដំណើរ ឬ
- **នីតិវិធីសាមញ្ញ**÷ សម្រាប់តែធុរជនទាំងឡាយណាដែលជាប្រតិបត្តិករឆ្លងកាត់ទទួលបានការអនុញ្ញាត (ATT) ដែលអនុញ្ញាតឱ្យផ្ទុកទំនិញនៅទីតាំងដែលទទួលបានការអនុញ្ញាតរបស់ខ្លួន។

នីតិវិធីសាមញ្ញជួយសម្របសម្រួលធុរជនទទួលបានប្រព័ន្ធឆ្លងកាត់ឱ្យកាន់តែមានប្រសិទ្ធភាព ហើយស្របពេលជាមួយគ្នានោះ នីតិវិធីសាមញ្ញនេះអនុញ្ញាតឱ្យអាជ្ញាធរគយកំណត់ធុរជនដែលមានហានិភ័យទាប ព្រមទាំងដើម្បីឱ្យអាជ្ញាធរគយប្រើប្រាស់ធនធានទៅលើផ្នែកដែលមានហានិភ័យមធ្យម និងផ្នែកដែលមានហានិភ័យខ្ពស់។

## ១. ការត្រួតពិនិត្យធម្មតានៅការិយាល័យចេញដំណើរ

### ១.១. វិធានការត្រួតពិនិត្យនៅការិយាល័យចេញដំណើរ

ព័ត៌មានលម្អិតនៃប្រតិវេទន៍ឆ្លងកាត់ត្រូវបានទាញយកដោយប្រព័ន្ធ ACTS តាមរយៈការស្វែងរកលេខយោងប្រតិវេទន៍ឆ្លងកាត់គយអាស៊ាន ARN។

ប្រព័ន្ធ ACTS ធ្វើការវិភាគហានិភ័យនៃប្រតិវេទន៍ដោយស្វ័យប្រវត្តិដោយប្រើប៉ារ៉ាម៉ែត្រហានិភ័យដើម្បីសម្រេចចិត្តថាគួរត្រួតពិនិត្យបន្ថែមក្នុងករណីចាំបាច់ដូចជា ការត្រួតពិនិត្យឯកសារ ឬការត្រួតពិនិត្យរូបវន្តដែរឬទេ។

- ប្រសិនបើ លទ្ធផលវិភាគហានិភ័យបញ្ជាក់ថា ទំនិញមិនអាចបញ្ចេញបាន ដូចនេះ ប្រព័ន្ធ ACTS នឹងជូនដំណឹងមន្ត្រីគយឱ្យបានដឹង។
- មន្ត្រីគយអាចបដិសេធចោលការសម្រេចចិត្តដែលបានធ្វើឡើងដោយស្វ័យប្រវត្តិរបស់ប្រព័ន្ធ ACTS ថាតើត្រូវបញ្ចេញទំនិញ ឬបញ្ជូនទៅត្រួតពិនិត្យបន្ថែម។
- ប្រសិនបើ មន្ត្រីគយសម្រេចចិត្តមិនធ្វើការត្រួតពិនិត្យលើទំនិញ មន្ត្រីគយត្រូវកត់ត្រាការសម្រេចចិត្ត និងហេតុផលទៅក្នុងប្រព័ន្ធ ACTS។
- សម្រាប់ការត្រួតពិនិត្យ ម្ចាស់ទំនិញត្រូវបានជូនដំណឹងអំពីការត្រួតពិនិត្យដើម្បីអនុញ្ញាតឱ្យគាត់មានវត្តមាននៅពេលត្រួតពិនិត្យ។

*ចំណាំ÷ នៅពេលមន្ត្រីគយចាប់ផ្តើមធ្វើការត្រួតពិនិត្យ ប្រតិវេទករមិនអាចកែប្រតិវេទន៍ទៀតឡើយ លើកលែងតែមន្ត្រីរកឃើញកំហុស ហើយបញ្ជូនត្រឡប់ឱ្យប្រតិវេទករធ្វើការកែតម្រូវឡើងវិញ។*

#### ១.១.១. ការគ្រប់គ្រងការត្រួតពិនិត្យ

ការផ្ទៀងផ្ទាត់ទំនិញ និង/ ឬឯកសារអមភ្ជាប់ និង/ ឬសៀល ជាដំណើរការដោយដៃដែលនឹងត្រូវអនុវត្តដោយមន្ត្រីគយនៅទីតាំងដាក់ទំនិញ។

- មន្ត្រីគយទៅទីតាំងដាក់ទំនិញ (ដូចបានបញ្ជាក់ក្នុងប្រតិវេទន៍) ដើម្បីផ្ទៀងផ្ទាត់ឯកសារ ឬទំនិញ (ឬទាំងពីរ) ដោយយកទៅជាមួយនូវប្រតិវេទន៍ដែលបានបោះពុម្ព។

- មន្ត្រីគយត្រួតពិនិត្យទំនិញធៀបនឹងប្រតិវេទន៍ដែលបានបោះពុម្ព។
- មន្ត្រីគយក៏អាចត្រួតពិនិត្យឯកសារអមភ្ជាប់ផងដែរ ដូចជា ឯកសារពាណិជ្ជកម្ម វិក្កយបត្រ បញ្ជីវេចខ្ចប់ និវេទនបណ្ណ និងអញ្ញត្តិបណ្ណជាដើម។
- មន្ត្រីគយកិប ឬកិបសៀលឡើងវិញ។

### ១.១.២. លទ្ធផលត្រួតពិនិត្យ

ប្រសិនបើ ការត្រួតពិនិត្យបានបង្ហាញថា គ្មានភាពមិនប្រក្រតីណាមួយលើទំនិញដែលបានត្រួតពិនិត្យ ជាមួយនឹងលទ្ធផលត្រួតពិនិត្យ "គ្មានកំហុសឆ្គង" ត្រូវបានចុះបញ្ជីទៅក្នុងប្រព័ន្ធ ACTS ដោយមន្ត្រីគយ។

*ចំណាំ៖ បំណុលគយត្រូវបានគណនាដោយប្រព័ន្ធ ACTS និងការប្រើប្រាស់និមុត្តិធានាត្រូវបានចុះបញ្ជីនៅការិយាល័យគ្រប់គ្រងនិមុត្តិធានា។*

មន្ត្រីគយមានសិទ្ធិកំណត់ពេលវេលាមកដល់ និងពេលវេលាត្រួតពិនិត្យ តាមរយៈការកែតម្រូវក្នុងប្រព័ន្ធ ACTS ដោយប្តូរទៅការកំណត់ប្រព័ន្ធលំនាំដើម។

ប្រព័ន្ធចាំបាច់ត្រូវមានមុខងារសម្រាប់រកឃើញនូវការពន្យានានា ដោយមានហេតុផលសមស្របសម្រាប់អនុញ្ញាតឱ្យមន្ត្រីគយគយធ្វើការសាកសួរដំណឹង។

### ១.១.៣. ការដោះស្រាយភាពមិនប្រក្រតីនៃការត្រួតពិនិត្យ

នៅពេល មានកំហុសឆ្គងតូច មន្ត្រីគយជូនដំណឹងម្ចាស់ទំនិញ។ ក្នុងករណី មានកំហុសឆ្គងតូចហើយម្ចាស់ទំនិញយល់ព្រម (មិនបដិសេធ) ជាមួយមន្ត្រីគយលើការកែសម្រួលកំហុសឆ្គងតូចនៃទិន្នន័យប្រតិវេទន៍៖

- មន្ត្រីគយអាចអនុញ្ញាតឱ្យម្ចាស់ទំនិញកែសម្រួល
- មន្ត្រីគយត្រូវបញ្ជាក់ថា រាល់ការកែប្រែណាមួយត្រូវអនុលោមតាមលទ្ធផលការពិនិត្យ និងការឯកភាព
- បើដូចនេះ លទ្ធផលត្រួតពិនិត្យថា គ្មានកំហុសឆ្គង ត្រូវបានចុះបញ្ជី ហើយប្រតិវេទន៍អាចចាប់ផ្តើមចុះបញ្ជិកាប្រើប្រាស់និមុត្តិធានាបាន។

*ចំណាំ៖ នៅពេលម្ចាស់ទំនិញបដិសេធ (ដូចជា គាត់មិនទទួលយកការកែសម្រួលដែលបានស្នើ) មន្ត្រីគយមានសិទ្ធមិនបញ្ចេញទំនិញសម្រាប់ឆ្លងកាត់។*

- មន្ត្រីគយកត់ត្រាលទ្ធផលត្រួតពិនិត្យ
- ប្រតិវេទន៍ត្រូវបានដាក់ក្នុងស្ថានភាពមិនមានដំណើរការ ដោយរង់ចាំរហូតដល់មានវិធានការបន្ថែម។

ក្នុងករណីម្ចាស់ទំនិញមិនទាន់បានផ្តល់យោបល់លើការកែសម្រួលកំហុសឆ្គងតូចនៅឡើយ ប្រតិវេទន៍នឹងស្ថិតក្រោមស្ថានភាព "រង់ចាំសំណើបញ្ចេញ" រហូតដល់មានការឆ្លើយតបពីម្ចាស់ទំនិញ។

### ១.១.៤. កំហុសធ្ងន់ធ្ងរ

ការត្រួតពិនិត្យបានបង្ហាញថាមានភាពមិនប្រក្រតីខ្លាំង ឬមានហេតុផលសមស្របសម្រាប់ការិយាល័យចេញដំណើរយកមកពិចារណាថា ការបង្ហាញទំនិញក្នុងរបបឆ្លងកាត់គយអាចបង្កការគំរាមកំហែងធ្ងន់ធ្ងរចំពោះសុវត្ថិភាព និងសន្តិសុខនៃប្រទេសពាក់ព័ន្ធនានា។

ឧទាហរណ៍÷ ការបរិយាយបន្លំ ឬទំនិញមិនបានប្រកាសត្រូវបានចាត់ទុកថា ជាកំហុសធ្ងន់ធ្ងរ។ ទំនិញបានប្រកាសប៉ុន្តែមិនបានបង្ហាញពេលត្រួតពិនិត្យក៏ត្រូវបានចាត់ទុកជាកំហុសធ្ងន់ធ្ងរដែរ។ ក្នុងករណីនេះ÷

- ទំនិញដែលបានត្រួតពិនិត្យមានកំហុសធ្ងន់ធ្ងរ (ដែលមិនអាចកែតម្រូវបាន) មន្ត្រីត្រូវចុះបញ្ជីលទ្ធផលត្រួតពិនិត្យ។
- ការិយាល័យចេញដំណើរជូនដំណឹងម្ចាស់ទំនិញថាប្រតិបត្តិការអាចមិនទៅដល់ការិយាល័យគម្យដ្ឋាន។
- អាចរងនូវទោសទណ្ឌតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

### ១.១.៥. ការបញ្ចេញទំនិញសម្រាប់ឆ្លងកាត់

ក្នុងករណីដែលប្រតិវេទន៍ឆ្លងកាត់ត្រូវបានបញ្ចេញសម្រាប់ឆ្លងកាត់ ប្រព័ន្ធ ACTS នឹងជូនដំណឹងម្ចាស់ទំនិញថា ទំនិញត្រូវបានបញ្ចេញសម្រាប់ឆ្លងកាត់ ហើយមន្ត្រីគយត្រូវ÷

- កិប ឬផ្ទៀងផ្ទាត់សៀលដែលកិបជាប់នឹងកន្លែងផ្ទុកទំនិញ
- កត់ត្រាអត្តសញ្ញាណ និងលេខសៀលចូលទៅក្នុងប្រព័ន្ធ ACTS និង
- បោះពុម្ពប្រតិវេទន៍អមដំណើរឆ្លងកាត់ (TAD) និងរាល់បញ្ជីមុខទំនិញជាទម្រង់ក្រដាស ដែលត្រូវប្រគល់ឱ្យធុរជន រួចមន្ត្រីគយនៅការិយាល័យចេញដំណើរបញ្ចេញទំនិញសម្រាប់ឆ្លងកាត់។

## ២. នីតិវិធីសាមញ្ញនៅការិយាល័យចេញដំណើរ

ប្រតិវេទន៍ឆ្លងកាត់ត្រូវផ្ទៀងផ្ទាត់និងត្រួតពិនិត្យដោយប្រព័ន្ធ ACTS ដូចនីតិវិធីធម្មតា លើសពីនេះទៀត÷

- ម្ចាស់ទំនិញត្រូវតែជាប្រតិបត្តិករឆ្លងកាត់ទទួលបានការអនុញ្ញាត (ATT) និងបានអនុញ្ញាតសម្រាប់ការិយាល័យចេញដំណើរនោះ
- ទំនិញត្រូវរក្សាទុកនៅទីតាំងដែលទទួលបានបានការអនុញ្ញាត ហើយមិនស្ថិតក្រោមបញ្ជីទំនិញហាមឃាត់ និងបញ្ជីទំនិញដកចេញពីការឆ្លងកាត់
- បញ្ជាក់នូវអ្នកទទួលទំនិញ និងតម្រាយផ្លូវដែលបានអនុញ្ញាត
- អត្តសញ្ញាណរបស់សៀលត្រូវបានត្រួតពិនិត្យធៀបនឹងសៀលដែលបានអនុញ្ញាត និង
- ការកំណត់ចិរវេលាត្រូវបានចាប់ផ្តើម សម្រាប់ការបញ្ចេញទំនិញសម្រាប់ឆ្លងកាត់ដោយស្វ័យប្រវត្តិលើកលែងតែមន្ត្រីគយធ្វើអន្តរាគមន៍ដើម្បីធ្វើការត្រួតពិនិត្យ។

*ចំណាំ ÷ ពេលវេលាកំណត់នៃការបញ្ចេញសម្រាប់ឆ្លងកាត់ដោយស្វ័យប្រវត្តិត្រូវបានកំណត់និងជូនដំណឹងម្ចាស់ទំនិញក្នុងការអនុញ្ញាតនៃនីតិវិធីសាមញ្ញ។*

ប្រសិនបើ ធុរជនមិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់នីតិវិធីសាមញ្ញ ឬមានការសង្ស័យនៅក្នុងទិន្នន័យដែលបានបញ្ចូលក្នុងប្រតិវេទន៍ នោះប្រតិវេទន៍នឹងត្រូវបានបដិសេធដោយមន្ត្រីគយ ហើយប្រព័ន្ធនិងត្រូវជូនដំណឹងដល់ម្ចាស់ទំនិញ។

### ២.១. ទំនិញជាប់កម្រិតកំណត់

ពាក់ព័ន្ធនឹងទំនិញជាប់កម្រិតកំណត់ ប្រព័ន្ធ ACTS នឹងនាំប្រតិវេទន៍ដោយស្វ័យប្រវត្តិទៅកាន់ "ដំណើរការនីតិវិធីធម្មតា" ដោយបង្កើតសារបញ្ជាក់ថាជា "ទំនិញជាប់កម្រិតកំណត់"។ ប្រតិវេទន៍ និងទំនិញត្រូវបង្ហាញគយការិយាល័យចេញដំណើរ មន្ត្រីគយនឹងធ្វើការសម្រេចចិត្តថា ត្រូវពិនិត្យឯកសារបន្ថែម និង/ឬពិនិត្យទំនិញជារូបវន្ត និងថាតើត្រូវបញ្ចេញទំនិញសម្រាប់ឆ្លងកាត់ដែរឬទេ។

### ២.២. វិធានត្រួតពិនិត្យនៅការិយាល័យចេញដំណើរ

បន្ទាប់ពីការផ្ទៀងផ្ទាត់ និងការទទួលយកប្រតិវេទន៍ ការិយាល័យចេញដំណើរអាចរៀបចំការគ្រប់គ្រងហានិភ័យដោយបញ្ជាប្រព័ន្ធ ACTS ឱ្យណែនាំដល់មន្ត្រីគយយកចិត្តទុកដាក់លើប្រតិវេទន៍នោះ។ អាចមានហេតុផលខុសគ្នាជាច្រើនក្នុងការត្រួតពិនិត្យលើព័ត៌មានលម្អិតរបស់ប្រតិវេទន៍មុនពេលបញ្ចេញ។

ជាមួយនឹងពេលវេលាកំណត់ក្នុងការបញ្ចេញដោយស្វ័យប្រវត្តិក្នុងប្រតិបត្តិការ មន្ត្រីគយអាចទទួលបានព័ត៌មានលម្អិតនៃប្រតិវេទន៍ និង÷

- កត់ត្រាចូលក្នុងប្រព័ន្ធ ACTS អំពីការសម្រេចចិត្តមិនធ្វើការត្រួតពិនិត្យ
  - បញ្ឈប់ពេលវេលាកំណត់ និង
  - ប្រតិវេទន៍បន្តទៅត្រួតពិនិត្យនិមុត្តិធានា និងចុះបញ្ជិកាការប្រើប្រាស់ធៀបទៅនឹងបរិមាណយោងនិមុត្តិធានារបស់ម្ចាស់ទំនិញ ឬ
- សម្រេចចិត្តត្រួតពិនិត្យ
  - បញ្ឈប់ថិរវេលាកំណត់ក្នុងការបញ្ចេញទំនិញ និង
  - ជូនដំណឹងម្ចាស់ទំនិញអំពីការត្រួតពិនិត្យ។

#### ២.២.១. ការគ្រប់គ្រងការត្រួតពិនិត្យ

ជាទូទៅ មន្ត្រីគយសហការជាមួយម្ចាស់ទំនិញដែលជាប្រតិបត្តិករទទួលបានការអនុញ្ញាត (ATT) ក្នុងការត្រួតពិនិត្យនៅទីតាំងផ្ទុកទំនិញដែលបានកំណត់ ហើយក្នុងករណីខ្លះ មន្ត្រីគយអាចតម្រូវឱ្យទំនិញនោះត្រូវយកមកការិយាល័យចេញដំណើរសម្រាប់ធ្វើការត្រួតពិនិត្យ។

មន្ត្រីគយមានព័ត៌មានលម្អិតប្រតិវេទន៍ដែលបានមកពីប្រព័ន្ធ ACTS និងប្រើព័ត៌មានលម្អិតទាំងនេះដើម្បីពិនិត្យទំនិញ និងឯកសារអមពាក់ព័ន្ធដទៃទៀត។

មន្ត្រីគយបញ្ជាក់អំពីភាពចាំបាច់នានាក្នុងការកិបសៀលឡើងវិញលើភណ្ឌិកា ឬកុងតឺន័រ។

#### ២.២.២. លទ្ធផលត្រួតពិនិត្យ

លទ្ធផលត្រួតពិនិត្យ និងការបញ្ញូសម្រាប់ឆ្លងកាត់ត្រូវបានចាត់ចែងតាមមធ្យោបាយដូចគ្នានឹងទំនិញក្រោមនីតិវិធីធម្មតា ដូចបានពិពណ៌នានៅចំណុចទី១។ ករណីលើកលែង រួមមាន÷

- ជាអ្នកផ្ញើទំនិញដែលទទួលបានការអនុញ្ញាត ម្ចាស់ទំនិញអាចបោះពុម្ពប្រតិវេទន៍អមដំណើរឆ្លងកាត់ជាទម្រង់ក្រដាស និង
- ក្នុងករណីរកឃើញកំហុសធ្ងន់ធ្ងរ បន្ថែមទៅលើទោសទណ្ឌជាប្រចាំ ឋានៈជាប្រតិបត្តិករឆ្លងកាត់ទទួលបានការអនុញ្ញាតត្រូវតែពិនិត្យឡើងវិញ ដើម្បីវាយតម្លៃភាពសមស្របសម្រាប់ពេលអនាគត។

## ៣. ការឆ្លងកាត់

នៅពេលដែលដំណើរការឆ្លងកាត់ចាប់ផ្ដើម ការិយាល័យចេញដំណើរនឹងទទួលបានសារពីគ្រប់ការិយាល័យឆ្លងកាត់ និងការិយាល័យគម្រោងដ្ឋានតាមរយៈប្រព័ន្ធ ACTS។

ពេលវេលាដែលនឹងទទួលសារទាំងនេះត្រូវបានកំណត់ក្នុងប្រព័ន្ធ ACTS ដោយយោងតាមចិរវេលាធ្វើដំណើរ តម្រាយផ្លូវ និងគម្យដ្ឋាន។ (លើកលែងតែ មានហេតុការណ៍ពិសេសណាមួយធ្វើឱ្យប៉ះពាល់ដល់ចិរវេលាធ្វើដំណើរដែលបានកំណត់ដោយការិយាល័យចេញដំណើរក្នុងពេលឆ្លងកាត់)។

### ៣.១. ការឆ្លងកាត់ត្រឹមត្រូវ

ដំណើរការឆ្លងកាត់បានចាប់ផ្ដើមនីតិវិធី និងត្រូវបានបញ្ចប់ដូចការគ្រោងទុក តាមតម្រាយផ្លូវ និងក្នុងពេលវេលាកំណត់ ស្របតាមព័ត៌មានលម្អិតប្រតិវេទន៍ និងការអនុញ្ញាតដែលបានផ្ដល់ឱ្យ។

ក្នុងករណីនេះ ការិយាល័យចេញដំណើរទទួលសារពីប្រព័ន្ធ ACTS បញ្ជាក់អំពីវឌ្ឍនភាពនៃដំណើរការ÷

#### ៣.១.១. សារបញ្ជាក់ថាប្រតិបត្តិការបានឆ្លងកាត់ព្រំដែន (NCF)

បានទទួលពីការិយាល័យឆ្លងកាត់នីមួយៗដែលសារបញ្ជាក់ថានឹងមានប្រតិបត្តិការឆ្លងកាត់បានបញ្ជូនមក។

#### ៣.១.២. សារបញ្ជាក់ថាបានមកដល់ (ARRIVAL ADVICE)

បានទទួលពីការិយាល័យគម្យដ្ឋាន។

#### ៣.១.៣. លទ្ធផលត្រួតពិនិត្យ

លទ្ធផលត្រួតពិនិត្យដែលមិនមានកំហុសធ្ងន់បានទទួលពីការិយាល័យគម្យដ្ឋាន÷

- ដំណើរការឆ្លងកាត់ត្រូវបានបញ្ចប់
- និមុត្តិធានាត្រូវបានបញ្ចេញ (ឬក្នុងករណីនិមុត្តិធានាសម្រាប់ប្រតិបត្តិការច្រើនលើក បរិមាណយោងត្រូវបានបញ្ចេញវិញ) និង
- ម្ចាស់ទំនិញត្រូវបានជូនដំណឹងអំពីដំណើរការឆ្លងកាត់

### ៣.២. ដំណើរការឆ្លងកាត់មិនប្រក្រតី

#### ៣.២.១. ការបង្វែរ ឬការមិនឃើញទំនិញ

នៅផ្នែកទី៩ ពិពណ៌នាអំពីនីតិវិធីដោះស្រាយការបង្វែរនៃដំណើការឆ្លងកាត់ទៅការិយាល័យគម្យដ្ឋាន ឬតាមរយៈការិយាល័យឆ្លងកាត់ ដោយមិនស្ថិតក្នុងការអនុញ្ញាតដែលបានទទួល និងប្រតិវេទន៍ដែលបានទទួលយក។

#### ៣.២.២. ការសាកសួរ និងនីតិវិធីប្រមូលបំណុលគយមកវិញ

ទំនិញដែលមិនបានមកដល់ការិយាល័យគម្យដ្ឋានត្រូវចាប់ផ្តើមដំណើរការសាកសួរ ដែលជាដំបូងសាកសួរជាមួយការិយាល័យចេញដំណើរ និងម្ចាស់ទំនិញ។

ផ្នែកទី១១ “ការសាកសួរ និងការប្រមូលបំណុលគយមកវិញ” បរិយាយលម្អិតអំពីដំណើរការសម្រាប់ការសាកសួរថា ហេតុអ្វីបានជាដំណើរឆ្លងកាត់មិនបានចាប់ផ្តើមដូចការគ្រោងទុក និងហេតុអ្វីបានជាដំណើរការនេះមិនត្រូវបានបញ្ចប់ត្រឹមត្រូវ។

ឧបសម្ព័ន្ធអមមានទម្រង់សម្រាប់ការសាកសួរតាមដាន ទោះបីជា ការប្រមូលបំណុលមកវិញនៃពន្ធ អាករដែលបានបាត់បង់ពីម្ចាស់ទំនិញ ឬអ្នកធានា ប្រសិនបើការប្រមូលបំណុលនេះបង្ហាញថាមានភាពចាំបាច់។

# ឧបសម្ព័ន្ធនៃផ្នែកទី៦

## ឧបសម្ព័ន្ធ ៦ក÷ គោលការណ៍នៃការគ្រប់គ្រងហានិភ័យ

### សេចក្តីផ្តើម

### តើការគ្រប់គ្រងហានិភ័យគឺជាអ្វី?

- ការគ្រប់គ្រងហានិភ័យគឺជាដំណើរការមួយដែលមន្ត្រីគយប្រើដើម្បីត្រួតពិនិត្យ និងគ្រប់គ្រងហានិភ័យដែលផ្សារភ្ជាប់នឹងទំនិញពាណិជ្ជកម្មអន្តរជាតិ។
- ដំណើរការគ្រប់គ្រងហានិភ័យពាក់ព័ន្ធនឹង÷
    - ការកំណត់ហានិភ័យដែលអាចកើតឡើង
    - ការវិភាគហានិភ័យដែលទំនងនឹងកើតឡើង
    - ការវាយតម្លៃផលប៉ះពាល់របស់វា និង
    - ការកំណត់លំដាប់នៃអាទិភាព

### ការគ្រប់គ្រងហានិភ័យក្នុងការងារគយ

ការអនុវត្តនៃការគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាពអនុញ្ញាតឱ្យរដ្ឋបាលគយ÷

- ផ្តោតការយកចិត្តទុកដាក់លើផ្នែកដែលមានហានិភ័យខ្ពស់ និងប្រើប្រាស់ធនធានឱ្យកាន់តែមានប្រសិទ្ធភាព
- ស្វែងរកភាពមិនប្រក្រតី ទំនិញក្លែងក្លាយ ទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់
- អនុវត្តការត្រួតពិនិត្យបន្តិចបន្តួចលើក្រុមហ៊ុនដែលមានប្រវត្តិអនុលោមភាពល្អ
- សម្របសម្រួលដំណើរការទំនិញស្របច្បាប់។

### គោលការណ៍នៃការគ្រប់គ្រងហានិភ័យ

- មិនលម្អៀង និងមានគោលដៅ
- ពិចារណាលើគថភាពនយោបាយ ច្បាប់ និងសារពើពន្ធ
- ហានិភ័យតែងតែផ្លាស់ប្តូរជាប់ជានិច្ច
- ប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហានិភ័យស្វ័យប្រវត្តិ
- មានបណ្តាញប្រាស្រ័យទាក់ទងល្អ
- ត្រូវពិនិត្យតាមដាន និងវាយតម្លៃ

### តើអ្វីខ្លះជាសមាសភាពគន្លឹះនៃការគ្រប់គ្រងហានិភ័យ?

- ការអនុវត្តការគ្រប់គ្រងល្អ
- វិធីសាស្ត្រជាប្រព័ន្ធ និងសមហេតុផល
- ការសម្រេចចិត្តដែលបានកែលម្អ
- មធ្យោបាយបញ្ចៀស ឬកាត់បន្ថយការខាតបង់

- ដំណើរការនៃដំណាក់កាល ការកែលម្អបរិមាណធុរកិច្ចប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព
- ការគ្រប់គ្រងហានិភ័យជាវិធីសាស្ត្រជាប្រព័ន្ធ និងសមហេតុផលមួយនៃការកំណត់ ការវិភាគ ការដោះស្រាយ និងការត្រួតពិនិត្យតាមដានហានិភ័យពាក់ព័ន្ធនឹងដំណើរការ ឬសកម្មភាពណាមួយ។
- ការគ្រប់គ្រងហានិភ័យជាវិធីសាស្ត្រមួយដែលជួយឱ្យអ្នកគ្រប់គ្រងចេះប្រើប្រាស់ធនធានដែលមានឱ្យបានល្អបំផុត។

**ការគ្រប់គ្រងហានិភ័យតាមប្រព័ន្ធ ACTS**

គោលបំណងនៃប្រព័ន្ធឆ្លងកាត់គយស្វ័យប្រវត្តិ ដូចជាប្រព័ន្ធ ACTS គឺដើម្បីសម្របសម្រួលធុរកិច្ចស្របច្បាប់ ស្របពេលជាមួយនឹងការរក្សាការប្រុងប្រយ័ត្នប្រឆាំងនឹងការរត់ពន្ធ និងការបំពានច្បាប់ដទៃទៀត។ ការបន្លំឆ្លងកាត់អាចត្រូវបានរៀបចំឡើងដើម្បីគេចពន្ធគយ និងអាករ ឬអាចមានបំណងនាំចូលទំនិញដែលស្ថិតក្រោមការហាមឃាត់ ដូចជាគ្រឿងញៀន ឬអាវុធជាដើម។ បច្ចុប្បន្ន ដោយសារតែ បរិមាណខ្ពស់នៃទំនិញដំណើរការឆ្លងកាត់ព្រំដែន អាជ្ញាធរមិនអាចត្រួតពិនិត្យទំនិញគ្រប់រថយន្តបានឡើយ។ ការគ្រប់គ្រងហានិភ័យអនុញ្ញាតឱ្យមន្ត្រីគយសម្របសម្រួលដំណើរការនៃធុរកិច្ចស្របច្បាប់ និងផ្តោតការខិតខំប្រឹងប្រែងស្វែងរកការបន្លំឆ្លងកាត់។ ចំណុចស្នូលនៃដំណើរការគ្រប់គ្រងហានិភ័យជាទស្សនទាន នៃប្រតិបត្តិករឆ្លងទទួលបានការអនុញ្ញាត (ATT) ដែលស្រដៀងគ្នាទៅនឹង ប្រតិបត្តិករសេដ្ឋកិច្ចទទួលបានការអនុញ្ញាត (AEO) ត្រូវបានផ្តល់នូវការអនុគ្រោះក្រោមការត្រួតពិនិត្យផ្ទៃក្នុងដ៏តឹងរឹងនៃការអនុវត្តពាណិជ្ជកម្ម។ ប្រតិបត្តិការពាណិជ្ជកម្មរបស់ ATT តែងតែស្ថិតក្រោមការត្រួតពិនិត្យរបស់គយដោយមិនបាច់ជូនដំណឹងមុន ឬការធ្វើសវនកម្មក្រោយពីបញ្ចេញទំនិញ (PCA) ដើម្បីធានាថារបបឆ្លងកាត់ត្រូវបានអនុវត្តតាម។ លើសពីនេះទៀត អាជ្ញាធរគយនឹងរក្សាទុកកំណត់ត្រានៃប្រតិបត្តិការកន្លងមកដែលធុរកិច្ចបានបញ្ជូនមកសម្រាប់ការនាំចូល នាំចេញ ឬការឆ្លងកាត់។ ផ្អែកលើលទ្ធផលនៃវិហ្វរនីតិវិធីនៃប្រតិវេទន៍កន្លងមកទាំងនេះ មន្ត្រីគយនឹងបង្កើតប្រវត្តិកំណត់អត្តសញ្ញាណទំនិញ ប្រទេសកំណើត និងធុរជនដែលមានហានិភ័យខ្ពស់ រួមទាំងតម្រុយផ្សេងៗទៀតផងដែរ។ មន្ត្រីគយប្រើតម្រុយហានិភ័យទាំងនេះ ដើម្បីកំណត់គោលដៅត្រួតពិនិត្យប្រតិវេទន៍ និងការពិនិត្យរូបវន្តទំនិញ។ លទ្ធផលនៃការកំណត់គោលដៅនេះនឹងបញ្ចូលទៅក្នុងប្រព័ន្ធដើម្បីរក្សាបច្ចុប្បន្នភាពប្រវត្តិហានិភ័យ។

កម្មវិធីគ្រប់គ្រងហានិភ័យដែលបានរចនាឡើងមួយនេះ នឹងផ្តល់ឱ្យមន្ត្រីគយនូវឱកាសកាន់ប្រសើរឡើងក្នុងការស្វែងរកប្រតិបត្តិការក្លែងបន្លំ។ ព័ត៌មានលម្អិតនៃការគ្រប់គ្រងហានិភ័យមានរៀបចំដូចខាងក្រោម។

**មានវិធីសាស្ត្រពីរនៃការគ្រប់គ្រងហានិភ័យតាមប្រព័ន្ធ ACTS**

ប្រព័ន្ធ ACTS ផ្តល់នូវមធ្យោបាយពីរសម្រាប់ចាត់ចែងក្នុងការគ្រប់គ្រងហានិភ័យ។ ក្នុងប្រព័ន្ធ ACTS មានការគ្រប់គ្រងហានិភ័យ នៃទំនិញឆ្លងកាត់។ ព័ត៌មានលម្អិតនៃយន្តការនេះមានដូចខាងក្រោម។ ក្រុមការងារអនុវត្តប្រព័ន្ធ ACTS នឹងផ្តល់សៀវភៅណែនាំ និងឯកសារបណ្តុះបណ្តាលស្តីពីរបៀប ប្រតិបត្តិប្រព័ន្ធគ្រប់គ្រងហានិភ័យក្នុងប្រព័ន្ធ ACTS។ នេះជាវិធីសាស្ត្រដែលបានណែនាំសម្រាប់ដំណាក់កាលអនុវត្តដំបូងនៃប្រព័ន្ធ ACTS។

ម្យ៉ាងវិញទៀត សម្រាប់រយៈពេលវែង ប្រទេសសមាជិកអាស៊ានណា ដែលមានបំណងចង់ប្រើប្រព័ន្ធគ្រប់គ្រងហានិភ័យសម្រាប់ប្រទេសរបស់ខ្លួន។ ក្នុងករណីនេះ ក្រុមការងារអនុវត្តប្រព័ន្ធ ACTS នឹងផ្តល់ព័ត៌មានស្តីពីរបៀបតភ្ជាប់ប្រព័ន្ធ (Interfaces) និងសមាសភាពសុវត្ថិភាពប្រព័ន្ធសំខាន់ៗ។

**មូលហេតុបន្លំឆ្លងកាត់**

- ដើម្បីគេចវេសការបង់ពន្ធអាករ
- ដើម្បីគេចទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់
- ដើម្បីទទួលបានអត្ថប្រយោជន៍លើទីផ្សារដោយអយុត្តិធម៌។

**វិធីសាស្ត្របន្លំឆ្លងកាត់**

- បង្វែរទំនិញឆ្លងកាត់ចូលក្នុងទីផ្សារក្នុងស្រុក
- ប្រើប្រាស់ឯកសារជំនួស ឬឯកសារក្លែងក្លាយ
- ក្លែងបន្លំនិមុត្តិធានាឆ្លងកាត់
- ការបរិយាយមិនពិតនៃទំនិញឆ្លងកាត់
- ការកំណត់តម្លៃទាបនៃទំនិញឆ្លងកាត់។

**តម្រុយបន្លំឆ្លងកាត់**

- មានការប៉ះពាល់សៀលដោយគ្មានការអនុញ្ញាត
- ការជ្រើសរើសតម្រាយផ្លូវឆ្លងកាត់មិនប្រក្រតី ឬមិនសមហេតុផល
- ការផ្លាស់ប្តូរទំនិញដោយមិនបានគ្រោងទុកពីមធ្យោបាយដឹកជញ្ជូនមួយទៅមធ្យោបាយដឹកជញ្ជូនមួយទៀតអំឡុងពេលឆ្លងកាត់
- ឯកសារមិនមានសង្គតិភាព ឬមិនពេញលេញ
- ការពន្យាពេលមិនសមហេតុផលនៃការដឹកជញ្ជូនទំនិញពីចំណុចមួយទៅចំណុចមួយទៀត
- រាយការណ៍អំពីគ្រោះថ្នាក់ ឬឧប្បត្តិហេតុដោយបង្ហាញថា ទំនិញត្រូវបានខូចខាត ឬបាត់បង់ ដោយគ្មានភស្តុតាងបញ្ជាក់ច្បាស់លាស់
- ការផ្លាស់ប្តូរតម្រាយផ្លូវដោយមិនបានគ្រោងទុក និងគ្មានមូលហេតុគ្រប់គ្រាន់
- គ្មានសង្គតិភាពជាមួយនឹងទម្ងន់ បរិមាណ ភណ្ឌិកា ឬកុងតឺន័រ
- គ្មានប្រវត្តិអនុលោមតាមច្បាប់កន្លងមក
- ព័ត៌មានដែលបានទទួលពីសាធារណជន / ធុរកិច្ច
- ព័ត៌មាន (ចារកម្ម) ដែលបានទទួលពីមន្ត្រីគយ ទីភ្នាក់ងារតាមព្រំដែន/ ទីភ្នាក់ងារអនុវត្តច្បាប់ផ្សេងៗ
- រថយន្តដឹកទំនិញមិនមានអាជ្ញាបណ្ណប្រើប្រាស់ប្រព័ន្ធ ACTS
- ប្រើប្រាស់ឧបករណ៍រាវរក ដូចជា ម៉ាស៊ីនស្កេនកាំរស្មីអ៊ិច។

**ភារកិច្ចរបស់មន្ត្រីគយក្នុងការទប់ស្កាត់ការក្លែងបន្លំឆ្លងកាត់**

មន្ត្រីគយត្រូវមានចំណេះដឹងបច្ចេកទេស បទពិសោធន៍ និងការបណ្តុះបណ្តាលចាំបាច់នានាដូចជា÷

- ច្បាប់គយថ្នាក់ជាតិ និងនីតិវិធីឆ្លងកាត់គយអាស៊ាន (ACTS)
- អនុសញ្ញាអន្តរជាតិ ដូចជា អនុសញ្ញាក្រុងក្យូតូ ក្របខ័ណ្ឌ WCO SAFE នៃស្តង់ដារ និងកិច្ចព្រមព្រៀងថ្នាក់តំបន់/ទ្វេភាគីដទៃទៀត ស្តីពីការឆ្លងកាត់គយ
- លក្ខខណ្ឌទីផ្សារប្រទេសទទួល
- យល់ដឹងអំពីករណីការបន្លំឆ្លងកាត់ និងវិធីសាស្ត្រប្រតិបត្តិការពីមុនៗ

**តើនរណាជាអ្នកប្រើការគ្រប់គ្រងហានិភ័យ?**

- ការអនុវត្តការគ្រប់គ្រងហានិភ័យត្រូវបានប្រើយ៉ាងទូលំទូលាយទាំងក្នុងវិស័យឯកជន និងសាធារណៈក្នុងការគ្របដណ្តប់សកម្មភាព ឬប្រតិបត្តិការជាច្រើន ដូចជា ក្នុងការធានារ៉ាប់រងជាដើម
- ការគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាព ជាមួយជំនាញដែលគេទទួលស្គាល់ និងឱ្យតម្លៃ
- ការគ្រប់គ្រងហានិភ័យគឺជាផ្នែកមួយដ៏សំខាន់នៃការធ្វើផែនការធុរកិច្ច។

**តើប្រើការគ្រប់គ្រងហានិភ័យដោយរបៀបណា?**

មានដំណាក់កាលគ្រឹះចំនួន ៧ ក្នុងដំណើរការគ្រប់គ្រងហានិភ័យ÷

1. បង្កើតបរិបទ
2. កំណត់ហានិភ័យ
3. វិភាគហានិភ័យ
4. វាយតម្លៃហានិភ័យ
5. ដោះស្រាយហានិភ័យ

*ចំណាំ÷ ហានិភ័យជាថាមវន្ត និងអាចផ្លាស់ប្តូរជាប់ជានិច្ច ដូចនេះដំណើរការគ្រប់គ្រងក៏ត្រូវបន្តធ្វើបច្ចុប្បន្នភាព។*

6. ត្រួតពិនិត្យតាមដាន និងពិនិត្យឡើងវិញ
7. ប្រាស្រ័យទាក់ទង និងប្រឹក្សាយោបល់ជានិច្ច

**ដំណើរការគ្រប់គ្រងហានិភ័យ**

1. បង្កើតបរិបទ

បរិបទយុទ្ធសាស្ត្រ និងស្ថាប័នដែលការគ្រប់គ្រងហានិភ័យនឹងត្រូវអនុវត្ត។ ឧទាហរណ៍ ប្រភេទធុរកិច្ច ហានិភ័យដែលផ្សារភ្ជាប់ក្នុងធុរកិច្ចនោះនិងការកំណត់អាទិភាព និងការប្រាស្រ័យទាក់ទងនិងប្រឹក្សាយោបល់។

2. កំណត់ហានិភ័យ

- កំណត់ប្រភេទហានិភ័យផ្សេងៗ ឧ. ហានិភ័យយុទ្ធសាស្ត្រចំពោះគោលបំណងធុរកិច្ច

- កំណត់ភាគីពាក់ព័ន្ធ រួមមាន អ្នកណានឹងចូលរួម ឬអ្នកទទួលរងផលប៉ះពាល់?
- ព្រឹត្តិការណ៍កន្លងមក និងការវិវឌ្ឍនាពេលអនាគត

3. ការវិភាគហានិភ័យ
   - តើព្រឹត្តិការណ៍ហានិភ័យទំនងនឹងកើតឡើងតាមរបៀបណា ដូចជា ភាពប្រហាក់ប្រហែល និងភាពញឹកញាប់?
   - តើមានផលប៉ះពាល់ ការចំណាយ និង/ឬផលវិបាកនៃព្រឹត្តិការណ៍អ្វីខ្លះ (ផលប៉ះពាល់អាចជាសេដ្ឋកិច្ច នយោបាយ សង្គម)?
   - ត្រួតពិនិត្យតាមដាន និងពិនិត្យមើលឡើងវិញ
   - ប្រាស្រ័យទាក់ទង និងប្រឹក្សាយោបល់
4. វាយតម្លៃហានិភ័យ
   - ចាត់លំដាប់ថ្នាក់ហានិភ័យដោយយោងតាមអាទិភាពនៃការគ្រប់គ្រង តាមប្រភេទហានិភ័យ និងវាយ-តម្លៃតាមភវនីយភាព និងលទ្ធភាពនៃតម្លៃ ឬផលវិបាក។
   - កំណត់កម្រិតហានិភ័យដែលផ្សារភ្ជាប់មកជាមួយ
5. ដោះស្រាយហានិភ័យ
   - បង្កើត និងអនុវត្តផែនការគ្រប់គ្រងហានិភ័យជាមួយនឹងវិធានការការពារជាក់លាក់ដើម្បីដោះស្រាយហានិភ័យដែលបានកំណត់។
   - ដោយពិចារណាលើ÷
     - អាទិភាព ទាំងកម្រិតយុទ្ធសាស្ត្រ និងកម្រិតប្រតិបត្តិ
     - ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងបច្ចេកទេស
     - ការទទួលយកហានិភ័យ (ហានិភ័យកម្រិតទាប)
   - ផែនការគ្រប់គ្រងហានិភ័យត្រូវពិពណ៌នាអំពីហេតុផលក្នុងការជ្រើសរើសហានិភ័យ និងវិធានការការពារ
   - ត្រូវកត់ត្រាការទទួលខុសត្រូវ ការត្រួតពិនិត្យតាមដាន ឬដំណើរការវាយតម្លៃដែលបានបែងចែក និងការប៉ាន់ប្រមាណហានិភ័យដែលនៅសេសសល់ផងដែរ។
6. ការត្រួតពិនិត្យតាមដាន
   - អ្នកគ្រប់គ្រងហានិភ័យត្រូវត្រួតពិនិត្យតាមដានសកម្មភាព និងដំណើរការនានាដើម្បីកំណត់ភាពត្រឹម-ត្រូវនៃផែនការគ្រោងទុកដែលបានរៀបចំឡើង និងប្រសិទ្ធភាពនៃវិធានការដែលបានអនុវត្តក្នុងការដោះស្រាយហានិភ័យនេះ
   - ក្នុងការកំណត់ហានិភ័យ ការកំណត់អាទិភាពហានិភ័យ ការដោះស្រាយហានិភ័យ និងការសន្ទត់ ត្រូវបានធ្វើឡើង ប៉ុន្តែអាចកែប្រែបាន (ឧ. បរិយាកាសធុរកិច្ច ទម្រង់ធុរកិច្ច គោលនយោបាយរដ្ឋាភិបាល)

7. ការពិនិត្យឡើងវិញ

- គោលនយោបាយគ្រប់គ្រងហានិភ័យ ការសម្រេចចិត្ត និងផែនការត្រូវធ្វើការកែប្រែជាប្រចាំ
- ប្រាស្រ័យទាក់ទង និងប្រឹក្សាយោបល់

ដូចនេះ ដំណើរការគ្រប់គ្រងហានិភ័យគួរអនុវត្តតាមវដ្តបន្តបន្ទាប់នៃដំណាក់កាលទាំងប្រាំពីរនេះ។

# ផ្នែកទី៧÷ ការិយាល័យគយឆ្លងកាត់

ការិយាល័យគយឆ្លងកាត់ទទួលកាលបរិច្ឆេទនៃដំណើរការឆ្លងកាត់ពីប្រព័ន្ធ ACTS ក្នុងទម្រង់ជាសារបញ្ជាក់ថានឹងមានប្រតិបត្តិការឆ្លងកាត់ (ATR)។

## ១. បុរេត្រួតពិនិត្យ

បុរេត្រួតពិនិត្យអនុញ្ញាតឱ្យមានការត្រួតពិនិត្យមុនការមកដល់ នៃការឆ្លងកាត់ ដោយផ្អែកលើការវិភាគហានិភ័យ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀត។

- ការសម្រេចចិត្តត្រូវបានចុះបញ្ជីថាតើ អនុញ្ញាតឱ្យឆ្លងកាត់ដែរឬទេ។

ការត្រួតពិនិត្យរូបវន្តទំនិញជាប្រចាំនៅការិយាល័យគយឆ្លងកាត់ត្រូវកាត់បន្ថយ។ ការវិភាគហានិភ័យតាមប្រព័ន្ធ ACTS នឹងណែនាំមន្ត្រីគយថាតើ ត្រូវពិនិត្យឯកសារបន្ថែម ឬត្រួតពិនិត្យរូបវន្តទំនិញ។




ម្ចាស់ទំនិញ ឬក្រុមហ៊ុនដឹកជញ្ជូន ត្រូវជូនដំណឹងមន្ត្រីគយថា រថយន្ត និងដំណើរការឆ្លងកាត់បានមកដល់ ហើយបង្ហាញទំនិញ និងប្រតិវេទន៍អមដំណើរឆ្លងកាត់ (TAD) ដល់មន្ត្រីគយ។

- មន្ត្រីគយយកលេខយោងប្រតិវេទន៍ឆ្លងកាត់ (ARN) ពី TAD បញ្ចូលក្នុងប្រព័ន្ធ ACTS តាមរយៈម៉ាស៊ីនស្កែនបារកូដ ឬបញ្ចូលដោយដៃ។
- យោងទៅលើសារបញ្ជាក់ថានឹងមានប្រតិបត្តិការឆ្លងកាត់ (ATR)។

សៀលត្រូវបានត្រួតពិនិត្យដើម្បីធានាថា សៀលនៅកិបជាប់ និងយោងទៅលើលេខសៀលលើប្រតិវេទន៍អមដំណើរឆ្លងកាត់ (TAD) និងលើសារបញ្ជាក់ថានឹងមានប្រតិបត្តិការឆ្លងកាត់ (ATR)។

## ២. ស្ថានភាពនិងការទទួលស្គាល់ដំណើរការឆ្លងកាត់

ប្រព័ន្ធ ACTS ទាញយកព័ត៌មានប្រតិបត្តិការឆ្លងកាត់ និងឆ្លើយតបទៅនឹងស្ថានភាពនៃប្រតិបត្តិការឆ្លងកាត់ ព្រមទាំងអនុវត្តការត្រួតពិនិត្យ រួមមាន÷

- ប្រតិបត្តិការឆ្លងកាត់ត្រូវបានដឹង នៅការិយាល័យចេញដំណើរ និងតម្រាយផ្លូវ។
- ប្រតិបត្តិការឆ្លងកាត់ត្រូវបានដឹង នៅការិយាល័យចេញដំណើរ ប៉ុន្តែមិនស្របគ្នាជាមួយនឹងការបង្ហាញទំនិញនៅការិយាល័យឆ្លងកាត់ (ឧ. ដំណើរការឆ្លងកាត់បានមកដល់ការិយាល័យគម្យដ្ឋានរួចហើយ)។
- ការបង្វែរក្នុងស្រុកឬអន្តរជាតិ (ឧ. ដំណើរការឆ្លងកាត់មិនបានប្រកាសនៅការិយាល័យឆ្លងកាត់ ឬប្រទេសឆ្លងកាត់)។

### ២.១. គ្មានសារបញ្ជាក់ថានឹងមានប្រតិបត្តិការឆ្លងកាត់ (ATR)

ប្រសិនបើដំណើរការឆ្លងកាត់មិនស្របគ្នាទៅនឹងសារបញ្ជាក់ថានឹងមានប្រតិបត្តិការឆ្លងកាត់ (ATR) (ការស្នើសុំ ATR នឹងត្រូវធ្វើឡើងនៅការិយាល័យចេញដំណើរតាមរយៈប្រព័ន្ធ ACTS សម្រាប់ព័ត៌មានប្រតិវេទន៍ដែលនឹងត្រូវបញ្ជូនជាសារបញ្ជាក់ថានឹងមានប្រតិបត្តិការឆ្លងកាត់ (ATR)។

ក្រោយពីបានទទួលសារបញ្ជាក់ថានឹងមានប្រតិបត្តិការឆ្លងកាត់ (ATR) និងសារព្រមានបន្ថែមផ្សេងទៀតដែលបង្កើតឡើងដោយប្រព័ន្ធ ACTS មន្ត្រីគយសម្រេចចិត្តលើវិធានការណាមួយបន្ថែមទៀត។

ក្នុងករណី ដំណើរការឆ្លងកាត់បានបង្វែរពីតម្រាយផ្លូវឆ្លងកាត់ដែលបានអនុញ្ញាតពីខាងដើម ឬផ្លាស់ប្តូរការិយាល័យគម្មដ្ឋាន ឬទទួលទំនិញ សូមមើលព័ត៌មានលម្អិតនៃនីតិវិធីប្រតិបត្តិការក្នុងផ្នែកទី៩÷ ការបង្វែរ ឬការមិនប្រគល់ទំនិញ។

## ៣. ការសម្រេចចិត្តត្រួតពិនិត្យដំណើរការឆ្លងកាត់

មន្ត្រីគយចាត់វិធានការសមស្របដើម្បីត្រួតពិនិត្យ ឬមិនត្រួតពិនិត្យទំនិញ ដោយរួមបញ្ចូលការព្រមានមុនការត្រួតពិនិត្យ ឬការអង្កេតលក្ខខណ្ឌទំនិញ ឬការវេចខ្ចប់ ឬបញ្ហាបារម្ភផ្សេងទៀតដូចបានបង្ហាញនៅការិយាល័យឆ្លងកាត់។ ប្រព័ន្ធអាចព្យាករណ៍ការសម្រេចចិត្តលើការត្រួតពិនិត្យនៅការិយាល័យឆ្លងកាត់។ ការសម្រេចចិត្តលើការត្រួតពិនិត្យទាំងនេះអាច÷

ក) អនុញ្ញាតឱ្យឆ្លងកាត់ព្រំដែន

ខ) បញ្ជូនដំណើរការឆ្លងកាត់ត្រលប់ទៅវិញ ឬ

គ) បញ្ឈប់ដំណើរការឆ្លងកាត់។

*ចំណាំ÷ ការបញ្ឈប់ដំណើរការឆ្លងកាត់មានន័យថា ការិយាល័យឆ្លងកាត់នឹងក្លាយជាការិយាល័យគម្មដ្ឋានដែលទំនិញអាចត្រូវបានត្រួតពិនិត្យ។ ក្រោយមក ប្រសិនបើទំនិញអនុញ្ញាតឱ្យបន្តនីតិវិធី ចាំបាច់ត្រូវមានប្រតិវេទន៍ថ្មីមួយទៀត។*

រាល់ការសម្រេចចិត្តលើការត្រួតពិនិត្យទាំងអស់ត្រូវបានកត់ត្រាចូលទៅក្នុងប្រព័ន្ធ ACTS។ ឧទាហរណ៍ ប្រសិនបើ ទំនិញត្រូវបានត្រួតពិនិត្យមុនពេលចុះបញ្ជីឆ្លងកាត់ព្រំដែននៅការិយាល័យចេញដំណើរ ឬប្រសិនបើដំណើរការឆ្លងកាត់មិនមានសុពលភាព ហើយត្រូវបញ្ឈប់ដំណើរការ ឬបញ្ជូនត្រលប់ទៅវិញ។

### ៣.១. សារបញ្ជាក់ថាប្រតិបត្តិការបានឆ្លងកាត់ព្រំដែន (NCF)

ប្រសិនបើ ការត្រួតពិនិត្យដោយមន្ត្រីគយ ឬដោយការឆ្លងកាត់ដែលបានទទួលការអនុញ្ញាតជាមុន ដំណើរការឆ្លងកាត់ត្រូវបានអនុញ្ញាតឱ្យឆ្លងកាត់ព្រំដែន ហើយការិយាល័យចេញដំណើរបានទទួលដំណឹងពីប្រព័ន្ធ ACTS តាមរយៈសារបញ្ជាក់ថាប្រតិបត្តិការបានឆ្លងកាត់ព្រំដែន (NCF)។

# ផ្នែកទី៨៖ ការិយាល័យគម្រូដ្ឋាន

បន្ទាប់ពីការបញ្ចេញទំនិញសម្រាប់ឆ្លងកាត់ ការិយាល័យចេញដំណើរបញ្ជូនសារបញ្ជាក់ថានឹងមានប្រតិបត្តិ-ការឆ្លងកាត់មកដល់ (AAR) តាមរយៈប្រព័ន្ធ ACTS ទៅកាន់ការិយាល័យគម្យដ្ឋាន។

ការិយាល័យគម្យដ្ឋានដឹងថា នឹងមានដំណើរការឆ្លងកាត់មកដល់នៅការិយាល័យនោះតាមរយៈការកំណត់កាលបរិច្ឆេទក្នុងប្រតិវេទន៍ឆ្លងកាត់ដែលបានអនុញ្ញាត។

## ១. ការត្រួតពិនិត្យមុនការមកដល់

បន្ទាប់ពីទទួលបានសារបញ្ជាក់ថានឹងមានប្រតិបត្តិការឆ្លងកាត់មកដល់ (AAR) ការិយាល័យគម្យដ្ឋានអនុវត្តការវិភាគហានិភ័យក្នុងប្រព័ន្ធដោយស្វ័យប្រវត្តិ និងរក្សាទុកជាមុននៃព័ត៌មានបរិយាយដំណើរការឆ្លងកាត់។

### ១.១. នីតិវិធីធម្មតា ឬនីតិវិធីសាមញ្ញ

ប្រតិបត្តិករឆ្លងកាត់ទទួលបានការអនុញ្ញាត (ATT) ទទួលបានអត្ថប្រយោជន៍ពីនីតិវិធីសាមញ្ញបន្ថែមនៅការិយាល័យគម្យដ្ឋាន ទោះបីជា នីតិវិធីសាមញ្ញទទួលបានការអនុញ្ញាតជាក់លាក់អាចខុសគ្នាពីការអនុញ្ញាតដែលបានចេញឱ្យ ATT ប្រភេទទំនិញ តម្រាយផ្លូវឆ្លងកាត់ អ្នកទទួលទំនិញ ឬគម្យដ្ឋាន។

*ចំណាំ៖ ដូចគ្នាផងដែរ ការសម្រេចចិត្តគ្រប់គ្រងហានិភ័យដែលបានធ្វើឡើងលើការត្រួតពិនិត្យមុនការមកដល់អាចបដិសេធលើការពិចារណាពិសេសណាមួយ ដែលជាទូទៅត្រូវបានអនុញ្ញាត និងជំនួសដោយវិធានការត្រួតពិនិត្យជាក់លាក់ណាមួយទៀត។*

- បន្ទាប់ពី AAR មកដល់ ជាមួយនឹងការកំណត់អត្តសញ្ញាណអ្នកទទួលទំនិញ ដែលបានអនុញ្ញាត ការិយាល័យគម្យដ្ឋាននឹងដឹងថាតើទំនិញ ដែលកំពុងដំណើរការស្ថិតក្រោមនីតិវិធីសាមញ្ញ និងបានបង្ហាញនៅទីតាំងអ្នកទទួលទំនិញដែលបានអនុញ្ញាតដែរឬទេ។

## ២. ការមកដល់ក្រោមនីតិវិធីធម្មតា

អ្នកទទួលទំនិញ ឬអ្នកតំណាងម្ចាស់ទំនិញជូនដំណឹងអំពីការមកដល់នៃទំនិញ។

- ប្រតិវេទន៍អមដំណើរឆ្លងកាត់ (TAD) មកដល់ជាមួយអ្នកបើកបររថយន្តដឹកជញ្ជូន។

*ចំណាំ៖ ក្រោមនីតិវិធីធម្មតា ទីតាំងដាក់ទំនិញអាចត្រូវបានត្រួតពិនិត្យនៅការិយាល័យគម្យដ្ឋាន។*

លេខយោងប្រតិវេទន៍ឆ្លងកាត់គយអាស៊ាន (ARN) ត្រូវបានទាញចេញពី TAD និងដាក់បញ្ចូលទៅក្នុងប្រព័ន្ធ ACTS។ ប្រព័ន្ធ ACTS ស្វែងរកព័ត៌មានដំណើរការឆ្លងកាត់ដោយយោងតាមរយៈ ARN។

### ២.១. ការមកដល់ត្រឹមត្រូវតាមលក្ខខណ្ឌ

ប្រសិនបើ ការមកដល់ត្រឹមត្រូវតាមលក្ខខណ្ឌ ការផ្ទៀងផ្ទាត់ជាមួយនឹងសារបញ្ជាក់ថានឹងមានប្រតិបត្តិការឆ្លងកាត់ត្រូវបានស្វែងរក និង៖

- ការមកដល់ត្រូវបានកត់ត្រាចូលក្នុងប្រព័ន្ធ ACTS និង

- ប្រព័ន្ធ ACTS ជូនដំណឹងការិយាល័យចេញដំណើរថា ការមកដល់ត្រូវបានទទួលយក។

## ២.២. ការមកដល់មិនត្រឹមត្រូវតាមលក្ខខណ្ឌ

ប្រសិនបើ ការមកដល់មិនត្រឹមត្រូវតាមលក្ខខណ្ឌ ដោយសារតែដំណើរការឆ្លងកាត់÷

- មិនមកដល់ ដោយសារការបង្វែរ ឬកាលៈទេសៈពិសេសផ្សេងទៀត ជាមួយនឹងភាពមិនស្របគ្នានៃសារបញ្ជាក់ថានឹងមានប្រតិបត្តិការឆ្លងកាត់មកដល់ (AAR) ក្នុងប្រព័ន្ធ ACTS÷
    - ការិយាល័យគម្យដ្ឋានស្នើសុំ AAR ពីការិយាល័យចេញដំណើរ ផ្តល់ព័ត៌មានអំពីដំណើរការឆ្លងកាត់
    - ប្រព័ន្ធ ACTS ផ្ញើទៅការិយាល័យគម្យដ្ឋានវិញដោយស្វ័យប្រវត្តិអំពីព័ត៌មាន និង
    - ប្រសិនបើដំណើរការឆ្លងកាត់អាចផ្ទៀងផ្ទាត់ដំណើរការឱ្យបន្តក្រោមនីតិវិធីធម្មតា។
- សម្រាប់ហេតុផលផ្សេងទៀតដែលមិនអាចទទួលយក ឧ. ទំនិញហាមឃាត់ ឬទំនិញជាប់កម្រិតកំណត់ដែលមិនបានអនុញ្ញាតសម្រាប់ប្រទេសគម្យដ្ឋាន ឬដំណើរការឆ្លងកាត់មិនអាចកំណត់អត្តសញ្ញាណក្នុងប្រព័ន្ធ ACTS បាន÷
    - ប្រព័ន្ធ ACTS បដិសេធការមកដល់ និង
    - ធុរជនត្រូវបានជូនដំណឹងថា ការបង្ហាញទំនិញមិនត្រឹមត្រូវតាមលក្ខខណ្ឌ។

## ២.៣. ការសម្រេចចិត្តត្រួតពិនិត្យ

ការវិភាគហានិភ័យ ត្រូវបានបញ្ចប់ក្នុងដំណាក់កាលនេះដើម្បីជួយដល់មន្ត្រីគយក្នុងការសម្រេចចិត្តលើការត្រួតពិនិត្យទំនិញ។ មន្ត្រីគយត្រូវធ្វើការពិចារណាលើកត្តាហានិភ័យថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន នៅពេលវិភាគហានិភ័យនៅការិយាល័យគម្យដ្ឋាន។

- ប្រព័ន្ធ ACTS កត់ត្រាលទ្ធផលនៃការវិភាគហានិភ័យ
- ទោះបីជា ការវិភាគហានិភ័យជាដំណើរការស្វ័យប្រវត្តិក៏ដោយ ប៉ុន្តែការសម្រេចចិត្តចុងក្រោយក្នុងការត្រួតពិនិត្យទំនិញអាចស្ថិតនៅលើការសម្រេចចិត្តរបស់មន្ត្រីគយ។

ប្រសិនបើ ការវិភាគបានស្នើឡើងក្នុងការចាត់វិធានការនៅការិយាល័យគម្យដ្ឋាន ប៉ុន្តែបើមន្ត្រីគយសម្រេចចិត្តមិនធ្វើការត្រួតពិនិត្យ ដូចនេះប្រព័ន្ធ ACTS តម្រូវឱ្យមន្ត្រីគយបញ្ជាក់អំពីមូលហេតុដែលមិនសម្រេចចិត្តធ្វើការត្រួតពិនិត្យ។

### ២.៣.១. ប្រសិនបើមិនមានការត្រួតពិនិត្យ

ទំនិញត្រូវបានបញ្ចេញ សម្រាប់របបគយផ្សេង ឬសកម្មភាពនានាផ្សេងទៀត (ឧ.ការរក្សាទុកបណ្តោះអាសន្ន នីតិវិធីនាំចូល - ល-) ហើយប្រព័ន្ធ ACTS ជូនដំណឹងម្ចាស់ទំនិញ។

- លទ្ធផលត្រួតពិនិត្យ “មិនមានកំហុសឆ្គង” ត្រូវបានជូនដំណឹងការិយាល័យចេញដំណើរតាមរយៈប្រព័ន្ធ ACTS ជាមួយនឹងព័ត៌មានលម្អិតអំពីការផ្ទេរទំនិញ និង/ ឬឧប្បត្តិហេតុ ប្រសិនបានកើតឡើងអំឡុងពេលចរាចរណ៍ទំនិញ។

### ២.៣.២. ការត្រួតពិនិត្យក្រោយបានអនុវត្ត

ប្រសិនបើ ការិយាល័យគម្រូដ្ឋានសម្រេចចិត្តធ្វើការត្រួតពិនិត្យ ការត្រួតពិនិត្យត្រូវអនុវត្តនៅការិយាល័យគម្រូដ្ឋានដើម្បីផ្ទៀងផ្ទាត់សៀល ប្រតិវេទន៍ ឬទំនិញ (ឬទាំងអស់) ដោយប្រើព័ត៌មានបរិយាយដំណើរការឆ្លងកាត់ដែលបានបោះពុម្ពជាទម្រង់ក្រដាស ផ្អែកលើលេខយោងប្រតិវេទន៍ឆ្លងកាត់គយអាស៊ាន (ARN)។

- មន្ត្រីគយនៅការិយាល័យគម្រូដ្ឋានកត់ត្រាលទ្ធផលនៃការត្រួតពិនិត្យបន្ទាប់ពីការត្រួតពិនិត្យទំនិញ
- នៅពេលគ្មានភាពមិនប្រក្រតី ឬនៅពេលមន្ត្រីគយសម្រេចចិត្តមិនរង់ចាំដំណោះស្រាយភាពមិនប្រក្រតីនៅការិយាល័យចេញដំណើរ មន្ត្រីគយត្រូវកត់ត្រាក្នុងប្រព័ន្ធ ACTS ដោយបញ្ជាក់ថា ទំនិញរួចរាល់សម្រាប់នីតិវិធី/ សកម្មភាពបន្ទាប់ (ឧ. ការរក្សាទុកបណ្តោះអាសន្ន នីតិវិធីនាំចូលជាដើម)
- ប្រព័ន្ធ ACTS ជូនដំណឹងការិយាល័យចេញដំណើរអំពីភាពប្រក្រតី ហើយបញ្ចេញទំនិញ
- ទំនិញត្រូវបានបញ្ចេញពីការឆ្លងកាត់គយ។

### ២.៤. ភាពមិនប្រក្រតី

ក្នុងករណី មានភាពមិនប្រក្រតី មន្ត្រីគយនៅការិយាល័យចេញដំណើរអាចសម្រេចចិត្តរង់ចាំដំណោះស្រាយភាពមិនប្រក្រតីនៅការិយាល័យចេញដំណើរមុនពេលបញ្ចេញទំនិញ។

- ការិយាល័យចេញដំណើរនឹងជូនដំណឹងតាមប្រព័ន្ធ ACTS ប្រសិនបើការិយាល័យគម្រូដ្ឋានសម្រេចរង់ចាំ
- មន្ត្រីគយកត់ត្រាចូលក្នុងប្រព័ន្ធ ACTS ដោយបញ្ជាក់ថា ការិយាល័យគម្រូដ្ឋានកំពុងរង់ចាំដំណោះស្រាយ
- ការបញ្ចេញទំនិញពីការឆ្លងកាត់ត្រូវបានពន្យាពេលរហូតដល់ភាពមិនប្រក្រតីត្រូវបានដោះស្រាយជាមួយការិយាល័យចេញដំណើរ។

## ៣. ការមកដល់ក្រោមនីតិវិធីសាមញ្ញ

អ្នកទទួលទំនិញ ឬអ្នកតំណាងម្ចាស់ទំនិញនឹងជូនដំណឹងការិយាល័យគម្រូដ្ឋានអំពីការមកដល់នៃទំនិញ÷

- ជាទូទៅ អ្នកទទួលទំនិញដែលទទួលបានអនុញ្ញាតទទួលបានការសម្របសម្រួលដោយអនុញ្ញាតឱ្យទំនិញប្រគល់ឱ្យនៅនឹងទីតាំងរបស់អ្នកទទួលទំនិញដោយផ្ទាល់។
- ប្រតិវេទន៍អមដំណើរឆ្លងកាត់ (TAD) មកដល់ជាមួយនឹងរថយន្តដឹកទំនិញ។

នៅពេលដែលការជូនដំណឹងការមកដល់ត្រូវបានបង្ហាញក្រោមនីតិវិធីសាមញ្ញ÷

- ប្រព័ន្ធ ACTS ត្រួតពិនិត្យថាតើ ធុរជនដែលជូនដំណឹងនៃការមកដល់ពិតជាទទួលបានការអនុញ្ញាតឱ្យប្រើប្រាស់នីតិវិធីសាមញ្ញនៅការិយាល័យគម្រូដ្ឋានដែរឬទេ និង
- ត្រួតពិនិត្យទីតាំងដាក់ទំនិញស្ថិតនៅក្នុងទីតាំងកំណត់ដែលបានអនុញ្ញាតដែរឬទេ។

ប្រសិនបើ គ្មានការបង្វែរទំនិញ ប្រព័ន្ធ ACTS ជូនដំណឹងការិយាល័យចេញដំណើរថា ការមកដល់ត្រូវបានទទួលយក ហើយការមកដល់ត្រូវបានកត់ត្រាចូលក្នុងប្រព័ន្ធ ACTS។

### ៣.១. ការបញ្ចេញទំនិញដោយស្វ័យប្រវត្តិ

ប្រសិនបើ ទំនិញត្រូវបានចាត់ទុកថា មានហានិភ័យទាប និងមិនមានទំនិញជាប់កម្រិតកំណត់ ការកំណត់ម៉ោងរង់ចាំការបញ្ចេញទំនិញដោយស្វ័យប្រវត្តិត្រូវបានចាប់ផ្តើម។

- បន្ទាប់ពីបញ្ចប់ការកំណត់ពេលវេលា អ្នកទទួលទំនិញទទួលបានការអនុញ្ញាតឱ្យទម្លាក់ទំនិញ

ការិយាល័យគម្រដ្ឋានទទួលបានព័ត៌មានអំពីដំណើរការឆ្លងកាត់ និងមានឱកាសធ្វើអន្តរាគមន៍ក្នុងចន្លោះពេលនេះជាមួយនឹងការសម្រេចចិត្តក្នុងការត្រួតពិនិត្យ។

ប្រសិនបើ មិនមានការត្រួតពិនិត្យទំនិញក្នុងរយៈពេលដែលបានព្រមព្រៀងនេះ ប្រព័ន្ធ ACTS ជូនដំណឹងធុរជនថា គាត់អាចចាប់ផ្តើមបញ្ចេញទំនិញ និងកត់ត្រាលទ្ធផលនៃការបញ្ចេញទំនិញ។

- ប្រសិនបើ មន្ត្រីគយសម្រេចចិត្តធ្វើការត្រួតពិនិត្យអំឡុងពេលនេះ ការអនុញ្ញាតបញ្ចេញទំនិញត្រូវបានបញ្ឈប់។

#### ៣.១.១. ការសម្រេចចិត្តត្រួតពិនិត្យ

ការវិភាគហានិភ័យត្រូវបានបញ្ចប់ដើម្បីជួយមន្ត្រីគយក្នុងការសម្រេចចិត្តត្រួតពិនិត្យទំនិញ។ លទ្ធផលវិភាគហានិភ័យដែលបានមកពីការិយាល័យចេញដំណើរអាចត្រូវបានទទួលយក ឬត្រូវពិចារណានៅពេលអនុវត្តការវិភាគហានិភ័យនៅការិយាល័យគម្រដ្ឋាន ហើយប្រព័ន្ធ ACTS កត់ត្រាលទ្ធផលនៃការវិភាគហានិភ័យ។

### ៣.២. ព័ត៌មាននៃការទម្លាក់ទំនិញ

ជាលក្ខខណ្ឌរបស់អ្នកទទួលទំនិញដែលទទួលបានការអនុញ្ញាត ព័ត៌មាននៃការបញ្ចេញទំនិញត្រូវផ្ញើទៅការិយាល័យគម្រដ្ឋាន។

- ប្រព័ន្ធ ACTS ត្រួតពិនិត្យភាពត្រឹមត្រូវនៃព័ត៌មានដែលបានទទួល និងរក្សាទុកព័ត៌មាននោះ។

នៅពេលការទម្លាក់ទំនិញត្រូវបានបញ្ចប់ដោយគ្មានការកត់សម្គាល់ណាមួយ បន្ទាប់មកប្រព័ន្ធ ACTS នឹងកត់ត្រាថា ទំនិញរួចរាល់សម្រាប់នីតិវិធីឬសកម្មភាពបន្ទាប់ (ឧ. ការរក្សាទុកបណ្តោះអាសន្ន នីតិវិធីនាំចូលជាដើម) ហើយទំនិញត្រូវបានបញ្ចេញពីការឆ្លងកាត់។ បន្ទាប់មក ប្រព័ន្ធ ACTS នឹងជូនដំណឹងការិយាល័យចេញដំណើរអំពីលទ្ធផលត្រួតពិនិត្យដោយបញ្ជាក់ថា “គ្មានកំហុសឆ្គង”។

នៅពេលការបញ្ចេញព័ត៌មានមិនបានបញ្ចប់ ដូចនេះ នឹងមានការកត់សម្គាល់លើការបញ្ចេញព័ត៌មាននេះ បន្ទាប់មកប្រព័ន្ធ ACTS ជូនដំណឹងមន្ត្រីគយថា គាត់ត្រូវធ្វើការសម្រេចចិត្តត្រួតពិនិត្យ ឬមិនត្រួតពិនិត្យទំនិញ។

- ការសម្រេចចិត្តមិនត្រួតពិនិត្យត្រូវបានកត់ត្រាចូលក្នុងប្រព័ន្ធ ACTS។

### ៣.៣. ការគ្រប់គ្រងការពិនិត្យ

ជាទូទៅ ការពិនិត្យត្រូវបានធ្វើឡើងនៅកន្លែងដាក់ទំនិញ ដូចបានបញ្ជាក់ក្នុងការជូនដំណឹងនៃការមកដល់។ មន្ត្រីគយត្រួតពិនិត្យទំនិញតាមរយៈការផ្ទៀងផ្ទាត់ទំនិញ និងឯកសារអមភ្ជាប់ធៀបនឹងព័ត៌មានបរិយាយអំពីដំណើរការដែលបោះពុម្ពជាទម្រង់ក្រដាស។

- ការិយាល័យគយគម្រូដ្ឋានកត់ត្រាចូលក្នុងប្រព័ន្ធ ACTS អំពីលទ្ធផលត្រួតពិនិត្យដោយបញ្ជាក់ថា "គ្មានកំហុសឆ្គង ឬមានកំហុសឆ្គង"។ រាល់ភាពមិនប្រក្រតីត្រូវបានដោះស្រាយជាមួយការិយាល័យចេញដំណើរ។

នៅពេលគ្មានកំហុសឆ្គង ឬមន្ត្រីគយសម្រេចចិត្តមិនរង់ចាំការកែតម្រូវកំហុសឆ្គងពីការិយាល័យចេញដំណើរ មន្ត្រីគយត្រូវកត់ត្រាចូលក្នុងប្រព័ន្ធ ACTS ថា ទំនិញរួចរាល់សម្រាប់នីតិវិធី/ សកម្មភាពបន្ទាប់ (ឧ. ការរក្សាទុកបណ្ដោះអាសន្ន ឬនីតិវិធីនាំចូលជាដើម)។

- ប្រព័ន្ធ ACTS ជូនដំណឹងការិយាល័យចេញដំណើរអំពីភាពប្រក្រតី ហើយបញ្ចេញទំនិញ។
- ទំនិញត្រូវបានបញ្ចេញពីការឆ្លងកាត់។

## ៣.៤. ភាពមិនប្រក្រតី

ក្នុងករណីមានភាពមិនប្រក្រតី ការិយាល័យគម្រូដ្ឋានអាចសម្រេចចិត្តរង់ចាំការកែតម្រូវភាពមិនប្រក្រតីនៅការិយាល័យចេញដំណើរមុនពេលបញ្ចេញទំនិញ។

- ការិយាល័យចេញដំណើរនឹងជូនដំណឹងតាមរយៈប្រព័ន្ធ ACTS ប្រសិនបើ ការិយាល័យគម្រូដ្ឋានសម្រេចរង់ចាំ។
- មន្ត្រីគយកត់ត្រាចូលក្នុងប្រព័ន្ធ ACTS ដោយបញ្ជាក់ថា ការិយាល័យគម្រូដ្ឋានកំពុងរង់ចាំ។
- ការបញ្ចេញទំនិញសម្រាប់ឆ្លងកាត់ត្រូវបានពន្យាពេលរហូតដល់ភាពមិនប្រក្រតីត្រូវបានដោះស្រាយជាមួយការិយាល័យចេញដំណើរ។

*ចំណាំ៖ ប្រសិនបើរកឃើញកំហុសឆ្គងធំ ការិយាល័យគយត្រូវពិចារណាលក្ខខណ្ឌ និងភាពធ្ងន់ធ្ងរ ថាតើកំហុសឆ្គងទាំងនេះ ធ្វើឱ្យប៉ះពាល់ដល់ការបន្តការអនុញ្ញាតនាពេលអនាគតរបស់អ្នកទទួលទំនិញ សម្រាប់នីតិវិធីសាមញ្ញដែរឬទេ។*

## ផ្នែកទី៩÷ ការបង្វែរ ឬការមិនប្រគល់ទំនិញ

### ១. ការបង្វែរទៅកាន់ការិយាល័យឆ្លងកាត់ ឬការិយាល័យគម្រដ្ឋានដែលមិនបានប្រកាស

ក្នុងករណី ការបង្វែរទំនិញឆ្លងកាត់ទៅកាន់ការិយាល័យគម្រដ្ឋានមួយផ្សេងទៀតក្រៅពីការិយាល័យដែលបានប្រកាសក្នុងប្រព័ន្ធ ACTS អ្នកទទួលទំនិញដែលទទួលបានការអនុញ្ញាត ឬអ្នកតំណាងម្ចាស់ទំនិញត្រូវជូនដំណឹងដល់ការិយាល័យគម្រដ្ឋានថ្មីអំពីការមកដល់នៃទំនិញនេះ។

- ការមកដល់ស្ថិតក្រោមនីតិវិធីសាមញ្ញនៅទីតាំងដែលបានអនុញ្ញាត ឬស្ថិតក្រោមនីតិវិធីធម្មតា។

នៅពេលការជូនដំណឹងការមកដល់ស្ថិតក្រោមនីតិវិធីសាមញ្ញ ប្រព័ន្ធ ACTS នឹងត្រួតពិនិត្យថា÷

- ធុរជនដែលជូនដំណឹងអំពីការមកដល់ត្រូវបានអនុញ្ញាតឱ្យ (អ្នកទទួលទំនិញ) ប្រើប្រាស់នីតិវិធីសាមញ្ញនៅការិយាល័យគម្រដ្ឋានដែរឬទេ និង
- ត្រួតពិនិត្យថា ទីតាំងដាក់ទំនិញស្ថិតនៅទីតាំងអនុញ្ញាត ដូចដែលបានបញ្ជាក់ក្នុងការអនុញ្ញាតដែរឬទេ។

#### ១.១. ការទាញយកព័ត៌មានប្រតិវេទន៍

នៅពេលទំនិញមកដល់ជាប្រក្រតីនៅការិយាល័យនិងប្រទេសនោះ លេខយោង ARN នឹងត្រូវបញ្ចូលទៅក្នុងប្រព័ន្ធ ACTS ដោយដៃ ឬដោយម៉ាស៊ីនស្កេនបារកូដ ហើយប្រព័ន្ធ ACTS ស្វែងរកព័ត៌មានដំណើរឆ្លងកាត់ដោយយោងតាមលេខយោងប្រតិវេទន៍ឆ្លងកាត់គយអាស៊ាន (ARN) ក្នុងការជូនដំណឹងការមកដល់។

- ក្នុងប្រទេសចេញដំណើរ បន្ទាប់ពីទទួលបានសារបញ្ជាក់ថានឹងមានប្រតិបត្តិការឆ្លងកាត់មកដល់ (AAR) ប្រព័ន្ធ ACTS ទទួលបានព័ត៌មាននៃដំណើរការឆ្លងកាត់ ដោយយោងតាមលេខយោងប្រតិវេទន៍ឆ្លងកាត់គយអាស៊ាន (ARN)។
- បន្ទាប់មក ប្រព័ន្ធ ACTS ផ្ញើទៅការិយាល័យគម្រដ្ឋានវិញនូវព័ត៌មានចាំបាច់សម្រាប់ដំណើរការឆ្លងកាត់។

ប្រសិនបើ ព័ត៌មានដែលទទួលបានមិនមានសារបញ្ជាក់ថា នឹងមានប្រតិបត្តិការឆ្លងកាត់មកដល់ (AAR) ដូចបានស្នើសុំ÷

- ប្រព័ន្ធ ACTS បដិសេធការមកដល់ និងជូនដំណឹងធុរជនអំពីការបដិសេធនេះ។

លើកលែងតែ÷

- ការបង្វែរត្រូវបានកត់ត្រាចូលទៅក្នុងប្រព័ន្ធ ACTS
- ការទទួលយកការមកដល់បានជូនដំណឹងដល់ការិយាល័យចេញដំណើរ និង
- ដំណើរការតាមរយៈការបញ្ចេញទំនិញសម្រាប់ឆ្លងកាត់អាចបន្តជាធម្មតា។

#### ១.២. ការិយាល័យឆ្លងកាត់ផ្សេងទៀត

ការបង្វែរ អាចកើតឡើងទៅការិយាល័យផ្សេងទៀតដែលខុសពីការិយាល័យដែលបានប្រកាសខាងដើមផងដែរ។ សរុបសេចក្តីមក នៅពេលមានការបង្វែរកើតឡើង ប្រព័ន្ធ ACTS នឹងត្រួតពិនិត្យថា ការិយាល័យឆ្លងកាត់ថ្មី ឬការិយាល័យគម្រដ្ឋានថ្មីជាការិយាល័យត្រឹមត្រូវដែរឬទេ។ មានន័យថា ប្រព័ន្ធនឹងត្រួតពិនិត្យ÷

- ប្រសិនបើការិយាល័យថ្មីក្នុងតម្រាយផ្លូវ ពោលគឺការិយាល័យគយឆ្លងកាត់ជំនួសមានតម្រាយផ្លូវចេញ ឬតម្រាយផ្លូវចូល។
- និមុត្តិធានាមានសុពលភាពក្នុងប្រទេសថ្មី មានន័យថា ប្រសិនបើ ការបង្វែរចូលក្នុងប្រទេសថ្មីមួយទៀត ដោយមិនគិតអំឡុងពេលផ្ទៀងផ្ទាត់ប្រតិវេទន៍ *(ប្រសិនបើ និមុត្តិធានាមិនមានសុពលភាពសម្រាប់ប្រទេសឆ្លងកាត់ថ្មី ឬប្រទេសគម្មដ្ឋានថ្មី ប្រតិបត្តិការឆ្លងកាត់ត្រូវបានបញ្ចប់)*។
- ទំនិញមិនមែនជាទំនិញហាមឃាត់/ ជាប់កម្រិតកំណត់ក្នុងប្រទេសថ្មី (ក្នុងករណីដែលចូលក្នុងប្រទេសថ្មីមួយទៀតខុសពីប្រទេសដែលបានប្រកាសខាងដើម)
- ស្ថានភាពនៃប្រតិវេទន៍ក្នុងលក្ខខណ្ឌបែបនេះអាចអនុញ្ញាតឱ្យមានដំណើរការបន្ថែមនៅការិយាល័យឆ្លងកាត់ (ដូចជា មិនទាន់បានទៅដល់នៅការិយាល័យគម្មដ្ឋានជាដើម)។
- ប្រសិនបើ ការិយាល័យគយថ្មីពិតជាការិយាល័យគយឆ្លងកាត់ (នៅព្រំដែន)។

ប្រសិនបើ ករណីខាងលើត្រូវបានយល់ព្រម ប្រព័ន្ធនឹងផ្ញើ ATR ទៅឱ្យការិយាល័យឆ្លងកាត់ថ្មី។ បន្ទាប់មកវាជាការទទួលខុសត្រូវរបស់មន្ត្រីគយធ្វើការផ្ទៀងផ្ទាត់ការឆ្លងកាត់ និងសម្រេចចិត្តថានឹងមានអ្វីកើតឡើងបន្ទាប់មកទៀត (អនុញ្ញាតឱ្យឆ្លងកាត់ព្រំដែន បញ្ជូនត្រលប់ទៅវិញ ឬបញ្ឈប់ ជាដើម)។

- ប្រព័ន្ធ ACTS នឹងជូនដំណឹងការិយាល័យគយឆ្លងកាត់ដែលបានប្រកាសពីដំបូងថា ការបង្វែរទៅកាន់ការិយាល័យថ្មីបានដំណើរការរួចរាល់ហើយ។

នៅការិយាល័យគម្មដ្ឋាន ប្រសិនបើការត្រួតពិនិត្យស្រដៀងគ្នាខាងលើត្រូវបានអនុវត្ត ការជូនដំណឹងការមកដល់នឹងត្រូវបានទទួលដោយស្វ័យប្រវត្តិ ហើយប្រព័ន្ធនឹងអនុញ្ញាតឱ្យតែមន្ត្រីគយប៉ុណ្ណោះចាប់ផ្តើមជាមួយនឹងដំណើរការនៅការិយាល័យនេះ ដែលជាការិយាល័យគម្មដ្ឋានចុងក្រោយ។

- មន្ត្រីគយមិនអាចមើលរំលងរឿងនេះបានឡើយ។
- ប្រសិនប្រព័ន្ធធ្វើការត្រួតពិនិត្យដោយជោគជ័យ ការិយាល័យបង្វែរនឹងក្លាយជាការិយាល័យគម្មដ្ឋាន និងមិនមានការបង្វែរណាផ្សេងទៀតដែលអាចទទួលយកបានឡើយ។

## ២. ឧប្បត្តិហេតុផ្សេងៗ

២.១. ក្នុងករណីមួយចំនួនដូចបញ្ជាក់ខាងក្រោម ក្រុមហ៊ុនដឹកជញ្ជូនចាំបាច់ត្រូវរៀបចំឯកសារមួយចំនួនក្នុងប្រតិវេទន៍អមដំណើរឆ្លងកាត់ ឬត្រូវមានភស្តុតាងគាំទ្រក្នុងទម្រង់ជារបាយការណ៍ផ្លូវការ និងបង្ហាញឯកសារនេះជាមួយនឹងទំនិញ និងប្រតិវេទន៍ឆ្លងកាត់ពាក់ព័ន្ធដទៃទៀតដល់អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសក្នុងដែនដែលមធ្យោបាយដឹកជញ្ជូនស្ថិតនៅ÷

(ក) ប្រសិនបើតម្រាយផ្លូវកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ចត្រូវបានផ្លាស់ប្តូរ

(ខ) ប្រសិនបើសៀលត្រូវបានខូចក្នុងអំឡុងពេលប្រតិបត្តិការដឹកជញ្ជូនដោយហេតុផលណាមួយលើសពីការគ្រប់គ្រងរបស់ក្រុមហ៊ុនដឹកជញ្ជូន

(គ) ប្រសិនបើ ទំនិញត្រូវបានផ្ទេរទៅមធ្យោបាយដឹកជញ្ជូនស្រដៀងគ្នាមួយទៀតក្នុងហេតុផលណាមួយ លើសពីការគ្រប់គ្រងរបស់ក្រុមហ៊ុនដឹកជញ្ជូន

(ឃ) ក្នុងករណីនឹងមានគ្រោះថ្នាក់ជិតកើតឡើងដែលចាំបាច់ត្រូវរើទំនិញផ្នែកខ្លះ ឬ ទាំងស្រុងជាបន្ទាន់ចេញពីមធ្យោបាយដឹកជញ្ជូន និង

(ង) ក្នុងករណី មានឧប្បត្តិហេតុ ឬគ្រោះថ្នាក់ណាមួយដែលអាចធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពរបស់ម្ចាស់ទំនិញ ឬក្រុមហ៊ុនដឹកជញ្ជូនក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន។

២.២. ក្នុងករណីមានឧប្បត្តិហេតុ និងគ្រោះថ្នាក់ស្រដៀងគ្នា ក្រុមហ៊ុនដឹកជញ្ជូនត្រូវស្វែងរករបាយការណ៍ស្តីពីគ្រោះថ្នាក់ពីមន្ត្រីគយ ឬមន្ត្រីនគរបាល ឬមន្ត្រីស៊ីវិលពាក់ព័ន្ធដទៃទៀត។ ក្រុមហ៊ុនដឹកជញ្ជូនត្រូវរាយការណ៍ឧប្បត្តិហេតុទៅកាន់ការិយាល័យគយឆ្លងកាត់ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន។

២.៣. នៅពេលដែលចាត់ទុកថាប្រតិបត្តិការឆ្លងកាត់មានបញ្ហាអាចបន្តតាមនីតិវិធីធម្មតា មន្ត្រីត្រូវចារលើប្រអប់ដែលបានកំណត់នៃប្រតិវេទន៍អមដំណើរឆ្លងកាត់ និងបញ្ជាក់ក្នុងប្រព័ន្ធ ACTS ផងដែរ។

## ៣. ការលុបចោលប្រតិវេទន៍ឆ្លងកាត់

នៅក្នុងប្រព័ន្ធ ACTS ម្ចាស់ទំនិញអាចស្នើសុំលុបប្រតិវេទន៍បាន មុនពេលមន្ត្រីធ្វើការត្រួតពិនិត្យ។ ការិយាល័យចេញដំណើរទទួលបានសំណើលុបចោលពីម្ចាស់ទំនិញ ហើយមន្ត្រីគយមានសិទ្ធសម្រេចថាលុបចោល ឬមិនលុបចោល។ ការលុបប្រតិវេទន៍ឆ្លងកាត់នឹងដំណើរការដោយមន្ត្រីគយ និងបញ្ចូលទៅក្នុងប្រព័ន្ធ ACTS។

- ម្ចាស់ទំនិញត្រូវផ្តល់ភស្តុតាងថាទំនិញត្រូវបានប្រកាសថាមានកំហុស ឬជាលទ្ធផលមួយនៃកាលៈទេសៈពិសេស ការដាក់ទំនិញក្រោមការឆ្លងកាត់លែងមានភាពត្រឹមត្រូវទៀតហើយ។

ការលុបចោលត្រូវបានបដិសេធនៅពេល÷

- មន្ត្រីគយបានសម្រេចចិត្តពិនិត្យទំនិញ ឬ
- ប្រសិនបើទំនិញបានបញ្ចេញរួចហើយ និងបានចាកចេញពីប្រទេសចេញដំណើរ (ការជូនដំណឹងនៃការឆ្លងកាត់ព្រំដែនត្រូវបានទទួលពីការិយាល័យឆ្លងកាត់)។

# ផ្នែកទី១០÷ នីតិវិធីអនុវត្តពេលប្រព័ន្ធមិនដំណើរការ

## ១. ពេលណាត្រូវប្រើនីតិវិធីអនុវត្តពេលប្រព័ន្ធមិនដំណើរការ

នីតិវិធីអនុវត្តពេលប្រព័ន្ធមិនដំណើរការនឹងដាក់ឱ្យអនុវត្តនៅពេល÷

(ក) ប្រព័ន្ធ ACTS សម្រាប់មន្ត្រីមិនដំណើរការ

(ខ) ប្រព័ន្ធ ACTS សម្រាប់ធុរជនមិនដំណើរការ

(គ) បណ្តាញទំនាក់ទំនងរវាងប្រព័ន្ធរបស់មន្ត្រី និងប្រព័ន្ធរបស់ធុរជនមិនដំណើរការ។

ក្នុងករណីទាំងនេះ ម្ចាស់ទំនិញត្រូវទំនាក់ទំនងក្រុមការងារបច្ចេកទេសរបស់ប្រព័ន្ធ ACTS របស់មន្ត្រីគយមានសមត្ថកិច្ច ដើម្បីសុំយោបល់។ ក្រុមការងារបច្ចេកទេសប្រព័ន្ធ ACTS ថ្នាក់ជាតិ និងថ្នាក់តំបន់នឹងផ្តល់ការណែនាំអំពីរយៈពេលដែលមិនអាចប្រើប្រាស់ប្រព័ន្ធនេះបាន។

លើសពីនេះទៀត តាមបច្ចេកទេស ភាពដែលអាចប្រើប្រាស់បាននៃប្រព័ន្ធនេះត្រូវរាយការណ៍ក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មាន ACTS (MIS) ដែលមានមុខងាររាយការណ៍អំពីភាពដែលមិនអាចប្រើបានដោយមិនបានគ្រោងទុកនៃប្រទេសសមាជិកអាស៊ាន។

## ២. វិធានការពេលប្រតិបត្តិការមិនដំណើរការនៅការិយាល័យចេញដំណើរ

មិនមានប្រតិវេទន៍ថ្មីណាមួយនឹងត្រូវទទួលយកក្នុងប្រព័ន្ធ ACTS។ ម្ចាស់ទំនិញមានជម្រើសក្នុងការប្រើប្រាស់នីតិវិធីឆ្លងកាត់ថ្នាក់ជាតិបច្ចុប្បន្ន (មិនប្រើប្រព័ន្ធ ACTS) ឬអាចរង់ចាំរហូតដល់ប្រព័ន្ធ ACTS មានដំណើរការឡើងវិញ។

ប្រសិនបើប្រតិវេទន៍ឆ្លងកាត់បានដាក់រួចរាល់ហើយ ប្រព័ន្ធ ACTS បានទទួលយក ប្រតិវេទន៍អមដំណើរឆ្លងកាត់ (TAD) បានបោះពុម្ពជាទម្រង់ក្រដាស ក្រោយមកប្រព័ន្ធខូចមុនពេលចេញដំណើរនៃដំណើរការឆ្លងកាត់ ឬតម្រាយផ្លូវទៅការិយាល័យឆ្លងកាត់ ឬការិយាល័យគម្យដ្ឋាន÷

- ដំណើរការឆ្លងកាត់ត្រូវបានអនុញ្ញាតឱ្យដំណើរការដោយប្រើប្រាស់ប្រតិវេទន៍អមដំណើរឆ្លងកាត់ (TAD) ត្រូវបានបោះពុម្ពជាទម្រង់ក្រដាស។

ប្រសិនបើ ប្រតិវេទន៍ត្រូវបានទទួលយក ប៉ុន្តែ ប្រតិវេទន៍អមដំណើរឆ្លងកាត់ (TAD) មិនបានបោះពុម្ពជាទម្រង់ក្រដាស÷

- ម្ចាស់ទំនិញអាចរង់ចាំប្រព័ន្ធ ACTS ដំណើរការម្តងទៀត ឬ
- ប្រើប្រាស់នីតិវិធីឆ្លងកាត់ថ្នាក់ជាតិ។

## ៣. វិធានការពេលប្រតិបត្តិការមិនដំណើរការនៅការិយាល័យគយឆ្លងកាត់

ក្រុមហ៊ុនដឹកជញ្ជូនត្រូវតែបង្ហាញទំនិញជាមួយនឹងប្រតិវេទន៍អមដំណើរឆ្លងកាត់ (TAD) ដល់ការិយាល័យគយឆ្លងកាត់។ មន្ត្រីគយត្រូវតពិនិត្យ÷

- ព័ត៌មានលម្អិតលើប្រតិវេទន៍អមដំណើរឆ្លងកាត់ (TAD) ដែលបោះពុម្ពជាទម្រង់ក្រដាស និងផ្ទៀងផ្ទាត់ការបរិយាយទំនិញធៀបនឹងប្រតិវេទន៍បែបពាណិជ្ជកម្មដែលមាននៅលើរថយន្តដឹកទំនិញ
- លេខសៀលដែលបានកិបជាប់នៅលើរថយន្តដឹកទំនិញ ឬកុងតឺន័រដើម្បីធានាថាលេខសៀលគឺដូចគ្នាទៅនឹងលេខសៀលដែលនៅលើ TAD និង
- ផ្ទៀងផ្ទាត់ថាសៀលនៅកិបជាប់ដដែល។

ប្រសិនបើមិនមានការសង្ស័យ មន្ត្រីគយនឹង÷

- ចារលើប្រតិវេទន៍អមដំណើរឆ្លងកាត់ (TAD) ច្បាប់ដើមដោយចារដោយដៃនៅផ្នែកម្ខាងទៀតជាមួយនឹងព័ត៌មានលម្អិតនៃការត្រួតពិនិត្យដែលបានអនុវត្ត និង
- ចុះហត្ថលេខា និងបោះត្រានៅលើផ្នែកម្ខាងទៀតរបស់ TAD ជាមួយនឹងត្រារបស់ការិយាល័យគយ។

*ចំណាំ÷ មន្ត្រីគយត្រូវថតចម្លង TAD (និងឯកសារភ្ជាប់) និងទុកវាជាឯកសារក្នុងការិយាល័យឆ្លងកាត់សម្រាប់សវនកម្មត្រួតពិនិត្យនៅពេលក្រោយ។*

- បន្ទាប់មក មន្ត្រីគយនឹងប្រគល់ TAD ឱ្យទៅក្រុមហ៊ុនដឹកជញ្ជូនវិញ និងអនុញ្ញាតដំណើរការឆ្លងកាត់បន្តដំណើរ។

ប្រសិនបើមានការសង្ស័យ មន្ត្រីគយអាចពិនិត្យរូបវន្តទំនិញ។ ប្រសិនបើ ការពិនិត្យរូបវន្តទំនិញមិនស្របគ្នាជាមួយនឹងការបរិយាយ ឬបរិមាណនៅលើ TAD មន្ត្រីគយនឹងចាត់វិធានការសមស្របតាមតាមច្បាប់ជាតិរបស់ប្រទេសដែលជាសមាជិកអាស៊ាន។

## ៤. វិធានការពេលប្រតិបត្តិការមិនដំណើរការនៅការិយាល័យគម្រដ្ឋាន

ប្រសិនបើ ប្រព័ន្ធមិនអាចប្រើប្រាស់បានខណៈដែលប្រតិបត្តិការឆ្លងកាត់កំពុងដំណើររវាងការិយាល័យគយឆ្លងកាត់និងការិយាល័យគយគម្រដ្ឋាន ទំនិញដែលមាន TAD ច្បាប់ដើមភ្ជាប់មកជាមួយត្រូវបង្ហាញដល់ការិយាល័យគយគម្រដ្ឋាន។

ប្រសិនបើដំណើរកាឆ្លងកាត់ស្ថិតក្រោមនីតិវិធីសាមញ្ញ មន្ត្រីគយត្រូវជូនដំណឹងម្ចាស់ទំនិញថា ដោយសារប្រព័ន្ធមិនអាចប្រើប្រាស់បាន÷

- នីតិវិធីសាមញ្ញនឹងមិនអាចអនុវត្តបាននៅការិយាល័យគម្រដ្ឋាន និង
- នីតិវីធីធម្មតានឹងត្រូវយកមកប្រើ។

*ចំណាំ÷ ក្នុងករណីទាំងពីរនេះ ទាំងនីតិវិធីធម្មតា និងនីតិវិធីសាមញ្ញ ក្រុមហ៊ុនដឹកជញ្ជូនត្រូវបង្ហាញទំនិញភ្ជាប់ជាមួយនឹង TAD ឱ្យការិយាល័យគយគម្រដ្ឋានដើម្បីត្រួតពិនិត្យ។*

មន្ត្រីគយការិយាល័យគម្រូដ្ឋាននឹងត្រួតពិនិត្យ÷

- ព័ត៌មាននៅលើ TAD ដែលបានបោះពុម្ពជាទម្រង់ក្រដាស និងផ្ទៀងផ្ទាត់ការបរិយាយទំនិញធៀបនឹងឯកសារពាណិជ្ជកម្មដែលមាននៅលើរថយន្តដឹកជញ្ជូន។
- លេខសៀលបានកិបជាប់នឹងរថយន្តដឹកទំនិញ ឬកុងតឺន័រដើម្បីធានាថា លេខសៀលគឺដូចគ្នាទៅនឹងលេខសៀលនៅលើ TAD និងត្រួតពិនិត្យដើម្បីផ្ទៀងផ្ទាត់ថា សៀលនៅកិបជាប់ដដែល។

ប្រសិនបើមិនមានការសង្ស័យ មន្ត្រីគយនឹង÷

- ចារលើ TAD ច្បាប់ដើមដោយចារដោយដៃនៅម្ខាងទៀតជាមួយនឹងព័ត៌មានលម្អិតនៃត្រួតពិនិត្យដែលបានអនុវត្ត និង
- ចុះហត្ថលេខា និងបោះត្រានៅលើផ្នែកម្ខាងទៀតរបស់ TAD ជាមួយនឹងត្រាគយ។

*ចំណាំ÷ មន្ត្រីគយត្រូវថតចម្លង TAD (និងឯកសារភ្ជាប់) និងទុកវាជាឯកសារក្នុងការិយាល័យគយគម្រូដ្ឋានសម្រាប់សវនកម្មត្រួតពិនិត្យនៅពេលក្រោយ។*

- បន្ទាប់មក មន្ត្រីគយនឹងប្រគល់ TAD ទៅឱ្យក្រុមហ៊ុនដឹកជញ្ជូនវិញ និងបញ្ចប់ដំណើរការឆ្លងកាត់។

ប្រសិនបើមានការសង្ស័យ មន្ត្រីគយអាចធ្វើការត្រួតពិនិត្យរូបវន្តទំនិញ។ ប្រសិនបើការត្រួតពិនិត្យរូបវន្តទំនិញ រកឃើញថា មិនមានភាពស្របគ្នាជាមួយនឹងការបរិយាយ ឬបរិមាណទំនិញនៅ TAD មន្ត្រីគយនឹងចាត់វិធានការសមស្របតាមច្បាប់ជាតិរបស់ប្រទេសសមាជិកអាស៊ាន។

## ៥. វិធានការនៅពេលដែលប្រព័ន្ធ ACTS មានដំណើរការឡើងវិញ

នៅពេលដែលប្រព័ន្ធ ACTS មានដំណើរការឡើងវិញ មន្ត្រីគយការិយាល័យឆ្លងកាត់ និងការិយាល័យគយគម្រូដ្ឋាននឹងបញ្ចូលប្រតិវេទន៍ទាំងឡាយណាអំឡុងពេលប្រព័ន្ធមិនដំណើរទៅក្នុងប្រព័ន្ធ ACTS ដោយប្រើប្រាស់ម៉ាស៊ីនស្កែនបារកូដ លើលេខយោងប្រតិវេទន៍ឆ្លងកាត់គយអាស៊ាន (ARN) នៃប្រតិវេទន៍អមដំណើរឆ្លងកាត់ (TAD) ជាទម្រង់ក្រដាសដែលបានរក្សាទុកដោយការិយាល័យនោះ។

សម្រាប់ប្រតិបត្តិការនៅពេលប្រព័ន្ធមិនដំណើរការ មន្ត្រីគយការិយាល័យគយគម្រូដ្ឋានត្រូវបញ្ជូនទៅការិយាល័យចេញដំណើរនូវការជូនដំណឹងការមកដល់ លទ្ធផលត្រួតពិនិត្យ និងការជូនដំណឹងនៃការបញ្ចប់ពេញលេញ ឬមិនពេញលេញ។

ក្រុមការងារអនុវត្តប្រព័ន្ធ ACTS នឹងផ្តល់ការណែនាំអំពីវិធានការដែលនឹងត្រូវអនុវត្តនៅពេលដែលប្រព័ន្ធ ACTS មានដំណើរការឡើងវិញ។

## ៦. តារាងរំហូរនីតិវិធីនៅពេលប្រព័ន្ធ ACTS មិនមានដំណើរការ

សម្រាប់តែ នៅពេលដែលប្រតិវេទន៍ឆ្លងកាត់បានបញ្ជូន បានទទួលយក និងបានបោះពុម្ពប្រតិវេទន៍អមដំណើរឆ្លងកាត់ (TAD) ជាទម្រង់ក្រដាសរួចហើយ។ ប្រសិនបើ ប្រតិវេទន៍ត្រូវបានទទួលរួចហើយ និង TAD មិនទាន់បានបោះពុម្ពជាទម្រង់ក្រដាស មន្ត្រីគយលុបចោលប្រតិវេទន៍នោះ។ ក្រៅពីនេះ ម្ចាស់ទំនិញអាចរង់ចាំឱ្យប្រព័ន្ធ ACTS មានដំណើរការឡើងវិញ ឬប្រើប្រាស់នីតិវិធីថ្នាក់ជាតិរបស់ប្រទេសនីមួយៗ។



## ផ្នែកទី១១៖ ការសាកសួរ និងការប្រមូលបំណុលគយមកវិញ

### ១. នីតិវិធីសាកសួររបស់ប្រព័ន្ធ

#### ១.១. សារបញ្ជាក់នានា

ការិយាល័យចេញដំណើរត្រូវទទួលបានសារបញ្ជាក់ថាបានមកដល់ (Arrival Advice) ក្នុងរយៈពេល ០២ថ្ងៃ ក្រោយពីកាលបរិច្ឆេទបញ្ជាក់ថាមកដល់បានកំណត់ពេលវេលាបញ្ចេញទំនិញ ផ្អែកលើតម្រាយផ្លូវ។

- សារនេះបញ្ជាក់ថាទំនិញបានមកដល់ក្នុងចំនួនថ្ងៃដែលបានកំណត់សម្រាប់ដំណើរការឆ្លងកាត់។

សារទី២ជាសារអំពី "លទ្ធផលត្រួតពិនិត្យ" គួរទទួលបានក្នុងរយៈពេលយ៉ាងយូរ ០៦ថ្ងៃ បន្ទាប់ពីបានទទួលសារបញ្ជាក់ថាបានមកដល់ (Arrival Advice)។

- សារបញ្ជាក់អំពីលទ្ធផលត្រួតពិនិត្យនេះបញ្ជាក់ថាតើដំណើរការអាចបញ្ចេញ និងបានបញ្ចេញនិមុត្តិធានាណាមួយ ក្នុងករណីរកឃើញកំហុសឆ្គងណាមួយ។

#### ១.២. ការចាប់ផ្ដើមនីតិវិធីសាកសួរ

ក្នុងករណីមិនបានទទួលសារទាំងនេះក្នុងរយៈពេលដែលបានកំណត់ ការិយាល័យចេញដំណើរទទួលខុសត្រូវចាប់ផ្ដើមនីតិវិធីសាកសួរ។

ប្រសិនបើ គ្មានព័ត៌មានបញ្ជាក់ថា ទំនិញបានបង្ហាញនៅការិយាល័គយគម្យដ្ឋាន÷

- ការឆ្លងកាត់ត្រូវចាត់ទុកថា "ស្ថិតនៅក្រោមការទាមទារសំណង"
- ម្ចាស់ទំនិញត្រូវបានណែនាំថា ម្ចាស់ទំនិញត្រូវរៀបចំភស្ដុតាងក្នុងរយៈ ៣០ថ្ងៃ ដើម្បីបង្ហាញថាការឆ្លងកាត់ពិតជាត្រឹមត្រូវ
- ភស្ដុតាងនឹងនឹងត្រូវផ្ទៀងផ្ទាត់ជាមួយអាជ្ញាធរនៅការិយាល័យគម្យដ្ឋាន។

ការិយាល័យគយផ្សេងទៀត ដែលពាក់ព័ន្ធនឹងដំណើរការឆ្លងកាត់នេះក៏អាចផ្ដួចផ្ដើមការសាកសួរផងដែរ។ ការសាកសួរនេះផ្អែកតាមព័ត៌មានដែលបានទទួលពីម្ចាស់ទំនិញនៃទីតាំងទុកដាក់រថយន្តដឹកទំនិញ។

#### ១.៣. ភស្ដុតាងដែលបានផ្ដល់ដោយម្ចាស់ទំនិញ

នៅពេលម្ចាស់ទំនិញផ្ដល់ភស្ដុតាងមិនមានកំហុសឆ្គងថា ប្រតិបត្តិការឆ្លងកាត់បានបញ្ចប់យ៉ាងត្រឹមត្រូវនៅការិយាល័យគយមួយផ្សេងទៀតខុសពីការិយាល័យដែលបានប្រកាស ប្រព័ន្ធនឹងជូនដំណឹងការិយាល័យគម្យដ្ឋានដើមក្នុងរយៈពេល ០៦ថ្ងៃ។

*ចំណាំ÷ ភស្ដុតាងអាចជា ឯកសារផ្ទៀងផ្ទាត់ដែលទំនិញបានដំណើរការក្រោមនីតិវិធីថ្នាក់ជាតិ ដូចជា ការនាំចូល ឬបញ្ចូលក្នុងឃ្លាំង ក្នុងប្រទេសគម្យដ្ឋាន។*

## ២. នីតិវិធីប្រមូលបំណុលគយមកវិញតាមប្រព័ន្ធ ACTS

គោលបំណងនៃនីតិវិធីប្រមូលបំណុលគយមកវិញ គឺដើម្បីកំណត់ស្ថានភាពបំណុលដែលបានកើតឡើងអំឡុងពេលប្រតិបត្តិការឆ្លងកាត់ ដើម្បីកំណត់កូនបំណុល និងប្រទេសដែលមានសមត្ថកិច្ចអនុវត្តការទូទាត់បំណុលមកវិញពីកូនបំណុល និងនិមុត្តិធានា។

ការិយាល័យចេញដំណើរផ្តួចផ្តើមនីតិវិធីសាកសួរ រៀងរាល់ពេលដែលមិនបានទទួលសារបញ្ជាក់ថាបានមកដល់ (Arrival Advice) ក្នុងរយៈពេល ០២ថ្ងៃ នៃពេលវេលាកំណត់ ដែលទំនិញនឹងត្រូវបង្ហាញនៅការិយាល័យគយគម្យដ្ឋាន ឬមិនបានទទួលសារបញ្ជាក់អំពីលទ្ធផលត្រួតពិនិត្យ ក្នុងរយៈ ០៦ថ្ងៃ បន្ទាប់ពីបានទទួលសារបញ្ជាក់ថាបានមកដល់។

ការផ្តួចផ្តើមនីវិធីប្រមូលបំណុលគយមកវិញ គឺដើម្បីទទួលព័ត៌មានចាំបាច់នានាក្នុងការបញ្ចេញប្រតិបត្តិការឆ្លងកាត់ ឬក្នុងករណីដែលមិនអាច÷

- ទូទាត់បំណុលគយដែលបានជំពាក់
- កំណត់អត្តសញ្ញាណកូនបំណុល និង
- កំណត់អាជ្ញាធរមានសមត្ថកិច្ចទទួលខុសត្រូវសម្រាប់ការទូទាត់បំណុលមកវិញ។

ក្នុងករណី ការិយាល័យចេញដំណើរបានទទួលសារបញ្ជាក់ថាបានមកដល់ (Arrival Advice) ប៉ុន្តែមិនបានទទួលសារបញ្ជាក់អំពីលទ្ធផលត្រួតពិនិត្យ ត្រូវផ្ញើសំណើរំលឹកទៅកាន់ការិយាល័យគម្យដ្ឋាន។

ប្រសិនបើ ការិយាល័យចេញដំណើរមិនបានទទួលសារបញ្ជាក់ថាបានមកដល់ (Arrival Advice) ត្រូវផ្ញើសំណើទៅការិយាល័យគម្យដ្ឋានបញ្ជាក់ថា ទំនិញមិនទាន់បានបង្ហាញ។

- ការិយាល័យគម្យដ្ឋានត្រូវឆ្លើយតបក្នុងរយៈពេល ០៧ថ្ងៃ។

### ២.១. ការចាត់វិធានការប្រមូលបំណុលគយមកវិញ

ប្រព័ន្ធ ACTS នឹងចាប់ផ្តើមវិធានការប្រមូលបំណុលមកវិញ ប្រសិនបើ÷

(ក) ពេលវេលាទូទាត់បំណុល (Recovery Recommended Timeout) ក្នុងប្រព័ន្ធ ACTS បានផុតកំណត់

(ខ) បានទទួលសំណើទូទាត់បំណុលពីការិយាល័យគម្យដ្ឋាន ឬការិយាល័យឆ្លងកាត់ ឬ

(គ) មិនមានព័ត៌មាន ឬព័ត៌មានមិនគ្រប់គ្រាន់អំពីស្ថានភាពនៃដំណើរការឆ្លងកាត់។

មន្ត្រីគយក៏អាចចាប់ផ្តើមនីតិវិធីប្រមូលបំណុលគយមកវិញដោយដៃបានគ្រប់ពេលផងដែរ បន្ទាប់ពីការបញ្ចេញដំណើរការឆ្លងកាត់។

អាជ្ញាធរគយការិយាល័យចេញដំណើរស៊ើបអង្កេត ប្រសិនទីតាំងមានភាពមិនប្រក្រតីកើតឡើងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ហើយប្រសិនបើមានភាពមិនប្រក្រតីពិតមែន ត្រូវចាប់ផ្តើមនីតិវិធីប្រមូលបំណុលគយ។

ប្រសិនបើ មិនមានភាពមិនប្រក្រតីកើតឡើងក្នុងប្រទេសចេញដំណើរ អាជ្ញាធរគយបញ្ជូនសំណើការទូទាត់បំណុលទៅប្រទេសឆ្លងកាត់ ឬប្រទេសគម្យដ្ឋាន។

- អាជ្ញាធរគយក្នុងប្រទេសឆ្លងកាត់ និងប្រទេសគម្យដ្ឋាន សម្រេចថាតើ ភាពមិនប្រក្រតីបានកើតឡើងក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដែរឬទេ ប្រសិនបើ ភាពមិនប្រក្រតីបានកើតឡើងក្នុងប្រទេសខ្លួនមែន អាជ្ញាធរគយក្នុងប្រទេសនោះត្រូវគណនាចំនួនពន្ធនិងអាករដែលត្រូវទូទាត់ និងចាប់ផ្តើមដំណើរការប្រមូលបំណុលគយមកវិញ។

នីតិវិធីប្រមូលបំណុលគយវិញមានគោលបំណងស្វែងរកការទូទាត់ពន្ធនិងអាករ ជាដំបូងពីម្ចាស់ទំនិញ ឬពីកូនបំណុលដែលបានកំណត់អត្តសញ្ញាណណាមួយ ប៉ុន្តែបើការទូទាត់នេះមិនអាចធ្វើទៅបាន ត្រូវធ្វើការទូទាត់ជាមួយអ្នកធានា។

ក្រោយពីបញ្ចប់នីតិវិធីប្រមូលបំណុលពន្ធនិងអាករ ដោយជោគជ័យជាមួយម្ចាស់ទំនិញ ឬអ្នកធានារួច÷

- ដំណើរការឆ្លងកាត់ត្រូវបានបញ្ចប់ប្រតិបត្តិការ
- ការបញ្ចេញនិមុត្តិធានាបានកត់ត្រាទៅក្នុងប្រព័ន្ធ ACTS និង
- ស្ថានភាពនៃប្រតិបត្តិការឆ្លងកាត់បានកំណត់ថា "បញ្ចប់ប្រតិបត្តិការ"។

អាជ្ញាធរគយដែលបានអនុវត្តការទូទាត់បំណុល (ក្រៅពីការិយាល័យចេញដំណើរ) ត្រូវជូនដំណឹងការិយាល័យចេញដំណើរ នៅពេលដែលបញ្ចប់ការទូទាត់បំណុលនោះ។

ការិយាល័យចេញដំណើរនឹងជូនដំណឹងអ្នកពាក់ព័ន្ធដទៃទៀតថា ការទូទាត់បំណុលបានបញ្ចប់ បន្ទាប់មកចាប់ផ្តើមនីតិវិធីបញ្ចប់ដំណើរការឆ្លងកាត់ និងបញ្ចេញនិមុត្តិធានា។

## ACTS Enquiry and Recovery Procedures




1. Customs Office of Departure shall initiate an enquiry procedure each time they have not received the Arrival Advice within 2 days of the expected arrival of the truck at destination or the control result message within 6 days after having received the arrival advice message.
2. The Customs Office of Departure checks ACTS to identify the country in which the transit movement was last under Customs control. Contacts Customs Authorities in that country for confirmation of status and that the transit movement was correctly terminated. If correctly terminated, the transit operation is discharged. If not, will continue with Step 3.
3. Customs Office of Departure requests evidence from the Principal within 30 days that the transit movement was correctly terminated. If evidence is available, then transit operation is discharged.
4. If no evidence of correct termination is received within 30 days of Customs request, Customs Authorities of Countries involved in the Transit operation will establish and agree where the loss of duties and taxes occurred, and which Customs Authority is responsible for recovery action.
5. Once there is an agreement where the Customs debt has been incurred, the RCA will authorize the ACA to start the recovery process. (See next page for Recovery Procedures)

**ACTS Recovery Procedures**




Note: ACA is the Customs Authority (can be destination/transit) in which irregularities happen.

RCA is the Customs Authority in which Principal and guarantor are situated (departure).

6. (a) The Applicant Customs Authority (ACA) informs Guarantor by registered post that a claim may be forthcoming (see Annex 11E (Transit Termination Enquiry) of Customs Procedures Manual) if the Principal does not provide proof of termination or respond within 30 days. This is copied to the Requested Customs Authority (RCA). This notification will be sent to Guarantor within 90 days of the date transit declaration was accepted for release by the Customs office of departure.

   (b) The RCA will contact the Principal, determine the facts of the case, and establish the persons responsible. Under normal circumstances, the Principal pays directly to the ACA.

   (c) The RCA informs the ACA on the result of the consultation with the Principal.
7. If the Principal does not pay the claim, the ACA will invoke payment of the debt from the Guarantor under the terms of the guarantee lodged with the Customs Office of Guarantee. This claim must be made within 270 days of the date the transit declaration was accepted for release by the Customs office of departure.
8. The ACA makes a claim against the Guarantor via the correspondent bank.
9. The Guarantor pays the Customs debt directly to the ACA's bank account within 30 days of the claim.
10. ACA completes the recovery process by registering the recovery outcome in the ACTS which automatically informs the RCA accordingly.

# ឧបសម្ព័ន្ធនៃផ្នែកទី១១

## ឧបសម្ព័ន្ធ ១១ក៖ ការសាកសួរ និងការប្រមូលបំណុលមកវិញ

### ១. សេចក្តីផ្តើម

ឧបសម្ព័ន្ធនេះកំណត់នូវនីតិវិធីស្តង់ដារ ដែលបានរៀបចំឡើងក្នុងគោលបំណងដើម្បីដោះស្រាយការសួរសំណួរងាយៗ និងចៀសវាងការទាមទារសំណងដែលពុំចាំបាច់នានា ប៉ុន្តែនីតិវិធីទាំងនេះមិនមែនជាការបង្គាប់បញ្ជាឡើយ។

ដោយទទួលស្គាល់ថា អាជ្ញាធរមានសមត្ថកិច្ចត្រូវមានភាពបត់បែនក្នុងការផ្តល់ជាជម្រើសនៃដំណាក់កាលសាកសួរ នៅពេលរកឃើញភាពមិនប្រក្រតី (បានបង្កើតបំណុលគយ) ផ្នែកនេះមានក្នុងឧបសម្ព័ន្ធបច្ចេកទេសនៃពិធីសារទី៧ មាត្រា៣៦ កថាខ័ណ្ឌទី១០ និងទី១១។

### ២. បញ្ជីសកម្មភាពរួម

| ល.រ | បញ្ហា | សកម្មភាព |
|---|---|---|
| ១ | ការិយាល័យចេញដំណើរមិនបានទទួលសារបញ្ជាក់ថាបានមកដល់ពីការិយាល័យគម្មដ្ឋានក្នុងរយៈពេល ២ ថ្ងៃ នៃពេលវេលាដែលបានកំណត់។ | ការិយាល័យចេញដំណើរត្រូវទំនាក់ទំនងការិយាល័យគម្មដ្ឋានដើម្បីបញ្ជាក់ថាដំណើរការឆ្លងកាត់បានបញ្ចប់ដោយគ្មានកំហុសឆ្គង ដោយប្រើប្រាស់សារអេឡិចត្រូនិកស្តង់ដារ។ |
| ២ | ការិយាល័យចេញដំណើរបានទទួលសារបញ្ជាក់ថាបានមកដល់ ប៉ុន្តែមិនបានទទួលសារបញ្ជាក់អំពីលទ្ធផលត្រួតពិនិត្យពីការិយាល័យគម្មដ្ឋានក្នុងរយៈពេល ០៦ ថ្ងៃក្រោយមក។ | ការិយាល័យចេញដំណើរទំនាក់ទំនងការិយាល័យគម្មដ្ឋានដោយប្រើប្រាស់សារអេឡិចត្រូនិកស្តង់ដារដើម្បីបញ្ជាក់ថាដំណើរការឆ្លងកាត់ត្រូវបានបញ្ចប់ដោយគ្មានកំហុសឆ្គង និងអាចបញ្ចេញការឆ្លងកាត់។ |
| ៣ | ការិយាល័យគម្មដ្ឋានមិនបានបញ្ជាក់អំពីការទទួលទំនិញ | ការិយាល័យគយចេញដំណើរ÷<br>ត្រួតពិនិត្យកំណត់ត្រាអេឡិចត្រូនិកដើម្បីកំណត់ប្រទេសដែលដំណើរការឆ្លងកាត់ចុងក្រោយបានស្ថិតក្រោយការត្រួតពិនិត្យរបស់គយដែរឬទេ។<br>ទំនាក់ទំនងអាជ្ញាធរមានសមត្ថកិច្ចក្នុងប្រទេសនោះដើម្បីបញ្ជាក់អំពីស្ថានភាព និងដំណើរការឆ្លងកាត់បានបញ្ចប់ត្រឹមត្រូវដែរឬទេ។ |

| | | |
|---|---|---|
| | | ស្នើសុំភស្តុតាងពីម្ចាស់ទំនិញក្នុងរយៈពេលកំណត់ ៣០ថ្ងៃដែលដំណើរការឆ្លងកាត់ត្រូវបញ្ចប់ត្រឹមត្រូវក្រោមការត្រួតពិនិត្យរបស់គយ ឬស្នើសុំព័ត៌មានពាក់ព័ន្ធនឹងទីតាំងនិងស្ថានភាពទំនិញ។<br>បញ្ចេញដំណើរការឆ្លងកាត់ ប្រសិនបើភស្តុតាងមានភាពសមស្រប។ |
| ៤ | ភស្តុតាងនៃការបញ្ចប់មិនបានផ្តល់ឱ្យការិយាល័យចេញដំណើរក្នុងរយៈពេល ៣០ថ្ងៃ។ | ការិយាល័យចេញដំណើរផ្តួចផ្តើមដំណើរការទូទាត់បំណុល។ ដំណោះស្រាយសំណងសម្រាប់ទូទាត់ម្ចាស់ទំនិញ ត្រូវធ្វើតាមអាសយដ្ឋានដែលបានបញ្ជាក់ ឬសមមូល(សូមមើលក្នុងឧបសម្ព័ន្ធ ១១ខ)។<br>ជូនដំណឹងអ្នកធានា (ឬភ្នាក់ងារ) ដែលអាចទុកចិត្តបានដោយថតចម្លងលិខិតនេះជូនម្ចាស់ទំនិញ។<br>ជូនដំណឹងអាជ្ញាធរគយដែលម្ចាស់ទំនិញស្ថិតនៅ (បើមិនស្ថិតក្នុងប្រទេសរបស់អាជ្ញាធរគយ សូមមើលក្នុងឧបសម្ព័ន្ធ ១១ខ ឃ និង ង) |
| ៥ | ម្ចាស់ទំនិញមិនបានដោះស្រាយសំណងក្នុងរយៈពេលកំណត់ និងមិនបានដាក់ពាក្យប្តឹងតវ៉ាក្នុងប្រទេសទាមទារសំណង។ | ការិយាល័យចេញដំណើរ ឬការិយាល័យគយដែលបានចាត់តាំងបញ្ជូនករណីនេះទៅ÷<br>តុលាការទាមទារសំណងពីអ្នកធានា ប្រសិនបើ ករណីនេះបានកើតឡើងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឬ ប្រសិនមិនបានកើតឡើងក្នុងដែនសមត្ថកិច្ចរបស់ខ្លួនទេ ចូរប្រើនីតិវិធីជំនួយទៅវិញទៅមក ឬនីតិវិធីបដិការ (Mutual Assistance Procedure) សម្រាប់ការទូទាត់បំណុល (សូមមើលក្នុងឧបសម្ព័ន្ធ ១១ខ ឃ និង ង)។ |

**គំរូលិខិតផ្ញើទៅកាន់ម្ចាស់ទំនិញ**

ឈ្មោះ និងព័ត៌មានទំនាក់ទំនងលម្អិតរបស់អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសចេញដំណើរ

.................................................................................................

..................................................................................................................

ទីកន្លែង និងកាលបរិច្ឆេទ.....................................................  ........................

ឈ្មោះ និងព័ត៌មានទំនាក់ទំនងលម្អិតរបស់ម្ចាស់ទំនិញ.....................................................

...................................................................................................................

គោរពជូន.........

យោងតាមកំណត់ត្រារបស់អាជ្ញាធរគយ អ្នកជាម្ចាស់ទំនិញនៃប្រតិវេទន៍ឆ្លងកាត់គយអាស៊ាន ដែលមានលេខយោងប្រតិវេទន៍ឆ្លងកាត់គយអាស៊ានដូចខាងក្រោម៖

i)............................................

ii)............................................

ពីការិយាល័យចេញដំណើរ [ឈ្មោះការិយាល័យចេញដំណើរ]

ដោយអនុលោមតាមច្បាប់ឆ្លងកាត់គយអាស៊ាន អាជ្ញាធរគយ សូមណែនាំ លោក/លោកស្រីថា អាជ្ញាធរគយមិនមានភស្តុតាងនៃការបញ្ចប់នីតិវិធីឆ្លងកាត់សម្រាប់ប្រតិវេទន៍ដែលបានរៀបរាប់ខាងលើ ពីការិយាល័យគយគម្រដ្ឋាននោះទេ (ឈ្មោះនិងអាសយដ្ឋាន)។

អ្នកតម្រូវឱ្យផ្ញើព័ត៌មានលម្អិត និងឯកសារពេញលេញដែលមានភស្តុតាងបង្ហាញថា នីតិវិធីនេះត្រូវបានបញ្ចប់ត្រឹមត្រូវ ជាពិសេស អ្នកត្រូវផ្តល់ព័ត៌មានផងដែរអំពីការផ្លាស់ប្តូរនានាក្នុងការិយាល័យគម្រដ្ឋាននិង/ឬការិយាល័យឆ្លងកាត់ដែលបានធ្វើឡើងអំឡុងពេលឆ្លងកាត់នេះ។

ប្រសិនបើ អ្នកមិនអាចបង្ហាញភស្តុតាងថា នីតិវិធីឆ្លងកាត់ដែលមានភាពសង្ស័យបានបញ្ចប់ក្រោមការត្រួតពិនិត្យរបស់គយ សូមផ្តល់រាល់ព័ត៌មានពាក់ព័ន្ធដែលអ្នកមាន ជាមួយនឹងភស្តុតាងជាឯកសារអម ជាពិសេសទីតាំង (ប្រទេស) ដែលដំណើរការឆ្លងកាត់បានបញ្ចប់។

សូមផ្តល់ព័ត៌មានទាំងនេះ <u>ក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីបានទទួលលិខិតនេះ</u> ប្រសិនបើ អ្នកមិនអាចផ្តល់ភស្តុតាងបញ្ជាក់ណាមួយអំពីប្រតិវេទន៍ខាងលើដែលបានបញ្ចប់ត្រឹមត្រូវ អ្នកនឹងទទួលខុសត្រូវចំពោះបំណុលគយពាក់ព័ន្ធនឹងទំនិញដែលបានប្រកាសក្រោមប្រតិវេទន៍ទាំងនេះ។

*(ការបញ្ចប់ដោយប្រើឃ្លាជាផ្លូវការ ឈ្មោះ និងអាសយដ្ឋានរដ្ឋបាលគយ)*

*ចម្លងជូន  អ្នកធានា (ឬភ្នាក់ងាររបស់ម្ចាស់ទំនិញ)*

## ឧបសម្ព័ន្ធ ១១គ÷ ជំនួយទៅវិញទៅមកសម្រាប់ការទូទាត់សំណង

១. សេចក្តីផ្តើម

នីតិវិធីក្នុងឧបសម្ព័ន្ធ ខ នឹងឆ្លើយសំណួរមួយចំនួនពាក់ព័ន្ធនឹងការមិនមកដល់ និងការមិនបញ្ចេញនៃដំណើរការឆ្លងកាត់ក្នុងករណីភាគច្រើន ហើយជាទូទៅម្ចាស់ទំនិញអាចផ្តល់ព័ត៌មានតាមលក្ខខណ្ឌតម្រូវ ព្រមទាំងបង្ហាញថា ការិយាល័យចេញដំណើរអាចបញ្ចេញដំណើរការឆ្លងកាត់ដែលស្ថិតក្រោមការសាកសួរ។

ដូចគ្នាផងដែរ នីតិវិធីដែលបានគូសបញ្ជាក់ក្នុងឧបសម្ព័ន្ធ ខ អាចប្រើសូម្បីតែក្នុងករណីសង្ស័យថា មានភាពមិនប្រក្រតី ឬរដ្ឋបាលគយថ្នាក់ជាតិបានកំណត់ថា មានភាពខុសគ្នាពីការិយាល័យចេញដំណើរ។

ក្នុងករណីដែលម្ចាស់ទំនិញមិនអាចផ្តល់ព័ត៌មានតាមលក្ខខណ្ឌតម្រូវបាន និងការទូទាត់មិនអាចធ្វើទៅបានដូចនេះ រដ្ឋបាលគយដែលរកឃើញភាពមិនប្រក្រតីចាត់ទុកថាជា អាជ្ញាធរគយដែលជាអ្នកដាក់ពាក្យសុំដូចបានបញ្ជាក់ក្នុងតារាងបញ្ជីសកម្មភាពរួម អាចប្រើបទប្បញ្ញត្តិជំនួយទៅវិញទៅមកនៃច្បាប់ ACTS យោងតាមការទាមទាររបស់អាជ្ញាធរគយពីម្ចាស់ទំនិញណាមួយ ដែលមានកិច្ចសហប្រតិបត្តិការយ៉ាងសកម្មជាមួយរដ្ឋបាលគយ ដែលម្ចាស់ទំនិញ និងអ្នកធានាស្ថិតនៅ ជាទូទៅគឺប្រទេសចេញដំណើរ ឬហៅថា អាជ្ញាធរគយទទួលសំណើ (Requested Customs Authority)។

ចូរកត់សម្គាល់ថា÷

1) រដ្ឋបាលគយមិនត្រូវចាប់ផ្តើមដំណើរការទាមទារចំនួននៃបំណុលគយពីអ្នកធានាឡើយ រហូតដល់មានវិធានការសមស្របដើម្បីទទួលបានបរិមាណសំណងពីម្ចាស់ទំនិញ និង
2) នៅពេលមានការស៊ើបអង្កេតនិងដោះស្រាយភាពមិនប្រក្រតី រដ្ឋបាលគយត្រូវត្រួតពិនិត្យកម្រិតនៃការអនុញ្ញាត នីតិវិធីសាមញ្ញ និងបរិមាណយោង ព្រមទាំងនិមុត្តិធានាដែលត្រូវបានកត់ត្រាលើធុរជនម្នាក់ដែលអាចមិនគោរពតាមកិច្ចសន្យា ឬមិនទូទាត់បំណុលគយ។
3) បញ្ជីសកម្មភាពរួម

| ល.រ | បញ្ហា | សកម្មភាព |
|---|---|---|
| ១ | ប្រទេសសមាជិកអាស៊ាន (AMS) កំណត់ថាដំណើរការឆ្លងកាត់មិនបានបញ្ចប់ពេញលេញនិងរកឃើញភាពមិនប្រក្រតីក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ហើយម្ចាស់ទំនិញស្ថិតក្នុង AMS និងមិនមានព័ត៌មាន និង/ឬមិនបានទទួលការទូទាត់បន្ទាប់ពីលទ្ធផលនៃនីតិវិធីសាកសួរ។<br>ហើយចំនុចទាំងអស់ខាងលើ ករណីអាជ្ញាធរគយដាក់សំណើ បានប្រើអស់លទ្ធភាពរាល់ | អាជ្ញាធរគយដាក់សំណើត្រូវទំនាក់ទំនងអាជ្ញាធរគយទទួលសំណើជាលាយលក្ខណ៍អក្សរ (សូមមើលក្នុងឧបសម្ព័ន្ធ ១១ឃ) សុំជំនួយក្នុងការបញ្ជាក់ថា ដំណើរការឆ្លងកាត់មួយបានបញ្ចប់ដោយគ្មានកំហុសឆ្គង ហើយប្រសិនបើមិនដូចនេះទេ ស្នើសុំឱ្យទូទាត់តាមចំនួនដែលបានទាមទារ។<br>អាជ្ញាធរគយដាក់សំណើជូនដំណឹងអ្នកធានា ឬភ្នាក់ងាររបស់អ្នកធានាតាមរយៈការិយាល័យប្រៃសណីយ៍ដែលបានចុះបញ្ជិកាដោយបញ្ជាក់ថា ការទាមទារសំណងអាចធ្វើឡើងនៅពេលខាងមុខ (សូមមើលឧបសម្ព័ន្ធ ១១ង) |

| | | |
|---|---|---|
| | បណ្ដាញស៊ើបអង្កេតទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដើម្បីរៀបចំអង្គហេតុ និងកំណត់ការទទួលខុសត្រូវ។ | ប្រសិនបើម្ចាស់ទំនិញមិនផ្ដល់ភស្ដុតាងអំពីការបញ្ចប់ ឬការទូទាត់បំណុល។ ការទាមទារសំណងនេះត្រូវថតចម្លងទៅឱ្យអាជ្ញាធរគយទទួលសំណើ។<br>អាជ្ញាធរគយទទួលសំណើ÷<br>ទំនាក់ទំនងម្ចាស់ទំនិញ កំណត់អង្គហេតុនៃករណី ចាត់តាំងបុគ្គល ឬក្រុមទទួលទទួលខុសត្រូវ និងផ្ញើសំណងប្រសិនបើជោគជ័យ។ |
| ២ | ប្រសិនបើម្ចាស់ទំនិញមិនរៀបចំ ភស្ដុតាង ឬទូទាត់ ឬមិនអាចទូទាត់ (ឧ. ក្នុងករណីក្ស័យធន) | អាជ្ញាធរគយទទួលសំណើណែនាំអាជ្ញាធរគយដាក់សំណើដែលស្នើសុំការទូទាត់បំណុលតាមរយៈភ្នាក់ងាររបស់អ្នកធានា[3] ក្នុងដែនរបស់អាជ្ញាធរគយដាក់សុំដោយប្រើទម្រង់ទាមទារសំណងក្នុងឧបសម្ព័ន្ធ ១១ច។ |

[3] ឬមន្ត្រីគយមានសមត្ថកិច្ចអាចធ្វើការទាមទារសំណងដោយផ្ទាល់ទៅកាន់អ្នកចេញនិមុត្តិធានា

## គំរូលិខិតរបស់អាជ្ញាធរគយដាក់សំណើផ្ញើទៅអាជ្ញាធរគយទទួលសំណើ

ឈ្មោះ និងព័ត៌មានទំនាក់ទំនងលម្អិតរបស់អាជ្ញាធរមានសមត្ថកិច្ចនៃអាជ្ញាធរគយដាក់សំណើ
..........................................................................................
..........................................................................................................

ទីតាំង និងកាលបរិច្ឆេទ ....................................................  ........................

ឈ្មោះ និងព័ត៌មានលម្អិតរបស់អាជ្ញាធរគយទទួលសំណើ ........................................................
..........................................................................................................

គោរពជូន ...........

ដោយអនុលោមតាមច្បាប់ឆ្លងកាត់គយអាស៊ាន អាជ្ញាធរគយសូមណែនាំ លោក/លោកស្រីថា អាជ្ញាធរគយមិនមានភស្តុតាង នៃការបញ្ចប់នីតិវិធីឆ្លងកាត់សម្រាប់ប្រតិវេទន៍ ដែលបានរៀបរាប់ខាងក្រោមពីការិយាល័យគយគម្យដ្ឋាននោះទេ (ឈ្មោះនិងអាសយដ្ឋាន)។

អាជ្ញាធរគយបានទំនាក់ទំនងម្ចាស់ទំនិញ (ឈ្មោះនិងអាសយដ្ឋាន) ប៉ុន្តែមិនបានទទួលការឆ្លើយតប/ការឆ្លើយតបមិនពេញតាមលក្ខខណ្ឌ។
*(សូមពន្យល់មូលហេតុ ប្រសិនបើ ការពន្យល់មិនពេញតាមលក្ខខណ្ឌ ហេតុផលសម្រាប់ការសាកសួរ និងផ្តល់ព័ត៌មានពាក់ព័ន្ធនានា) ។*

ព័ត៌មានលម្អិតនៃដំណើរការឆ្លងកាត់ មានដូចខាងក្រោម÷

លេខយោងប្រតិវេទន៍ឆ្លងកាត់គយអាស៊ាន (ARN)

ការបរិយាយទំនិញ

ក្រុមហ៊ុនដឹកជញ្ជូន (ប្រសិនបើខុសពីម្ចាស់ទំនិញ)

អ្នកផ្ញើទំនិញ (ប្រសិនបើខុសពីម្ចាស់ទំនិញ)

អ្នកទទួលទំនិញ

អ្នកធានា

ភ្នាក់ងារជាតិរបស់អ្នកធានា

ចំនួនទឹកប្រាក់សំណង (បំបែកជាការគណនាលម្អិត)

ឯកសារអមសម្រាប់ជាជំនួយសម្រាប់ការសាកសួររបស់ លោក/ លោកស្រី (ភ្ជាប់ឯកសារបើមាន ឬលុប)។

អាជ្ញាធរគយ សូមថ្លែងអំណរគុណ ប្រសិនបើ លោក/ លោកស្រី ទំនាក់ទំនងម្ចាស់ទំនិញជាបន្ទាន់ ដើម្បីទទួលបានព័ត៌មានលម្អិតពេញលេញ និងឯកសារដែលបញ្ជាក់ថា នីតិវិធីបានបញ្ចប់ត្រឹមត្រូវ។ ជាពិសេស អាជ្ញាធរ

គយក៏សូមថ្លែងអំណរគុណផងដែរ ប្រសិនបើ លោក/លោកស្រី អាចផ្តល់រាល់ការកែប្រែនានាដែលបានធ្វើឡើងក្នុងការិយាល័យគម្យដ្ឋាន និង/ ឬ ការិយាល័យឆ្លងកាត់ ឬឧប្បត្តិហេតុដែលបានកើតឡើងអំឡុងពេលឆ្លងកាត់។

ប្រសិនបើ លោក/លោកស្រី មិនអាចបង្ហាញភស្តុតាងថា នីតិវិធីឆ្លងកាត់ដែលមានសង្ស័យបានបញ្ចប់ត្រឹមត្រូវក្រោមការត្រួតពិនិត្យរបស់គយ សូមផ្តល់ព័ត៌មាននានាដែល លោក/លោកស្រីមានជាមួយឯកសារគាំទ្រ ជាពិសេសទីតាំង (ប្រទេស) ដែលដំណើរការឆ្លងកាត់បានបញ្ចប់។

ប្រសិនបើ មិនអាចបង្ហាញភស្តុតាងថា ប្រតិវេទន៍ខាងលើឱ្យបានត្រឹមត្រូវទេនោះ សូមលោក/លោកស្រីជូនដំណឹងរដ្ឋបាលគយឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ធ្វើដូចនេះដំណាក់កាលសមស្របអាចត្រូវបានអនុវត្តដើម្បីប្រមូលបំណុលគយមកវិញពីអ្នកធានា។

*(ការបញ្ចប់ដោយប្រើឃ្លាជាផ្លូវការ ឈ្មោះ និងអាសយដ្ឋានរដ្ឋបាលគយ)*

*ឈ្មោះ* ..........................................................................................................

*អាសយដ្ឋានរដ្ឋបាលគយ*..............................................

## ឧបសម្ព័ន្ធ ១១ខ៖ ការសាកសួរការបញ្ចប់ដំណើរការឆ្លងកាត់ (សម្រាប់អ្នកធានា)

**គំរូលិខិតរបស់អាជ្ញាធរគយដាក់សំណើផ្ញើទៅកាន់អ្នកធានា ក្នុងរយៈពេលកៅសិបថ្ងៃ (៩០ថ្ងៃ) នៃកាលបរិច្ឆេទការិយាល័យចេញដំណើរបានទទួលយកប្រតិវេទន៍គយ**

ឈ្មោះនិងព័ត៌មានទំនាក់ទំនងលម្អិតរបស់អាជ្ញាធរមានសមត្ថកិច្ចនៃអាជ្ញាធរគយដាក់សំណើ
..........................................................................................
..........................................................................................................

ទីតាំង និងកាលបរិច្ឆេទ..................................................... ........................

ឈ្មោះ និងព័ត៌មានលម្អិតរបស់អ្នកធានា (ឬភ្នាក់ងារ)........................................................
..........................................................................................................

គោរពជូន .........

ដោយអនុលោមតាមច្បាប់ឆ្លងកាត់គយអាស៊ាន អាជ្ញាធរគយសូមណែនាំ លោក/លោកស្រីថា អាជ្ញាធរគយមិនមានភស្តុតាងការបញ្ចប់នៃនីតិវិធីឆ្លងកាត់សម្រាប់ប្រតិវេទន៍ខាងក្រោម៖

- ម្ចាស់ទំនិញ (ឈ្មោះ និងអាសយដ្ឋាន)
- លេខយោងប្រតិវេទន៍ឆ្លងកាត់គយអាស៊ាន (ARN) និងកាលបរិច្ឆេទ
- លេខយោងនិមុត្តិធានា (GRN)
- ការបរិយាយទំនិញ
- ចំនួនទឹកប្រាក់សំណង (បំបែកជាការគណនាលម្អិត)

សម្រាប់ជាព័ត៌មានសម្រាប់ លោក/លោកស្រី លិខិតដែលបានភ្ជាប់មកជាមួយនេះ ជាលិខិតដែលបានផ្ញើទៅឱ្យម្ចាស់ទំនិញដោយបញ្ជាក់ថា អាជ្ញាធរគយមិនបានទទួលការឆ្លើយតប/ការឆ្លើយតបមិនពេញតាមលក្ខខណ្ឌសម្រាប់មូលហេតុដូចខាងក្រោម៖

សូមជម្រាបជូនថា បច្ចុប្បន្នរដ្ឋបាលគយយើងខ្ញុំធ្វើការទំនាក់ទំនងជាផ្លូវការ ជាមួយរដ្ឋបាលគយ XXXXX ក្នុងដែនរបស់ម្ចាស់ទំនិញរស់នៅ ដើម្បីជួយដល់រដ្ឋបាលគយយើងខ្ញុំជាមួយនឹងការសាកសួរមួយចំនួន។

ប៉ុន្តែលិខិតនេះសូមណែនាំដល់លោក/លោកស្រីជាផ្លូវការថា ជាអ្នកធានាចំពោះរដ្ឋបាលគយអាស៊ាន ក្នុងករណីនេះ ម្ចាស់ទំនិញមិនបានផ្តល់ភស្តុតាងថា ដំណើរការឆ្លងកាត់បានបញ្ចប់ត្រឹមត្រូវ ឬមិនបានទូទាត់បំណុលគយ អាស្រ័យហេតុនេះ រដ្ឋបាលគយនឹងសម្រេចក្នុងការទាមទារសំណងដែលបានទាមទារពី លោក/លោកស្រី ក្នុងនាមជាអ្នកធានា។

***ចំណាំ៖ នេះមិនមែនជាការទាមទារសំណងសម្រាប់បំណុលគយនោះទេ។***

*(ការបញ្ចប់ដោយប្រើឃ្លាជាផ្លូវការ ឈ្មោះ និងអាសយដ្ឋានរដ្ឋបាលគយ*

## ឧបសម្ព័ន្ធ ១១ច÷ ការទាមទារសំណងសម្រាប់ប្រមូលបំណុលគយមកវិញ

**គំរូលិខិតរបស់អាជ្ញាធរគយដាក់សំណើផ្ញើទៅកាន់អ្នកធានាដែលនឹងត្រូវផ្ញើក្នុងរយៈពេលពីរយចិតសិប (២៧០ថ្ងៃ) នៃកាលបរិច្ឆេទបន្ទាប់ពីការិយាល័យចេញដំណើរបានទទួលយកប្រតិវេទន៍ឆ្លងកាត់គយ នឹងផ្ញើជូនតាមរយៈគ្នាក់ងារធនាគាររបស់អ្នកធានា**[4]

ឈ្មោះនិងព័ត៌មានទំនាក់ទំនងលម្អិតរបស់អាជ្ញាធរមានសមត្ថកិច្ចនៃអាជ្ញាធរគយដាក់សំណើ

..........................................................................................................

ទីតាំង និងកាលបរិច្ឆេទ....................................................... ........................

ឈ្មោះ និងព័ត៌មានលម្អិតរបស់អ្នកធានា (ឬភ្នាក់ងារ) .............................................................

គោរពជូន ...

ដោយអនុលោមតាមច្បាប់ឆ្លងកាត់គយអាស៊ាន អាជ្ញាធរគយសូមណែនាំ លោក/លោកស្រីថា អាជ្ញាធរគយមិនមានភស្តុតាងការបញ្ចប់នៃនីតិវិធីឆ្លងកាត់សម្រាប់ប្រតិវេទន៍ខាងក្រោម÷

ម្ចាស់ទំនិញ (ឈ្មោះ និងអាសយដ្ឋាន)

លេខយោងប្រតិវេទន៍ឆ្លងកាត់គយអាស៊ាន (ARN) និងកាលបរិច្ឆេទ

លេខយោងនិមុត្តិធានា (GRN)

ការបរិយាយទំនិញ

ចំនួនទឹកប្រាក់ទាមទារសំណងក្នុងរូបិយវត្ថុនៃអាជ្ញាធរគយដាក់សំណើ

ចំនួនទឹកប្រាក់ទាមទារសំណងក្នុងរូបិយវត្ថុនៃការអនុវត្តនិមុត្តិធានា - នឹងត្រូវប្តូរតាមកាលបរិច្ឆេទបច្ចុប្បន្ន

សម្រាប់ជាព័ត៌មាន ខ្ញុំសូមភ្ជាប់មកជាមួយលិខិតដែលបានផ្ញើទៅកាន់ម្ចាស់ទំនិញ។ ម្ចាស់ទំនិញមិនបានទូទាត់បំណុលគយ។

នេះជាការទាមទារសំណងជាផ្លូវការទាមទារពីលោក/លោកស្រី ដែលជាអ្នកធានាចំពោះរដ្ឋបាលគយអាស៊ាន នូវចំនួនទឹកប្រាក់ដែលបានបញ្ជាក់ខាងលើ។

សូមធ្វើការទូទាត់នេះតាមរយៈធនាគារខាងក្រោមក្នុងរយៈពេល ៣០ថ្ងៃ ចាប់ពីកាលបរិច្ឆេទទទួលបានលិខិតទាមទារសំណងនេះ÷

ឈ្មោះធនាគារ÷

អាសយដ្ឋានធនាគារ÷

លេខគណនីធនាគារ÷

លេខកូដ SWIFT / IBAN ÷

*(ការបញ្ចប់ដោយប្រើឃ្លាជាផ្លូវការ ឈ្មោះ និងអាសយដ្ឋានរដ្ឋបាលគយ)*

---

[4] ឬមន្ត្រីគយមានសមត្ថកិច្ចអាចធ្វើការទាមទារសំណងដោយផ្ទាល់ទៅកាន់អ្នកចេញនិមុត្តិធានា

# ផ្នែកទី១២÷ ការពន្យល់នីតិវិធីគយក្នុងទម្រង់ជាតារាងវំហូរនីតិវិធី

## ១. នីតិវិធីគយតាមប្រព័ន្ធ ACTS - តារាងវំហូរនីតិវិធី

ឧបសម្ព័ន្ធនេះជាសេចក្តីសង្ខេបនៃដំណើរការ និងនីតិវិធីប្រព័ន្ធ ACTS នៃសៀវភៅណែនាំ ស្តីពីនីតិវិធីគយ។ សេចក្តីសង្ខេបនេះបង្ហាញតាមរយៈតារាងវំហូរ ជាវិធីសាស្ត្រដែលគេនិយមប្រើក្នុងការបំបែកទៅជាផ្នែកផ្សេងៗដាច់ដោយឡែក ដោយសារតែដំណើរការនេះមានលក្ខណៈប្រទាក់ក្រឡាគ្នានឹងស្មុគស្មាញ នៅពេលពិនិត្យមើលជាដំណើរការទាំងមូល។ តារាងវំហូរជាមួយនឹងការពន្យល់សង្ខេបនៃសកម្មភាព ឬដំណើរការនីមួយៗមានគោលបំណងជួយពន្យល់នីតិវិធីមូលដ្ឋាន និងមធ្យោបាយនានាពាក់ព័ន្ធនឹងការគ្រប់គ្រងដំណើរការឆ្លងកាត់គយអាស៊ានដោយប្រព័ន្ធ ACTS។

ជាទូទៅ គោលការណ៍ និងនីតិវិធីនៃការឆ្លងកាត់អន្តជាតិមានលក្ខណៈដូចគ្នា ដោយមិនគិតថា ជាការគ្រប់គ្រង និងការត្រួតពិនិត្យដោយក្រដាស ឬប្រព័ន្ធកុំព្យូទ័រឡើយ។ តារាងនៅទំព័រទី ៣ រូបភាពទី២÷ ទិដ្ឋភាពទូទៅនៃនីតិវិធី ឬដំណើរការ គឺមានលក្ខណៈដូចគ្នាទៅនឹងប្រព័ន្ធដំណើរការដោយកុំព្យូទ័រ ឬក្រដាសក្នុងការរៀបចំដំណើរការគោល។

### ១.១. ស្វែងយល់អំពីសញ្ញាតារាងវំហូរ

តារាងវំហូរត្រូវបានប្រើជាច្រើនទាំងក្នុងវិស័យឯកជន និងរដ្ឋ ដើម្បីវិភាគនិងកត់ត្រាដំណើរការត្រួតពិនិត្យសុពលភាពនៃការរៀបចំដំណើរការ និងដើម្បីធានាថា នីតិវិធីសមស្របត្រូវបានអនុវត្តតាមក្នុងប្រតិបត្តិការរបស់ស្ថាប័ន។ មូលហេតុម្យ៉ាងទៀតក្នុងការប្រើប្រាស់តារាងនេះគឺ ប្រើសម្រាប់ជាមធ្យោបាយដើម្បីពន្យល់ឱ្យកាន់តែងាយស្រួលយល់។ តារាងវំហូរប្រើរូបសញ្ញាពិសេសៗតំណាងប្រភេទសកម្មភាព ឬដំណាក់កាលផ្សេងៗក្នុងដំណើរការមួយ។ បន្ទាត់ និងសញ្ញាព្រួញបង្ហាញលំដាប់លំដោយនៃដំណាក់កាល និងទំនាក់ទំនងរបស់វា។ ជារួម ការប្រើប្រាស់រូបសញ្ញាក្នុងតារាងវំហូរអនុលោមទៅតាមស្តង់ដារអន្តរជាតិដែលគេទទួលស្គាល់។

ប្រសិនបើ អ្នកមិនយល់អំពីរបៀបប្រើរូបសញ្ញានៃតារាងវំហូរ ការធ្វើតារាង និងការពន្យល់នៃការប្រើប្រាស់ក្នុងផ្នែកនេះរបស់សៀវភៅណែនាំនៅទំព័របន្ទាប់។

### ១.២. ដំណើរការប្រព័ន្ធ

ទិដ្ឋភាពទូទៅនៃច្រកដំណើរការសំខាន់ៗនៃប្រព័ន្ធ ACTS និងតារាងនីមួយៗដែលគូសបញ្ជាក់អំពីរបៀបដែលដំណើរការប្រព័ន្ធ ACTS ជួយមន្ត្រីគយត្រួតពិនិត្យដំណើរការឆ្លងកាត់។ ដំណើរការទាំងនេះពិពណ៌នាដូចខាងក្រោម÷

**តារាង÷**

- នីតិវិធីទទួលប្រតិវេទន៍
- ត្រួតពិនិត្យ នីតិវិធីធម្មតា
- ត្រួតពិនិត្យ នីតិវិធីសាមញ្ញ
- ដំណើរការនៅការិយាល័យចេញដំណើរ បញ្ចេញទំនិញសម្រាប់ឆ្លងកាត់

- ការចុះបញ្ជីនិមុត្តិធានា
- ដំណើរការនៅការិយាល័យឆ្លងកាត់
- ដំណើរការមកដល់ នីតិវិធីធម្មតា
- ដំណើរការមកដល់ នីតិវិធីសាមញ្ញ
- ការប្រើប្រាស់និមុត្តិធានា
- នីតិវិធីសាកសួរដំណើង
- នីតិវិធីទារបំណុល

តារាងទាំងនេះបង្ហាញអំពីនីតិវិធីគយសំខាន់ៗ។ ដំណើរការតូចៗ ដូចជា ការគ្រប់គ្រងនិមុត្តិធានា ការបង្វែរ ការលុបចោលប្រតិវេទន៍ ការសាកសួរ និងការប្រមូលពន្ធនិងអាករមកវិញ និងមានពិពណ៌នាដោយសង្ខេបផងដែរ។ ទោះបីជាតារាងវិហ្វូរទាំងនេះមើលទៅមានលក្ខណៈស្មុគស្មាញ ប៉ុន្តែអ្វីដែលសំខាន់ត្រូវទទួលស្គាល់ថា អ្នកប្រើប្រាស់ប្រព័ន្ធ ACTS នៃនីតិវិធីគយ ប្រើប្រាស់វានៅពេលដែលធ្វើការជាមួយដំណើរការដែលពាក់ព័ន្ធនឹងភារកិច្ច ឬការទទួលខុសត្រូវរបស់ខ្លួនតែប៉ុណ្ណោះ។

### ១.៣. រូបសញ្ញាប្រើក្នុងតារាងវិហ្វូរទាំងនេះ

| សញ្ញា | ការពិពណ៌នា | ឧទាហរណ៍ |
|---|---|---|
|  | ចាប់ផ្តើម ឬបញ្ចប់ដំណើរការ | ប្រតិបត្តិករដឹកជញ្ជូនរៀបចំប្រតិវេទន៍ឆ្លងកាត់<br>ដំណើរការឆ្លងកាត់បានបញ្ចប់ និងម្ចាស់ទំនិញបានទទួលការជូនដំណឹងអំពីការបញ្ចប់ប្រតិបត្តិការឆ្លងកាត់ |
|  | សម្រេចចិត្តដោយមន្ត្រីគយ ឬដោយប្រព័ន្ធ ផ្អែកលើព័ត៌មានរក្សាទុកក្នុងប្រព័ន្ធ ឬព័ត៌មានបញ្ចូលក្នុងប្រព័ន្ធ | មន្ត្រីគយសម្រេចចិត្តត្រួតពិនិត្យ ឬមិនត្រួតពិនិត្យដំណើរការឆ្លងកាត់ (“បាទ” ឬ “ទេ”)។ ប្រព័ន្ធ ACTS បដិសេធដោយសារតែព័ត៌មានចាំបាច់មិនមានក្នុងប្រតិវេទន៍ |
|  | ដំណើរការដោយស្វ័យប្រវត្តិ ផ្អែកលើព័ត៌មានរក្សាទុកក្នុងប្រព័ន្ធ ជាទូទៅរួមបញ្ចូលព័ត៌មាន ឬទិន្នន័យដែលបញ្ចូលដោយអ្នកប្រើប្រាស់ | ការផ្ទៀងផ្ទាត់ប្រតិវេទន៍ផ្អែកលើលក្ខខណ្ឌតម្រូវដែលបានកំណត់ជានីតិវិធីធម្មតា ឬនីតិវិធីសាមញ្ញ ប្រភេទទំនិញ តម្រាយផ្លូវឆ្លងកាត់ និងគម្យដ្ឋាន។<br>ការគណនាបំណុលគយ ផ្អែកលើពន្ធ/អាករអតិបរមាសម្រាប់ប្រទេសឆ្លងកាត់ |
|  | ឯកសារផ្លូវការ ជាអេឡិចត្រូនិក ឬជាទម្រង់ក្រដាស | ប្រតិវេទន៍ឆ្លងកាត់ ACTS<br>ប្រតិវេទន៍អមដំណើរឆ្លងកាត់ TAD |
|  | ការបញ្ចូលទិន្នន័យដោយប្រើក្តារចុច ឬម៉ាស៊ីនស្កែនបារកូដ។ | ការបញ្ចូលប្រតិវេទន៍របស់ម្ចាស់ទំនិញ<br>ការបញ្ចូលរបាយការណ៍ត្រួតពិនិត្យរបស់មន្ត្រីគយ |

| | | |
|---|---|---|
| | បង្ហាញសារនៅលើអេក្រង់  ឬ ប្រព័ន្ធបោះពុម្ពចេញ | ការិយាល័យឆ្លងកាត់ប្រើម៉ាស៊ីនស្កែនបារកូដលើ TAD។ មន្ត្រីគយ ឬម្ចាស់ទំនិញបោះពុម្ព TAD ជាទម្រង់ក្រដាស |
|   | ប្រើព័ត៌មានទាំងអស់រក្សាទុកក្នុងប្រព័ន្ធសម្រាប់ផ្ទៀងផ្ទាត់ទិន្នន័យប្រតិវេទន៍ និងសម្រាប់កត់ត្រា និងត្រួតពិនិត្យដំណើរការឆ្លងកាត់។ | រួមមាន ការរក្សាទិន្នន័យតារាង និងវិធានគ្រប់គ្រងហានិភ័យសម្រាប់ផ្ទៀងផ្ទាត់។ ប្រតិវេទន៍ជាក់លាក់ណាមួយ និងព្រឹត្តិការពាក់ព័ន្ធ និងព័ត៌មានលម្អិតនិមុត្តិធានា និងការប្រើប្រាស់ ជាដើម |
|   | ប្រសិនបើប្រព័ន្ធចង់ចូលទៅដំណើរការមួយទៀតដើម្បីបញ្ចប់នីតិវិធី ឧបករណ៍ភ្ជាប់នឹងណែនាំ Reader ទៅកាន់ដ្យាក្រាមមួយទៀត ដោយរៀបរាប់ថាដំណើរការដទៃទៀត។ | ធ្វើឱ្យតារាងវិហ្វូរមានភាពងាយស្រួលមើល ដោយបំបែកតារាងទៅជាផ្នែកតូចៗ និងងាយស្រួលអាន ជាមួយឧបករណ៍ភ្ជាប់ (Connector) បំបែកទៅជាដំណើរការទី ២ ហើយលទ្ធផលពីដំណើរការទី២ បញ្ជូនទៅកាន់ដំណើរការទី១ វិញដោយឧបករណ៍ភ្ជាប់ (Connector) មួយទៀត។<br>និមុត្តិធានាជាឧទាហរណ៍មួយដ៏ល្អ ជាមួយនឹងការត្រួតពិនិត្យថា មានសុពលភាព ឬអត់។ |
|  | ព្រួញទិសដៅ | បង្ហាញវិហ្វូរតាមរយៈដំណើរការ ពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត |

## ១.៤. ទិដ្ឋភាពទូទៅនៃវិហ្សនីតិវិធីសំខាន់ៗ

| ម្ចាស់ទំនិញ/ធុរជន | ប្រព័ន្ធ ACTS | គយ | កំណត់សម្គាល់ |
|---|---|---|---|




រូបភាពទី២: ទិដ្ឋភាពទូទៅនៃវិហ្សនីតិវិធីប្រព័ន្ធ ACTS

ដ្យាក្រាមនេះពន្យល់អំពីទិដ្ឋភាពទូទៅនៃវិហ្សនីតិវិធីសំខាន់ៗនៃប្រព័ន្ធ ACTS ប៉ុន្តែដ្យាក្រាមនេះមិនបង្ហាញនូវដំណើរការតូចៗនោះទេ ដូចជាការកែតម្រូវនានា

- ការផ្ទៀងផ្ទាត់ប្រតិវេទន៍ ការទទួលយក និងដំណើរការផ្ទៀងផ្ទាត់
- ការវិភាគហានិភ័យ
- ព័ត៌មានលម្អិតដំណើរការត្រួតពិនិត្យនៅការិយាល័យចេញដំណើរ និងការិយាល័យគម្យដ្ឋាន
- ការគ្រប់គ្រងនិមុត្តិធានា
- ការចាត់ចែងលទ្ធផលត្រួតពិនិត្យ
- ការបង្វែរទំនិញឆ្លងកាត់
- ដំណើរការសាកសួរ ឬទាមទារសំណង។

ដំណើរការសំខាន់ៗមានពន្យល់ដូចខាងក្រោម÷

1. រដ្ឋបាលនៃប្រព័ន្ធ ACTS
2. ការរៀបចំប្រតិវេទន៍ឆ្លងកាត់អេឡិចត្រូនិកតាមប្រព័ន្ធ ACTS និងការផ្តល់និមុត្តិធានា
3. ដំណើរប្រព័ន្ធ ACTS ក្នុងការទទួលយកប្រតិវេទន៍
4. ដំណើរការនៅការិយាល័យចេញដំណើរ
5. ប្រតិវេទន៍អមដំណើរឆ្លងកាត់ (TAD) និងការចាប់ផ្តើមដំណើរការឆ្លងកាត់
6. ដំណើរការនៅការិយាល័យគយឆ្លងកាត់
7. ដំណើរការមកដល់នៅការិយាល័យគម្យដ្ឋាន
8. ការបញ្ចេញទំនិញសម្រាប់ឆ្លងកាត់ និងការបញ្ចេញដំណើរការឆ្លងកាត់ទៅដំណាក់កាលបន្ទាប់ក្នុងប្រព័ន្ធ ACTS។

## ១.៥. ដំណើរការទទួលយកប្រតិវេទន៍ ACTS

| ម្ចាស់ទំនិញ/ ធុរជន | ប្រព័ន្ធ ACTS | គយ | កំណត់សម្គាល់ |
|---|---|---|---|




រូបភាពទី៣: ការទទួលយកដោយប្រព័ន្ធ ACTS

1. ទិន្នន័យប្រតិវេទន៍បានបញ្ជូនតាមអេឡិចត្រូនិក ក្នុងទម្រង់ដែលបានព្រមព្រៀង
2. សម្រាប់នីតិវិធីពេលប្រព័ន្ធមិនដំណើរការ ដាក់ប្រតិវេទន៍ និងដំណើរការដោយដៃ ប្រតិវេទន៍ត្រូវបញ្ចូលទៅក្នុងប្រព័ន្ធ ACTS នៅពេលប្រព័ន្ធដំណើរការឡើងវិញ។ ម្ចាស់ទំនិញត្រូវផ្តល់លេខចុះបញ្ជិកាធុរជន (TRN) ដើម្បីឱ្យម្ចាស់ទំនិញ ឬការិយាល័យចេញដំណើរយោងទិន្នន័យក្នុងប្រព័ន្ធ ACTS
3. ប្រតិវេទន៍ត្រូវបានត្រួតពិនិត្យផ្ទៀបនឹងទម្រង់ប្រតិវេទន៍អេឡិចត្រូនិក លក្ខខណ្ឌតម្រូវការទិន្នន័យ រួមមាន ការត្រួតពិនិត្យជាមួយការិយាល័យគ្រប់គ្រងនិមុត្តិធានា (ក) និង (ខ) ដែលនិមុត្តិធានាមានស្រាប់ និងមានសុពលភាពសម្រាប់ប្រើប្រាស់។ ប្រព័ន្ធ ACTS បដិសេធប្រតិវេទន៍ដែលមិនមានសុពលភាព និងជូនដំណឹងធុរជនអំពីមូលហេតុសម្រាប់ការបដិសេធប្រតិវេទន៍
4. ក្រោមនីតិវិធីធម្មតា ការបង្ហាញទំនិញត្រូវធ្វើនៅការិយាល័យចេញដំណើរ
5. ប្រសិនបើ ម្ចាស់ទំនិញអះអាងថា ជាប្រតិបត្តិករឆ្លងកាត់ទទួលបានការអនុញ្ញាត (ATT) ប្រព័ន្ធ ACTS នឹងពិនិត្យថាតើ ម្ចាស់ទំនិញទទួលបានការអនុញ្ញាតឱ្យប្រើនីតិវិធីសាមញ្ញ ប្រភេទទំនិញ (មិនស្ថិតក្នុងបញ្ជីទំនិញហាមឃាត់/ជាប់កម្រិតកំណត់/ដកចេញពីការឆ្លងកាត់) ទីតាំងនិងសៀលដែលបានអនុញ្ញាត និងការិយាល័យបានកំណត់ថា មិនមានហានិភ័យ

6. ប្រសិនបើមិនអនុញ្ញាតឱ្យប្រើនីតិវិធីសាមញ្ញ ឬប្រសិនបើ បានប្រកាសថា ទីតាំងដាក់ទំនិញដែលបាន អនុញ្ញាតលែងមានសុពលភាព ឬសៀលមិនមានសុពលភាព ដូចនេះប្រព័ន្ធ ACTS នឹងបដិសេធ ប្រតិវេទន៍ និងជូនដំណឹងម្ចាស់ទំនិញ

*ចំណាំ ÷ នៅពេលប្រតិវេទន៍មានសុពលភាព ការិយាល័យចេញដំណើរទទួលយកប្រតិវេទន៍នោះ។*

7. លេខ ARN ថ្មី (លេខយោងប្រតិវេទន៍ឆ្លងកាត់គយអាស៊ាន) ត្រូវបានបង្កើតដោយស្វ័យប្រវត្តិ។ ARN ថ្មីនេះនឹងបែងចែកទៅឱ្យប្រតិបត្តិការឆ្លងកាត់ និងផ្ញើទៅឱ្យធុរជន។ ប្រសិនបើ មានហានិភ័យ មន្ត្រីគយនឹងទទួលបានសារក្រើនរំលឹកសម្រាប់ការធ្វើអន្តរាគមន៍ និងការសម្រេចចិត្តត្រួតពិនិត្យ (គ) ។ នៅពេលប្រតិវេទន៍ស្ថិតក្រោមនីតិវិធីសាមញ្ញ ការកំណត់ពេលវេលា “រង់ចាំបញ្ចេញដោយស្វ័យប្រវត្តិ” បានចាប់ផ្តើម ស្ថានភាពប្រតិវេទន៍និងត្រូវបានបញ្ចេញដោយស្វ័យប្រវត្តិបន្ទាប់ពីផុតម៉ោងកំណត់។

## ១.៦. ការត្រួតពិនិត្យប្រតិវេទន៍តាមប្រព័ន្ធ ACTS ក្រោមនីតិវិធីធម្មតា

| ម្ចាស់ទំនិញ/ ធុរជន | ប្រព័ន្ធ ACTS | គយ | កំណត់សម្គាល់ |
|---|---|---|---|




រូបភាពទី៤: ការត្រួតពិនិត្យធម្មតាតាមប្រព័ន្ធ ACTS

1. ព័ត៌មាននៃដំណើរការឆ្លងកាត់ដែលបានមកពីប្រព័ន្ធ ACTS តាមរយៈការស្វែងរក ARN និងលទ្ធផលនៃការវិភាគហានិភ័យបញ្ជាក់ថា ទំនិញមិនគួរបញ្ចេញ បន្ទាប់មកប្រព័ន្ធ ACTS ក្រើនរំលឹកដល់មន្ត្រីគយ។ ទោះបីជាការវិភាគហានិភ័យជាដំណើរការស្វ័យប្រវត្តិក៏ដោយ ប៉ុន្តែការសម្រេចចិត្តចុងក្រោយក្នុងការត្រួតពិនិត្យគឺស្ថិតលើមន្ត្រីគយ
2. ប្រសិនបើ មន្ត្រីគយសម្រេចចិត្តមិនត្រួតពិនិត្យទំនិញ និង/ ឬឯកសារអម មន្ត្រីគយត្រូវកត់ត្រាការសម្រេចនេះក្នុងប្រព័ន្ធ ACTS
3. ប្រសិនបើ លទ្ធផលត្រួតពិនិត្យរបស់ការិយាល័យគយចេញដំណើរចាត់ទុកថា គ្មានកំហុសឆ្គង
4. ដំណើរការរៀបចំចុះបញ្ជិកាប្រើប្រាស់និមុត្តិធានា (ឃ) ធ្វើការគណនាបំណុលគយ
5. (មិនមានបរិយាយ)
6. មន្ត្រីគយសម្រេចត្រួតពិនិត្យ និងបានចារលទ្ធ-ផលត្រួតពិនិត្យក្នុងប្រព័ន្ធ។ ការត្រួតពិនិត្យត្រូវអនុវត្តនៅការិយាល័យចេញដំណើរ (ប្រសិនបើការវិភាគហានិភ័យបានស្នើឱ្យចាត់វិធានការនៅការិយាល័យចេញដំណើរ ប៉ុន្តែមន្ត្រីគយសម្រេចចិត្តមិនត្រួតពិនិត្យ ដូចនេះ ប្រព័ន្ធតម្រូវឱ្យមន្ត្រីគយបញ្ជាក់អំពីការសម្រេចចិត្តនេះ)
7. ប្រព័ន្ធនឹងជូនដំណឹងម្ចាស់ទំនិញអំពីការសម្រេចចិត្តត្រួតពិនិត្យនេះ ដើម្បីអនុញ្ញាតឱ្យម្ចាស់ទំនិញបង្ហាញទំនិញអំឡុងពេលត្រួតពិនិត្យ (ការិយាល័យចេញដំណើរឈប់ទទួលយកការកែតម្រូវប្រតិវេទន៍)

8. មន្ត្រីគយផ្ទៀងផ្ទាត់ទំនិញ និង/ឬឯកសារអម និង/ឬសៀលនៅកន្លែងដាក់ទំនិញដោយផ្ទាល់
9. មន្ត្រីគយទៅកន្លែងដាក់ទំនិញ (ដូចបានបញ្ជាក់) ដើម្បីផ្ទៀងផ្ទាត់ឯកសារ ទំនិញ (ឬទាំងពីរ) ដោយយកទៅជាមួយនូវប្រតិវេទន៍ដែលបានទទួលយកជាទម្រង់ក្រដាស។ មន្ត្រីគយត្រួតពិនិត្យទំនិញធៀបនឹងព័ត៌មានលម្អិត (៥) នៃប្រតិវេទន៍ដែលបានទទួលយក។ មន្ត្រីគយកិបសៀល ឬកិបសៀលម្តងទៀត
10. នៅពេលរកឃើញកំហុសឆ្គងបន្តិចបន្តួច មន្ត្រីគយទំនាក់ទំនងម្ចាស់ទំនិញ។ ក្រោយមក ម្ចាស់ទំនិញសម្រេចថាតើម្ចាស់ទំនិញឯកភាព (មិនជំទាស់) ដែរឬទេជាមួយនឹងការកែតម្រូវនេះ។ ម្ចាស់ទំនិញអាចផ្តល់យោបល់ ការបដិសេធភ្លាមៗ ឬនៅពេលក្រោយនៅពេលដែលម្ចាស់ទំនិញមិនអាចឆ្លើយតបនៅពេលនោះ។ ដោយមានការអនុញ្ញាតពីគយ ម្ចាស់ទំនិញអាចកែតម្រូវប្រតិវេទន៍
11. នៅពេលលទ្ធផលត្រួតពិនិត្យបង្ហាញថាគ្មានកំហុសឆ្គង ឬបន្ទាប់ពីការកែតម្រូវ និងការត្រួតពិនិត្យឡើងវិញឃើញថាសមស្របក្រោយកែតម្រូវ លទ្ធផលត្រួតពិនិត្យថា “គ្មានកំហុសឆ្គង” បានចុះបញ្ជី

*ចំណាំ៖ នៅពេលរកឃើញកំហុសឆ្គងបន្តិចបន្តួច ហើយម្ចាស់ទំនិញផ្តល់យោបល់ភ្លាមៗ ដោយជំទាស់លើការកែតម្រូវ (ដូចជា ម្ចាស់ទំនិញមិនព្រមកែតម្រូវ) ដំណើរការឆ្លងកាត់នឹងមិនអាចបញ្ចេញបាន។ មន្ត្រីគយកត់ត្រាទំនិញដែលបានត្រួតពិនិត្យ និងបញ្ចូលទិន្នន័យប្រតិវេទន៍ដោយផ្អែកលើលទ្ធផលត្រួតពិនិត្យ។ ប្រតិវេទន៍នេះត្រូវចាត់ទុកថា មិនមានសុពលភាព និងត្រូវរង់ចាំរហូតដល់មានវិធានការបន្ថែមទៀត។*

*ចំណាំ៖ ក្នុងករណីរកឃើញកំហុសឆ្គងបន្តិចបន្តួចអំឡុងពេលត្រួតពិនិត្យទំនិញនិង/ឬឯកសារអម ហើយម្ចាស់ទំនិញមិនទាន់បានផ្តល់យោបល់លើការកែតម្រូវនេះទេ ពេលវេលាកំណត់ “រង់ចាំសម្រាប់សំណើបញ្ចេញទំនិញ” បានចាប់ផ្តើមការពារសំណើមិនបញ្ចេញទំនិញដែលបានមកពីម្ចាស់ទំនិញ។ មន្ត្រីគយកត់ត្រាទំនិញដែលបានត្រួតពិនិត្យ និងកែតម្រូវទិន្នន័យប្រតិវេទន៍។*

12. ប្រសិនបើរកឃើញកំហុសឆ្គងធំ ឬមានហេតុផលសមស្របសម្រាប់ឱ្យការិយាល័យចេញដំណើរពិចារណាឃើញថា ការអនុញ្ញាតឱ្យឆ្លងកាត់អាចបង្កឱ្យមានហានិភ័យធ្ងន់ធ្ងរដល់សុវត្ថិភាព និងសន្តិសុខនៃប្រទេសពាក់ព័ន្ធ ទំនិញដែលបានត្រួតពិនិត្យដែលមានកំហុសឆ្គងធំ និងលទ្ធផលត្រួតពិនិត្យថាមានកំហុសឆ្គងត្រូវបានចុះបញ្ជី។ ការិយាល័យចេញដំណើរជូនដំណឹងម្ចាស់ទំនិញថា ដំណើរការឆ្លងកាត់នេះគឺមិនអនុញ្ញាតឡើយ ហើយអាចរងនូវទោសទណ្ឌតាមបទប្បញ្ញត្តិជាធរមាន។

## ១.៧. ការត្រួតពិនិត្យប្រតិវេទន៍តាមប្រព័ន្ធ ACTS ក្រោមនីតិវិធីសាមញ្ញ

| ម្ចាស់ទំនិញ/ ធុរជន | ប្រព័ន្ធ ACTS | គយ | កំណត់សម្គាល់ |
|---|---|---|---|




រូបភាពទី៥: ការត្រួតពិនិត្យក្រោមនីតិវិធីសាមញ្ញ តាមប្រព័ន្ធ ACTS

1. ក្រោយពីទទួលយកប្រតិវេទន៍ក្រោមនីតិវិធីសាមញ្ញ រួចហើយ ការកំណត់ពេលវេលាបញ្ចេញដោយស្វ័យប្រវត្តិត្រូវបានចាប់ផ្តើម។ ដូចនេះ ការត្រួតពិនិត្យនេះត្រូវបញ្ចប់ក្នុងរយៈពេលព្រមព្រៀងដែលបានបញ្ជាក់ក្នុងការអនុញ្ញាតនៃនីតិវិធីសាមញ្ញ
2. ប្រសិនបើ លទ្ធផលវិភាគហានិភ័យបញ្ជាក់ថា ទំនិញមិនគួរបញ្ចេញពីការិយាល័យចេញដំណើរ ឬមានហេតុផលនៃកង្វល់ណាមួយសម្រាប់ការិយាល័យចេញដំណើរ ដូចនេះប្រព័ន្ធ ACTS ក្រើនរំលឹកមន្ត្រីគយ
3. ទីបំផុត មន្ត្រីគយសម្រេចចិត្តត្រួតពិនិត្យ
4. ការសម្រេចចិត្តត្រួតពិនិត្យ ឬមិនត្រួតពិនិត្យត្រូវកត់ត្រាចូលក្នុងប្រព័ន្ធ ACTS
5. ការកំណត់ពេលវេលារង់ចាំបញ្ចេញដោយស្វ័យប្រវត្តិត្រូវបានបញ្ឈប់
6. បំណុលពន្ធនិងអាករត្រូវគណនានៅពេលដំណើរការរៀបចំចុះបញ្ជិកាប្រើប្រាស់និមុត្តិធានា (ឃ)
7. ដើម្បីត្រួតពិនិត្យដំណើរការឆ្លងកាត់ មន្ត្រីគយអាចស្នើសុំលិខិតថតចម្លងនៃព័ត៌មានលម្អិតប្រតិវេទន៍
8. ការត្រួតពិនិត្យ រួមមាន ការត្រួតពិនិត្យឯកសារ និងទំនិញនៅទីតាំងដាក់ទំនិញដែលបានអនុញ្ញាត ក្នុងពេលវេលាដែលបានកំណត់នៃការអនុញ្ញាត។ មន្ត្រីគយកិបសៀល ឬកិបសៀលឡើងវិញ
9. នៅពេលរកឃើញកំហុសឆ្គងបន្តិចបន្តួច ហើយម្ចាស់ទំនិញឯកភាព
10. ម្ចាស់ទំនិញកែតម្រូវប្រតិវេទន៍ បើមិនដូចនេះទេ ដំណើរការឆ្លងកាត់នឹងមិនអាចបញ្ចេញបាន រហូតដល់មានដំណោះស្រាយ

11. ប្រសិនបើ ការត្រួតពិនិត្យបង្ហាញថា គ្មានភាពមិនប្រក្រតី
12. លទ្ធផលនៃសម្រេចចិត្តដែលបញ្ជាក់ថា “ មិនមានកំហុសឆ្គង” ត្រូវបានកត់ត្រាទុកប្រព័ន្ធ ACTS
13. នៅពេលការត្រួតពិនិត្យរកឃើញកំហុសឆ្គងធំ មន្ត្រីគយការិយាល័យចេញដំណើរនឹងកត់ត្រាលទ្ធផលនៃការត្រួតពិនិត្យថា មានកំហុសឆ្គង “Unsatisfactory” ។

## ១.៨. ដំណើរការនៅការិយាល័យចេញដំណើរ ការបញ្ចេញទំនិញសម្រាប់ឆ្លងកាត់

| ម្ចាស់ទំនិញ/ ធុរជន | ប្រព័ន្ធ ACTS | គយ | កំណត់សម្គាល់ |
|---|---|---|---|




រូបភាពទី៦: ការបញ្ចេញនៅការិ. ចេញដំណើរ ACTS

1. និមុត្តិធានាអាចត្រូវត្រួតពិនិត្យ និងចុះបញ្ជិកា
2. ពន្ធ និងអាករបានគណនាផ្អែលើពន្ធនិងអាករខ្ពស់បំផុតដែលអាចទូទាត់បានតាមតម្រាយផ្លូវ។ បរិមាណដែលបានគណនារួចត្រូវបានចុះបញ្ជីក្នុងប្រព័ន្ធ ACTS
3. (មិនមានបរិយាយ)
4. ដំណើរការចុះបញ្ជិកាប្រើប្រាស់និមុត្តិធានា ធ្វើការត្រួតពិនិត្យនិមុត្តិធានា (ង) ដើម្បីបញ្ជាក់លើព័ត៌មានលម្អិតរបស់និមុត្តិធានាដែលម្ចាស់ទំនិញបានផ្តល់ឱ្យ និងបញ្ជាក់ថាតើនិមុត្តិធានាមានចំនួនគ្រប់គ្រាន់ដែរឬទេ
5. ប្រសិនបើការត្រួតពិនិត្យជោគជ័យ លទ្ធផលត្រួតពិនិត្យបញ្ជាក់ថា ការប្រើប្រាស់និមុត្តិធានាត្រូវបានចុះបញ្ជីដោយស្វ័យប្រវត្តិ (ច)
6. ប្រសិនបើការត្រួតពិនិត្យការចុះបញ្ជិកាប្រើប្រាស់និមុត្តិធានាបរាជ័យ ម្ចាស់ទំនិញនឹងទទួលបានដំណឹងថា និមុត្តិធានាដែលបានប្រកាសមិនមានសុពលភាព
7. ម្ចាស់ទំនិញមានរយៈពេលកំណត់ក្នុងការកែតម្រូវនិមុត្តិធានាដែលមិនមានសុពលភាព (បើមិនដូចនេះទេ ទំនិញនឹងមិនអាចបញ្ចេញបានឡើយ)
8. ដំណើរការឆ្លងកាត់ត្រៀមរួចដើម្បីបញ្ចេញ។ កាលបរិច្ឆេទត្រូវបានកំណត់សម្រាប់កាលបរិច្ឆេទដែលនឹងមកដល់នៅការិយាល័យគម្យដ្ឋាន និងនៅពេលណាដែលលទ្ធផលត្រួតពិនិត្យនឹងបញ្ជូនពីការិយាល័យគម្យដ្ឋានមកវិញជាមួយនឹងពេលវេលាឆ្លងកាត់ដោយផ្អែកលើតម្រាយផ្លូវឆ្លងកាត់

9. ប្រតិវេទន៍អមដំណើរឆ្លងកាត់ (TAD) បានបោះពុម្ពជាទម្រង់ក្រដាស និងប្រគល់ឱ្យម្ចាស់ទំនិញ
10. ធុរជននឹងទទួលបានព័ត៌មានអំពីការបញ្ចេញសម្រាប់ឆ្លងកាត់ និងព័ត៌មានលម្អិតនៃបច្ចុប្បន្នភាពដំណើរការដើម្បីគ្របដណ្តប់រាល់ការកែតម្រូវនានា និងលទ្ធផលត្រួតពិនិត្យ
11. TAD អាចបោះពុម្ពដោយអ្នកផ្ញើទំនិញ នៅទីតាំងរបស់ខ្លួន
12. សារបញ្ជាក់ថា នឹងមានប្រតិបត្តិការឆ្លងកាត់ (ATR) បានផ្ញើទៅឱ្យការិយាល័យឆ្លងកាត់ដែលបានប្រកាស ( ជ)។ បន្ទាប់មក ការិយាល័យឆ្លងកាត់បានទទួលសារបញ្ជាក់ថាប្រតិបត្តិការបានឆ្លងកាត់ព្រំដែន (NCF) ( ឈ)
13. ការិយាល័យគម្យដ្ឋានដែលបានប្រកាសទទួលបានសារបញ្ជាក់ថានឹងមានប្រតិបត្តិការឆ្លងកាត់មកដល់ (AAR) ( ញ)
14. ការិយាល័យគម្យដ្ឋានផ្ញើសារបញ្ជាក់ថាបានមកដល់ (Arrival Advice) និងលទ្ធផលត្រួតពិនិត្យបន្ទាប់ពីការផ្ទៀងផ្ទាត់ទំនិញមកដល់។ លទ្ធផលនេះត្រូវបានកត់ត្រាទុកក្នុងប្រព័ន្ធ ACTS។

## ១.៩. ការចុះបញ្ជិកានិមុត្តិធានាតាមប្រព័ន្ធ ACTS

| ម្ចាស់ទំនិញ/ ធុរជន | ប្រព័ន្ធ ACTS | គយ | កំណត់សម្គាល់ |
|---|---|---|---|




រូបភាពទី៧: ការត្រួតពិនិត្យមុនការចុះបញ្ជិកា និងការចុះបញ្ជិកានិមុត្តិធានាតាមប្រព័ន្ធ ACTS

1. ការរៀបចំ និងការចុះបញ្ជិកានិមុត្តិធានា

*ចំណាំ៖ ម្ចាស់ទំនិញត្រូវតម្កល់និមុត្តិធានាក្នុងបរិមាណសមស្របជាមុនសិន រួចប្រគល់ជូនការិយាល័យគ្រប់គ្រងនិមុត្តិធានា។*

*ចំណាំ៖ ប្រសិនបើ និមុត្តិធានាមានសុពលភាព និងរៀបចំបានត្រឹមត្រូវ មន្ត្រីនឹងបញ្ចូលព័ត៌មានលម្អិតទៅក្នុងប្រព័ន្ធគ្រប់គ្រងនិមុត្តិធានា (GMS) ដែលនឹងបង្កើតបានជាលេខយោងនិមុត្តិធានា (GRN)។ ម្ចាស់ទំនិញត្រូវបញ្ចូលលេខ GRN នេះនៅពេលប្រកាសប្រតិវេទន៍។ ម្ចាស់ទំនិញនឹងទទួលបានការជូនដំណឹងប្រសិនបើ និមុត្តិធានាដែលបានប្រើប្រាស់មិនមានសុពលភាព ឬមិនអាចទទួលយកបាន។*

2. ការផ្ទៀងផ្ទាត់និមុត្តិធានា

*ចំណាំ៖ បន្ទាប់ពីម្ចាស់ទំនិញដាក់ប្រតិវេទន៍ឆ្លងកាត់តាមទម្រង់អេឡិចត្រូនិក ប្រព័ន្ធនឹងផ្ទៀងផ្ទាត់ព័ត៌មានលម្អិត នៃនិមុត្តិធានាដែលគ្របដណ្តប់ការទាមទារសំណង។*

3. ការប្រើប្រាស់និមុត្តិធានា៖
   a. ការិយាល័យចេញដំណើរ ធ្វើការត្រួតពិនិត្យនិមុត្តិធានា (ង)
   b. ប្រព័ន្ធ ACTS បញ្ជូនព័ត៌មានលម្អិតនៃនិមុត្តិធានាទៅកាន់ប្រព័ន្ធគ្រប់គ្រងនិមុត្តិធានាដើម្បីត្រួតពិនិត្យនិងចុះបញ្ជិកា
   c. ប្រព័ន្ធគ្រប់គ្រងនិមុត្តិធានានឹងត្រួតពិនិត្យនិមុត្តិធានាដែលបានចុះបញ្ជិកា។ ប្រសិនបើ ការត្រួតពិនិត្យនៃនិមុត្តិធានាទទួលបានជោគជ័យ

ការប្រើប្រាស់និមុត្តិធានានឹងត្រូវបានកត់ត្រាទុកក្នុងប្រព័ន្ធ

d. ប្រសិនបើ ការត្រួតពិនិត្យនិមុត្តិធានាបរាជ័យ ប្រព័ន្ធនឹងមិនកត់ត្រាការប្រើប្រាស់និមុត្តិធានាឡើយ

e. ការិយាល័យចេញដំណើរទទួលលទ្ធផលនៃការត្រួតពិនិត្យនិមុត្តិធានាពីប្រព័ន្ធគ្រប់គ្រងនិមុត្តិធានា (ច)។ ប្រសិនបើ ការត្រួតពិនិត្យនិមុត្តិធានាមិនជោគជ័យ ការប្រើប្រាស់នៃនិមុត្តិធានាដែលបានចុះបញ្ជិការួចហើយនឹងត្រូវលុបចោល។ ម្ចាស់ទំនិញត្រូវកែសម្រួល ឬប្តូរនិមុត្តិធានា។

## ១.១០. ដំណើរការតាមប្រព័ន្ធ ACTS នៅការិយាល័យឆ្លងកាត់

| ម្ចាស់ទំនិញ/ ធុរជន | ប្រព័ន្ធ ACTS | គយ | កំណត់សម្គាល់ |
|---|---|---|---|




រូបភាពទី៨: ការិយាល័យឆ្លងកាត់ តាមប្រព័ន្ធ ACTS

1. ការិយាល័យឆ្លងកាត់ទទួលបាន សារបញ្ជាក់ថានឹងមានប្រតិបត្តិការឆ្លងកាត់ (ATR) ជាមុន។ មន្ត្រីគយធ្វើការត្រួតពិនិត្យមុនការមកដល់ ផ្អែកលើការវិភាគហានិភ័យ និងព័ត៌មានពាក់ព័ន្ធដទៃទៀត។ ការសម្រេចចិត្តត្រូវបានចុះបញ្ជីថាតើអនុញ្ញាតឱ្យឆ្លងកាត់ដែរឬទេ
2. ក្រុមហ៊ុនដឹកទំនិញជូនដំណឹងមន្ត្រីគយអំពីទំនិញមកដល់ ហើយមន្ត្រីស្កេនលេខ ARN ឬស្វែងរកប្រតិវេទន៍ក្នុងប្រព័ន្ធ
3. ប្រព័ន្ធ ACTS ស្វែងរកព័ត៌មានពាក់ព័ន្ធនឹងការឆ្លងកាត់ (ATR) និង
5. នៅពេលព័ត៌មាននៃដំណើរការឆ្លងកាត់មិនអាចរកឃើញ អាចជាករណីបង្វែទំនិញ ឬករណីផ្សេងទៀត ប្រព័ន្ធ ACTS ទំនាក់ទំនងទៅកាន់ការិយាល័យចេញដំណើរសម្រាប់ ATR និងក្រើនរំលឹកដល់ការិយាល័យឆ្លងកាត់ ឬ
7. នៅពេលមានព័ត៌មាន ATR ការឆ្លងកាត់អាចត្រូវបានផ្ទៀងផ្ទាត់។ ប្រព័ន្ធ ACTS ទាញយកព័ត៌មានដំណើរការឆ្លងកាត់ និងឆ្លើយតបជាមួយនឹងស្ថានភាពរបស់ដំណើរការឆ្លងកាត់ នឹងបានអនុវត្តការត្រួតពិនិត្យ ដូចជា÷
   - ប្រព័ន្ធកត់ត្រាទីតាំងនៃដំណើរការឆ្លងកាត់នៅការិយាល័យចេញដំណើរ ឬ

- ប្រព័ន្ធកត់ត្រាទីតាំងនៃដំណើរការឆ្លងកាត់ នៅការិយាល័យចេញដំណើរ ប៉ុន្តែមិនមានភាពស្របគ្នាជាមួយការិយាល័យឆ្លងកាត់ (ឧ. ដំណើរការឆ្លងកាត់បានមកដល់ការិយាល័យគម្យដ្ឋានរួចហើយ)

- ប្រសិនបើ ដំណើរការឆ្លងកាត់ត្រូវបញ្ឈប់នៅការិយាល័យឆ្លងកាត់។ ក្នុងករណីនេះ ការិយាល័យឆ្លងកាត់នឹងក្លាយជាការិយាល័យគម្យដ្ឋាន (ការបង្វែរ)
- ការបង្វែរក្នុងស្រុក ឬអន្តរជាតិ (ដំណើរការឆ្លងកាត់មិនបានប្រកាសពីដំបូងថាមកការិយាល័យឆ្លងកាត់នេះ ឬប្រទេសឆ្លងកាត់នេះ ហើយនិមុត្តិធានាមិនមានសុពលភាពនៅប្រទេសនេះ) ឬ
- ប្រព័ន្ធនឹងព្រមានថា ដំណើរការឆ្លងកាត់នេះត្រូវបានកំណត់ថា "តម្រាយផ្លូវជាប់កាតព្វកិច្ច" ឬមានផ្ទុក "ទំនិញជាប់កម្រិតកំណត់" ឬដំណើរការឆ្លងកាត់នេះត្រូវបានកត់ត្រាទុកថាបានចូលក្នុងប្រទេសនេះរួចហើយ (នៅការិយាល័យឆ្លងកាត់)

8. ប្រព័ន្ធ ឬមន្ត្រីគយចាត់វិធានការសមស្របដើម្បីត្រួតពិនិត្យ ឬមិនត្រួតពិនិត្យ
9. រាល់ការសម្រេចចិត្តលើការត្រួតពិនិត្យណាមួយត្រូវបានកត់ត្រាទុកក្នុងប្រព័ន្ធ ACTS។ ឧទាហរណ៍ ការជូនដំណឹងក្រុមហ៊ុនដឹកជញ្ជូនជាមុន ប្រសិនបើសម្រេចថាត្រួតពិនិត្យទំនិញពេលមកដល់ព្រំដែន ឬប្រសិនបើដំណើរការឆ្លងកាត់មិនមានសុពលភាព និងត្រូវតែបញ្ឈប់ ឬបញ្ជូនត្រលប់ទៅវិញ
10. ប្រសិនបើ មិនមានការសង្ស័យ ឬការសម្រេចជាមុនថាអនុញ្ញាតឱ្យឆ្លងកាត់ ដំណើរការឆ្លងកាត់ត្រូវបានអនុញ្ញាត។ មន្ត្រីគយកត់ត្រាព័ត៌មានបញ្ជាក់ថាប្រតិបត្តិការបានឆ្លងកាត់ព្រំដែន (NCF) ក្នុងប្រព័ន្ធ ACTS ហើយប្រព័ន្ធនឹងជូនដំណឹងដល់ការិយាល័យគយចេញដំណើរ ការិយាល័យគយគម្យដ្ឋាន និងការិយាល័យគយឆ្លងកាត់ដោយស្វ័យប្រវត្តិ។

## ១.១១. ដំណើរការមកដល់តាមប្រព័ន្ធ ACTS - នីតិវិធីធម្មតា

| ម្ចាស់ទំនិញ/ ធុរជន | ប្រព័ន្ធ ACTS | គយ | កំណត់សម្គាល់ |
|---|---|---|---|




រូបភាពទី៩: ការត្រួតពិនិត្យការមកដល់ ក្រោមនីតិវិធីធម្មតាតាមប្រព័ន្ធ ACTS

1. ការិយាល័យគម្យដ្ឋានទទួលសារបញ្ជាក់ថានឹងមានប្រតិបត្តិការឆ្លងកាត់មកដល់ (AAR), ប្រព័ន្ធ ACTS ធ្វើការវិភាគហានិភ័យដោយស្វ័យប្រវត្តិ, រក្សាទុកជាមុននូវព័ត៌មានបរិយាយដំណើរការឆ្លងកាត់ដែលនឹងត្រូវមកដល់ការិយាល័យគម្យដ្ឋាន។ បន្ទាប់ពីការមកដល់ នៅលើប្រតិវេទន៍នឹងមានបញ្ជាក់ថា ធុរជនជាប្រតិបត្តិករដែលទទួលបានការអនុញ្ញាត ឬទេ ហើយពេលនោះ ការិយាល័យគម្យដ្ឋាននឹងដឹងថាតើ ទំនិញនឹងត្រូវបង្ហាញនៅការិយាល័យគយ ឬទីតាំងរបស់អ្នកទទួលទំនិញដែលបានអនុញ្ញាត
2. អ្នកទទួលទំនិញដែលទទួលបានការអនុញ្ញាត ឬអ្នកតំណាងម្ចាស់ទំនិញជូនដំណឹងការិយាល័យគម្យដ្ឋានអំពីការមកដល់នៃទំនិញ
3. ប្រតិវេទន៍អមដំណើរឆ្លងកាត់មកដល់ជាមួយអ្នកបើកបររថយន្តដឹកទំនិញ។ ក្រោមនីតិវិធីធម្មតា ទីតាំងដែលទំនិញត្រូវត្រួតពិនិត្យគឺនៅការិយាល័យគម្យដ្ឋាន
4. នៅពេលការមកដល់មានសុពលភាព
5. ប្រព័ន្ធ ACTS ស្វែងរកព័ត៌មានដំណើរការឆ្លងកាត់ ដោយយោងតាម ARN
6. ប្រសិនបើមិនមានការបង្វែរ ប្រព័ន្ធមន្ត្រីគយនៅគម្យដ្ឋានប្រើប្រាស់ប្រព័ន្ធ ACTS ដើម្បីជូនដំណឹងការិយាល័យចេញដំណើរថា ការមកដល់ត្រូវបានទទួលយក
7. ការវិភាគហានិភ័យត្រូវបានបញ្ចប់ក្នុងដំណាក់កាលនេះដើម្បីជួយមន្ត្រីគយក្នុងការសម្រេចចិត្តត្រួតពិនិត្យទំនិញ។ ការវិភាគហានិភ័យនៅ

ការិយាល័យគម្រូដ្ឋានត្រូវបានពិចារណាលើកត្តាហានិភ័យថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ។ ប្រព័ន្ធ ACTS កត់ត្រាលទ្ធផលនៃការវិភាគហានិភ័យនេះ

8. ទោះបីជា ដំណើរការវិភាគហានិភ័យធ្វើឡើងដោយដោយស្វ័យប្រវត្តិក៏ដោយ ក៏ប៉ុន្តែការសម្រេចចិត្តចុងក្រោយស្ថិតនៅលើមន្ត្រីគយ
9. ប្រសិនបើ ការវិភាគហានិភ័យបានស្នើឱ្យចាត់វិធានការសមស្របនៅការិយាល័យគម្រូដ្ឋាន ប៉ុន្តែមន្ត្រីសម្រេចចិត្តមិនត្រួតពិនិត្យ ដូចនេះប្រព័ន្ធ ACTS តម្រូវឱ្យមន្ត្រីគយនោះបញ្ជាក់អំពីការសម្រេចចិត្តមិនត្រួតពិនិត្យ។ ទំនិញត្រៀមរួចរាល់សម្រាប់សកម្មភាពឬនីតិវិធីបន្ទាប់។ (ឧ. ការរក្សាទុកបណ្តោះអាសន្ន ឬនីតិវិធីនាំចូលជាដើម)
10. ទំនិញត្រូវបានបញ្ចេញពីការឆ្លងកាត់ ហើយប្រព័ន្ធ ACTS ជូនដំណឹងធុរជន។ លទ្ធផលត្រួតពិនិត្យដែលបញ្ជាក់ថា “គ្មានកំហុសឆ្គង (Considered satisfactory)” ត្រូវជូនដំណឹងការិយាល័យចេញដំណើរ តាមរយៈប្រព័ន្ធ ACTS ជាមួយនឹងព័ត៌មានលម្អិតនៃការផ្ទេរទំនិញណាមួយ និង/ឬឧប្បត្តិហេតុប្រសិនបើ បានកើតឡើងក្នុងអំឡុងពេលតម្រាយផ្លូវ
11. ប្រសិនបើ មន្ត្រីគយសម្រេចចិត្តត្រួតពិនិត្យ ការត្រួតពិនិត្យត្រូវធ្វើឡើងនៅការិយាល័យគម្រូដ្ឋាន (១២) ដើម្បីផ្ទៀងផ្ទាត់សៀល ប្រតិវេទន៍ ឬទំនិញ (ឬទាំងអស់) ដោយប្រើប្រាស់ព័ត៌មានបរិយាយដំណើរការឆ្លងកាត់ដែលបោះពុម្ពជាក្រដាសផ្អែកលើ លេខយោងប្រតិវេទន៍ឆ្លងកាត់គយអាស៊ាន (ARN)។

មន្ត្រីគយការិយាល័យគម្រូដ្ឋានកត់ត្រាលទ្ធផលនៃការត្រួតពិនិត្យទំនិញ។ នៅពេលមានភាពប្រក្រតី ឬមន្ត្រីគយសម្រេចចិត្តមិនរង់ចាំការកែតម្រូវកំហុសឆ្គងពីការិយាល័យចេញដំណើរ មន្ត្រីគយត្រូវកត់ត្រាក្នុងប្រព័ន្ធ ACTS ថា ទំនិញរួចរាល់សម្រាប់នីតិវិធី/សកម្មភាពបន្ទាប់ (ឧ.ការរក្សាទុកបណ្តោះអាសន្ន ឬនីតិវិធីនាំចូល ជាដើម)។ បន្ទាប់មក ទំនិញត្រូវបានបញ្ចេញពីការឆ្លងកាត់ (១០)។

ក្នុងករណីរកឃើញភាពមិនប្រក្រតី មន្ត្រីគយការិយាល័យគម្រូដ្ឋានអាចសម្រេចចិត្តរង់ចាំការដោះស្រាយភាពមិនប្រក្រតីពីការិយាល័យចេញដំណើរ មុនពេលបញ្ចេញទំនិញ។ ការិយាល័យចេញដំណើរនឹងត្រូវបានជូនដំណឹង ប្រសិនបើការិយាល័យគម្រូដ្ឋានបានសម្រេចចិត្តរង់ចាំ។ នៅពេលមន្ត្រីគយសម្រេចចិត្តរង់ចាំការដោះស្រាយភាពមិនប្រក្រតីពីការិយាល័យចេញដំណើរ ការសម្រេចចិត្តនេះនឹងត្រូវកត់ត្រាក្នុងប្រព័ន្ធ ACTS ដោយបញ្ជាក់ថា “កំពុងរង់ចាំ”។

## ១.១២. ដំណើរការមកដល់តាមប្រព័ន្ធ ACTS - នីតិវិធីសាមញ្ញ

| ម្ចាស់ទំនិញ/ ធុរជន | ប្រព័ន្ធ ACTS | គយ | កំណត់សម្គាល់ |
|---|---|---|---|




រូបភាពទី១០: ការត្រួតពិនិត្យការមកដល់ក្រោមនីតិវិធីសាមញ្ញតាមប្រព័ន្ធ ACTS

1. ការិយាល័យគម្យដ្ឋានទទួលបានសារបញ្ជាក់ថា នឹងមានប្រតិបត្តិការឆ្លងកាត់មកដល់ (AAR) ប្រព័ន្ធ ACTS ធ្វើការវិភាគហានិភ័យ និងរក្សាទុកព័ត៌មានបរិយាយដំណើរការឆ្លងកាត់
2. អ្នកទទួលទំនិញ ឬអ្នកតំណាងម្ចាស់ទំនិញជូនដំណឹងការិយាល័យគម្យដ្ឋានអំពីការមកដល់នៃទំនិញ។ ប្រតិវេទន៍អមដំណើរឆ្លងកាត់ (TAD) ត្រូវមកដល់ជាមួយនឹងរថយន្តដឹកទំនិញ
3. នៅពេលការជូនដំណឹងមកដល់បង្ហាញថាស្ថិតក្រោមនីតិវិធីសាមញ្ញ ប្រព័ន្ធ ACTS ត្រួតពិនិត្យធុរជនដែលជាអ្នកទទួលទំនិញពិតជាបានអនុញ្ញាតឱ្យប្រើប្រាស់នីតិវិធីសាមញ្ញនៅការិយាល័យគម្យដ្ឋាននោះ និងត្រួតពិនិត្យទីតាំងទំនិញដែលត្រូវត្រួតពិនិត្យស្ថិតក្នុងចំណោមទីតាំងដែលបានអនុញ្ញាតដែរឬទេ

*ចំណាំ៖ ប្រសិនបើ គ្មានការបង្វែរ ប្រព័ន្ធ ACTS ជូនដំណឹងការិយាល័យចេញដំណើរថា ការមកដល់ត្រូវបានទទួលយក និងបានកត់ត្រាចូលក្នុងប្រព័ន្ធ ACTS*

4. ប្រសិនបើ ទំនិញត្រូវបានចាត់ទុកថា មានហានិភ័យទាប និងមិនមែនជាទំនិញជាប់កម្រិតកំណត់នោះទេ ការកំណត់ពេលវេលា "រង់ចាំការអនុញ្ញាតការបញ្ចេញស្វ័យប្រវត្តិ" ត្រូវបានចាប់ផ្ដើម
5. ក្រោយពីបញ្ចប់ ពេលវេលាកំណត់រង់ចាំ ទំនិញត្រូវបានផ្ដល់ការអនុញ្ញាតឱ្យបញ្ចេញ។ ការិយាល័យគម្យដ្ឋានទទួលបានព័ត៌មានអំពីដំណើរការឆ្លងកាត់ និងមានឱកាសធ្វើអន្តរាគមន៍

ក្នុងចន្លោះពេលនេះជាមួយនឹងការសម្រេចចិត្ត
ត្រួតពិនិត្យ

6. ប្រសិនបើ មន្ត្រីគយការិយាល័យគម្បដ្ឋានមិនសម្រេចចិត្តត្រួតពិនិត្យទំនិញក្នុងរយៈពេលដែលបានកំណត់ ប្រព័ន្ធ ACTS នឹងជូនដំណឹងធុរជន (៧) ថាធុរជនអាចចាប់ផ្តើមបញ្ចេញទំនិញ និងកត់ត្រាការអនុញ្ញាតការបញ្ចេញទំនិញនេះ។ ប្រសិនបើ មន្ត្រីគយសម្រេចចិត្តត្រួតពិនិត្យទំនិញអំឡុងពេលនេះ ការអនុញ្ញាតបញ្ចេញទំនិញត្រូវបានបញ្ឈប់
8. ការវិភាគហានិភ័យត្រូវបានបញ្ចប់ដើម្បីជួយដល់មន្ត្រីគយសម្រេចចិត្តលើការត្រួតពិនិត្យទំនិញ។ លទ្ធផលវិភាគហានិភ័យដែលបានផ្ញើពីការិយាល័យចេញដំណើរអាចទទួលយក ឬការិយាល័យគម្បដ្ឋានអាចពិចារណាម្តងទៀតនៅពេលវិភាគហានិភ័យ។ ប្រព័ន្ធ ACTS កត់ត្រាលទ្ធផលវិភាគហានិភ័យ
9. ការិយាល័យគម្បដ្ឋានទទួលបានព័ត៌មានការបញ្ចេញទំនិញពីអ្នកទទួលទំនិញ។ ប្រព័ន្ធ ACTS ត្រួតពិនិត្យសុពលភាពនៃព័ត៌មានដែលទទួលបាន និងរក្សាទុកព័ត៌មាននៃការបញ្ចេញទំនិញនោះ។ នៅពេលការបញ្ចេញទំនិញបានបញ្ចប់ដោយមិនមានការកត់សម្គាល់ ដូចនេះប្រព័ន្ធ ACTS កត់ត្រាទុកថា ទំនិញរួចរាល់សម្រាប់នីតិវិធី ឬសកម្មភាពបន្ទាប់ (ឧ.ការរក្សាទុកបណ្តោះអាសន្ន ឬនីតិវិធីនាំចូលជាដើម) ហើយទំនិញបានបញ្ចេញពីការឆ្លងកាត់

*ចំណាំ÷ ប្រព័ន្ធ ACTS ជូនដំណឹងការិយាល័យចេញដំណើរ (ឈ) អំពីលទ្ធផលត្រួតពិនិត្យដោយកំណត់ថា “ពុំមានកំហុសឆ្គង (Considered satisfactory)”។ នៅពេលការបញ្ចេញទំនិញមិនបានបញ្ចប់ ដូចនេះមានការកត់សម្គាល់លើការបញ្ចេញទំនិញ បន្ទាប់មកប្រព័ន្ធ ACTS ជូនដំណឹងមន្ត្រីគយថា មន្ត្រីគយត្រូវសម្រេចចិត្តត្រួតពិនិត្យ ឬមិនត្រួតពិនិត្យទំនិញនោះ។*

10. ការសម្រេចចិត្តមិនត្រួតពិនិត្យត្រូវបានកត់ត្រាទុកក្នុងប្រព័ន្ធ ACTS
11. មន្ត្រីគយទៅពិនិត្យទីតាំងដាក់ទំនិញដែលបានបញ្ជាក់ក្នុងការជូនដំណឹងការមកដល់ ដើម្បីផ្ទៀងផ្ទាត់សៀល ប្រតិវេទន៍ ឬទំនិញ (ឬទាំងអស់) ដោយប្រើប្រាស់ព័ត៌មានបរិយាយដំណើរការឆ្លងកាត់ដែលបោះពុម្ពជាក្រដាសផ្អែកលើ លេខយោងប្រតិវេទន៍ឆ្លងកាត់គយអាស៊ាន (ARN)។

មន្ត្រីគយការិយាល័យគម្បដ្ឋានត្រួតពិនិត្យទំនិញ និងឯកសារអមផ្ទៀបនឹងព័ត៌មានបរិយាយដំណើរការឆ្លងកាត់ដែលបានបោះពុម្ពជាក្រដាស។

មន្ត្រីគយការិយាល័យគម្បដ្ឋានកត់ត្រាទុកលទ្ធផលត្រួតពិនិត្យ ក្នុងករណី “មិនមានកំហុសឆ្គង” ឬ “មានកំហុសឆ្គង” ចូលក្នុងប្រព័ន្ធ។ រាល់ភាពមិនប្រក្រតីត្រូវដោះស្រាយជាមួយការិយាល័យចេញដំណើរ។

## ១.១៣. ការគ្រប់គ្រងនិមុត្តិធានាតាមប្រព័ន្ធ ACTS - ការបញ្ចេញការប្រើប្រាស់និមុត្តិធានា

| ម្ចាស់ទំនិញ/ ធុរជន | ប្រព័ន្ធ ACTS | គយ | កំណត់សម្គាល់ |
|---|---|---|---|




រូបភាពទី១១: ការបញ្ចេញការប្រើប្រាស់និមុត្តិធានា ACTS

បន្ទាប់ពីបញ្ចប់ដំណើរការឆ្លងកាត់ ការិយាល័យគម្យដ្ឋានជូនដំណឹងការិយាល័យចេញដំណើរដោយប្រើសារបញ្ជាក់ថាបានមកដល់ (Arrival Advice) តាមរយៈប្រព័ន្ធ ACTS បន្ទាប់មកនឹងមានសារមួយផ្សេងទៀត អាស្រ័យថាតើ លទ្ធផលនៃដំណើរការឆ្លងកាត់ត្រូវត្រួតពិនិត្យឬអត់ គ្មានកំហុសឬមានកំហុស និងកំណត់សកម្មភាពលើការបញ្ឈប់ ឬបញ្ចប់ប្រតិបត្តិការ និងបញ្ចេញនិមុត្តិធានាណាមួយ។

1. ក្នុងករណី និមុត្តិធានាសម្រាប់ប្រតិបត្តិការច្រើនលើក បរិមាណយោងដែលបានរក្សាទុកសម្រាប់ដំណើរការឆ្លងកាត់ជាក់លាក់មួយត្រូវបានបង្វិល ប៉ុន្តែមិនទាន់បានបញ្ចេញ ហើយត្រូវបានកត់ត្រាទុកក្នុងប្រព័ន្ធគ្រប់គ្រងនិមុត្តិធានា
2. បន្ទាប់ពីទទួលបានសារបញ្ជាក់ថា បានមកដល់សម្រាប់ដំណើរឆ្លងកាត់ដែលគ្របដណ្តប់ដោយនិមុត្តិធានាសម្រាប់ប្រតិបត្តិការច្រើនលើក ប្រព័ន្ធនឹងជ្រើសរើសការិយាល័យគ្រប់គ្រងនិមុត្តិធានាពាក់ព័ន្ធ និងស្នើសុំឱ្យបង្វិលបរិមាណយោង
3. នៅពេលត្រូវបញ្ចេញនិមុត្តិធានា ដូចជានៅពេលដំណើរការឆ្លងកាត់បានបញ្ចប់ប្រតិបត្តិការ ហើយការបញ្ចប់ប្រតិបត្តិការនេះត្រូវបានកត់ត្រាទុកក្នុងប្រព័ន្ធ ACTS និងបានជូនដំណឹងដល់ម្ចាស់ទំនិញ

4. ព័ត៌មានស្ដីពីការបញ្ចប់ប្រតិបត្តិការបានផ្ញើទៅការិយាល័យគ្រប់គ្រងនិមុត្តិធានាពាក់ព័ន្ធ សម្រាប់បញ្ចេញការប្រើប្រាស់និមុត្តិធានា ទាំងសម្រាប់ប្រតិបត្តិតែមួយលើក ឬប្រតិបត្តិការច្រើនលើក និងការបញ្ចេញការប្រើប្រាស់និមុត្តិធានាត្រូវបានកត់ត្រាទុកក្នុងប្រព័ន្ធគ្រប់គ្រងនិមុត្តិធានា (៦)។

*ចំណាំ÷ ការលុបចោលការប្រើប្រាស់និមុត្តិធានា សម្រាប់មូលហេតុផ្សេងៗ ក្រៅពីការបញ្ចប់នៃដំណើរការឆ្លងកាត់ និងការបញ្ចប់ប្រតិបត្តិការ អនុវត្តតាមវិធានទីតិវិធីស្រដៀងគ្នា។ ឧទាហរណ៍ ក្នុងករណីដែលដំណើរការឆ្លងកាត់មិនអាចបន្ត ហើយការិយាល័យចេញដំណើរលុបចោលប្រតិវេទន៍។*

## ១.១៤. នីតិវិធីសាកសួរតាមប្រព័ន្ធ ACTS

| ម្ចាស់ទំនិញ/ ធុរជន | ប្រព័ន្ធ ACTS | គយ | កំណត់សម្គាល់ |
|---|---|---|---|




រូបភាពទី១២: នីតិវិធីសាកសួរការឆ្លងកាត់ ACTS

1. ពេលវេលាដែលបានបែងចែកសម្រាប់ការទទួលយកសារបញ្ជាក់ថាបានមកដល់ ឬការត្រួតពិនិត្យបានផុតពេលកំណត់។ មុនពេលចាប់ផ្តើមការស្នើសុំ រយៈពេលផុតកំណត់នេះកំណត់ដោយប្រទេសចេញដំណើរ ដោយប្រើប្រាស់ប៉ារ៉ាម៉ែត្រដែលបានអនុញ្ញាតពាក់ព័ន្ធនឹងបទប្បញ្ញត្តិច្បាប់។ ក្រោយពីទទួលបានសារបញ្ជាក់ថា បានមកដល់ ប៉ារ៉ាម៉ែត្រនេះនឹងផ្លាស់ប្តូរ។ ក្រៅពីនេះ មន្ត្រីគយអាចបង្រួមប៉ារ៉ាម៉ែត្រនេះដោយខ្លួនឯង
2. ពេលបានទទួលលទ្ធផលត្រួតពិនិត្យពីការិយាល័យគម្យដ្ឋាន ឬពេលបញ្ចប់ដំណើរឆ្លងកាត់ដោយសារហេតុផលផ្សេងទៀត ការកំណត់ពេលវេលាក៏បញ្ឈប់ផងដែរ (៣)
4. ប្រសិនបើ ប្រទេសចេញដំណើរមិនបានទទួលសារបញ្ជាក់ថាបានមកដល់ ប្រទេសចេញដំណើរផ្ញើសំណើទៅការិយាល័យប្រទេសគម្យដ្ឋាន (ដែលបានប្រកាស) ឬ ប្រសិនបើ បានដឹងអំពីការបង្វែរ ការស្នើសុំនេះនឹងផ្ញើទៅប្រទេសគម្យដ្ឋានមួយផ្សេងទៀត។ បន្ទាប់ពីផ្ញើការផ្ញើសំណើនេះ ការកំណត់ពេលវេលា “គួរចាប់ផ្តើមការប្រមូលបំណុលមកវិញ” (Recovery recommended) ត្រូវបានចាប់ផ្តើម
5. ប្រព័ន្ធ ACTS នៅការិយាល័យគម្យដ្ឋាន ត្រួតពិនិត្យស្ថានភាព និងឆ្លើយតបដោយស្វ័យប្រវត្តិទៅប្រទេសចេញដំណើរនូវស្ថានភាពជាក់ស្តែងរបស់ខ្លួន (៦)។ ប្រសិនបើ ស្ថានភាពនៅការិយាល័យគម្យដ្ឋាន មិនស្របជាមួយនឹងការិយាល័យចេញដំណើរដោយមិនមានសារ

Error នានា សារដែលមិនបានទទួលនឹងត្រូវផ្ញើឡើងវិញ

*ចំណាំ៖ ប្រសិនបើមិនអាចធ្វើទៅបានក្នុងរយៈពេលកំណត់ ការិយាល័យប្រទេសគម្យដ្ឋានបញ្ជូនព័ត៌មានដែលមិនបានទទួលដើម្បីអនុញ្ញាតឱ្យប្រទេសចេញដំណើរអាចតាមដានបានដោយសមស្រប។*

7. ប្រព័ន្ធ ACTS នៅប្រទេសចេញដំណើរត្រួតពិនិត្យថាតើ ស្ថានភាពនៅប្រទេសគម្យដ្ឋានស្របគ្នាទៅនឹងស្ថានភាពនៅប្រទេសចេញដំណើរ និងបានទទួលសារបញ្ជាក់ថាបានមកដល់ហើយឬនៅ។ ប្រសិនបើមិនទទួលបានសារបញ្ជាក់ថាបានមកដល់ ឬលទ្ធផលត្រួតពិនិត្យ មន្ត្រីគយនៃប្រទេសចេញដំណើរអាចចាប់ផ្តើមនីតិវិធីសាកសួរ ឬពន្យាទុកនៅពេលក្រោយ។ ក្នុងករណីពន្យាទុក មន្ត្រីគយត្រូវកំណត់ពេលវេលាឡើងវិញ
8. ប្រទេសចេញដំណើរត្រួតពិនិត្យព័ត៌មានដែលមានក្នុងដៃ អំពីអ្នកទទួលទំនិញ និងសម្រេចចិត្តថាតើព័ត៌មាននេះគ្រប់គ្រាន់ដែរឬទេ។ ប្រសិនបើចាត់ទុកថា ព័ត៌មាននេះមិនគ្រប់គ្រាន់ មន្ត្រីគយស្នើម្ចាស់ទំនិញផ្តល់ព័ត៌មានបន្ថែម (១០) និងផ្តល់ក្នុងរយៈពេលកំណត់មួយ។ ប្រសិនបើ មិនមានការផ្តល់ព័ត៌មានក្នុងរយៈពេលកំណត់នេះ ត្រូវចាត់ទុកថាចម្លើយអវិជ្ជមាន។ សំណើចាប់ផ្តើមការសាកសួរដំណឹងអាចធ្វើឡើងនៅការិយាល័យផ្សេងមួយទៀតក៏បាន បើពាក់ព័ន្ធ។ ប្រសិនបើព័ត៌មានអំពីអ្នកទទួលទំនិញចាត់ទុកថា គ្រប់គ្រាន់ អាចចាប់ផ្តើមនីតិវិធីសាកសួរបានជាមួយនឹងការិយាល័យគម្យដ្ឋានដែលបានប្រកាស (៩)។ ប្រព័ន្ធ ACTS កត់ត្រាព័ត៌មានសំណើសម្រាប់ធុរជនទទួលសំណើ ឬផ្ញើសំណើសាកសួរទៅកាន់ការិយាល័យទទួលសំណើ និងកំណត់ពេលវេលាម្រាប់ការឆ្លើយតប
11. ប្រសិនបើម្ចាស់ទំនិញផ្តល់ភស្តុតាងផ្សេងទៀត ដំណើរការឆ្លងកាត់អាចបញ្ចប់ប្រតិបត្តិការ (១២) និងយោបល់នេះត្រូវផ្ញើទៅការិយាល័យពាក់ព័ន្ធដើម្បីបញ្ចប់ដំណើរការឆ្លងកាត់។

ប្រសិនបើ ម្ចាស់ទំនិញផ្តល់ព័ត៌មានផ្សេងទៀតដែលមានលក្ខណៈគ្រប់គ្រាន់ (ភស្តុតាងផ្សេងទៀត) ដល់ប្រទេសចេញដំណើរ ឬការិយាល័យគម្យដ្ឋានថ្មី ហើយព័ត៌មាននេះនឹងត្រូវបញ្ជូនទៅការិយាល័យគម្យដ្ឋាន។

ប្រសិនបើម្ចាស់ទំនិញមិនបានផ្តល់ព័ត៌មាន ឬព័ត៌មានដែលបានផ្តល់ឱ្យអាចកែប្រែស្ថានភាព ឬព័ត៌មានដែលបានផ្តល់ឱ្យមិនគ្រប់គ្រាន់ នីតិវិធីប្រមូលបំណុលមកវិញត្រូវចាប់ផ្តើមជាបន្ទាន់។

## ១.១៥. នីតិវិធីប្រមូលបំណុលមកវិញតាមប្រព័ន្ធ ACTS

| ម្ចាស់ទំនិញ/ ធុរជន | ប្រព័ន្ធ ACTS | គយ | កំណត់សម្គាល់ |
|---|---|---|---|




រូបភាពទី១៣: នីតិវិធីទូទាត់ពន្ធនិងអាករមកវិញតាម ACTS

1. វិធានការប្រមូលបំណុលគយមកវិញចាប់ផ្តើម ប្រសិនបើ÷
    - ការកំណត់ពេលវេលា “គួរប្រមូលបំណុលមកវិញ” បានផុតពេលកំណត់
    - សំណើសុំទូទាត់បំណុលបានទទួលពីការិយាល័យគម្យដ្ឋាន ឬការិយាល័យឆ្លងកាត់ ឬ
    - មិនមានព័ត៌មាន ឬព័ត៌មានមិនគ្រប់គ្រាន់ ឬ ទទួលបានព័ត៌មានដែលអាចកែប្រែស្ថានភាព

    *ចំណាំ÷ មន្ត្រីគយក៏អាចចាប់ផ្តើមនីតិវិធីប្រមូលបំណុលមកវិញដោយផ្ទាល់ផងដែរ។*

2. មន្ត្រីគយនៅការិយាល័យចេញដំណើរអាចស៊ើបអង្កេតប្រសិនបើ ទីតាំងដែលមិនមានភាពប្រក្រតីនោះនៅក្នុងប្រទេសចេញដំណើរដើម្បីសម្រេចចិត្តថា តើខ្លួនជាទាមទារបំណុលនោះមកវិញដែរឬទេ។ ប្រសិនបើ ទីតាំងនោះស្ថិតក្នុងប្រទេសខ្លួន ការិយាល័យនោះមានសមត្ថកិច្ច និងអនុវត្តការទូទាត់បំណុលមកវិញ (៣, ៤)

5. ប្រសិនបើ ភាពមិនប្រក្រតីមិនបានកើតឡើងក្នុងប្រទេសចេញដំណើរ មន្ត្រីគយត្រូវបញ្ជូនទៅឱ្យប្រទេសគួរទទួល

6. អាជ្ញាធរមានសមត្ថកិច្ចបានទទួលសំណើសុំទូទាត់បំណុលមកវិញ ហើយសម្រេចចិត្តថាតើ ប្រទេសនោះគួរជាអ្នកទូទាត់ឬទេ។ ប្រសិនបើអាជ្ញាធរម្ចាស់សំណើ ពិតមានអាចទូទាត់បាន អាជ្ញាធរនោះនឹងចាប់ផ្តើមនីតិវិធីទូទាត់បំណុលមកវិញ (៧)

9. មន្ត្រីគណនាបរិមាណពន្ធនិងអាករដែលនឹងត្រូវទូទាត់សង

*ចំណាំ៖ នីតិវិធីប្រមូលបំណុលមកវិញមានគោលបំណងទូទាត់ពន្ធនិងអាករជាដំបូងពីម្ចាស់ទំនិញ ឬកូនបំណុលណាមួយដែលបានកំណត់ ប្រសិនបើការទូទាត់នេះមិនអាចធ្វើទៅបាន ត្រូវទូទាត់បំណុលពីអ្នកធានា (លើកលែងតែ ដំណើរការឆ្លងកាត់ត្រូវបានគ្របដណ្តប់ដោយនិមុត្តិធានាជាប្រាក់សុទ្ធ)។*

10. ក្រោយពីបញ្ចប់នីតិវិធីប្រមូលបំណុលពន្ធ និងអាករមកវិញដោយជោគជ័យពីម្ចាស់ទំនិញ ឬអ្នកធានា ដំណើរឆ្លងកាត់ត្រូវបញ្ចប់ប្រតិបត្តិការ ការបញ្ចេញនិមុត្តិធានាត្រូវបានកត់ត្រាទុកក្នុងប្រព័ន្ធ ACTS ប្រទេសទទួលប្រតិបត្តិការឆ្លងកាត់កំណត់ថា "ដំណើរការឆ្លងកាត់ត្រូវបញ្ចប់ប្រតិបត្តិការ" (១១) ម្ចាស់ទំនិញទទួលបានព័ត៌មានអំពីនីតិវិធីប្រមូលបំណុលមកវិញ៕

# សូមអរគុណ!!!

**បោះពុម្ពលើកទី១**

ចំនួន ៥០០ ច្បាប់

**រៀបចំ និង បោះពុម្ពដោយ**

នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន

នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

**ឧបត្ថម្ភគាំទ្រការបោះពុម្ពដោយ**

គម្រោងគាំទ្រការធ្វើសមាហរណកម្មតំបន់អាស៊ាន - ជំនួយ

ពាក់ព័ន្ធពាណិជ្ជកម្មកម្ពុជា (ARISE Plus Cambodia)